ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


០២-០១-២០១២ -ព្រះរាជក្រម នស/រកម/០១១២/001 ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ៤៥៩


### ២~ព្រះរាជក្រឹត្យ


០៧-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០១១ ស្តីពី ការដាក់ឱ្យចូលនិវត្តន៍ឯកឧត្តម **ចាន់ ម៉ែន** ពីឋានន្តរស័ក្តិឧត្តមអភិបាល ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ៥៥០

១២-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០១៦ ស្តីពី ការតែងតាំងឯកឧត្តម **សោម សារុន** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៥៥១

១២-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០១៨ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ជាតូបការ ចំពោះ ឯកឧត្តម **ឡោត ហ៊ួរ** ៥៥២

១២-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០១៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ មន្ត្រីរាជការ និង សប្បុរសជន ចំនួន ១២ រូប ៥៥៣

១២-០១-២០១២ -ព្រះរាជក្រឹត្យ នស/រកត/០១១២/០២០ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា តាមលំដាប់ថ្នាក់ ចំពោះ កងកម្លាំងប្រដាប់អាវុធ ,អស់លោក ,លោកស្រី និង កញ្ញា ចំនួន ៥២ រូប ៥៥៤


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


១៨-០១-២០១២-អនុក្រឹត្យលេខ ០៦ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៦០០ ហិកតា ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ ៥៥៦

១៨-០១-២០១២-អនុក្រឹត្យលេខ ០៧ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៥០០ ហិកតា ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ និង ខេត្តព្រះវិហារ ៥៥៨

១៨-០១-២០១២-អនុក្រឹត្យលេខ ០៨ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០២០ ហិកតា ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ ៥៦០

១៨-០១-២០១២-អនុក្រឹត្យលេខ ០៩ អនក្រ.បក ស្តីពី ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.១៧៣ ហិកតា ក្នុងដែនជម្រកសត្វព្រៃលំផាត់ ស្ថិតនៅក្នុងភូមិសាស្ត្រ ស្រុកលំផាត់ ខេត្តរតនគីរី ៥៦២
១៧-០១-២០១២-អនុក្រឹត្យលេខ ៦៦ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៤
១៧-០១-២០១២-អនុក្រឹត្យលេខ ៦៧ អនក្រ.តត ស្តីពី ការជូនមេដាយស្ថាបនាជាតិ ៥៦៥
១៧-០១-២០១២-អនុក្រឹត្យលេខ ៦៨ អនក្រ.តត ស្តីពី ការជូនមេដាយសហមេត្រី ៥៦៦
១៨-០១-២០១២-អនុក្រឹត្យលេខ ៦៩ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៦៧
១៨-០១-២០១២-អនុក្រឹត្យលេខ ៧០ អនក្រ.តត ស្តីពី ការទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្តព្រៃវែង អាណត្តិទី ១ លើកទី ១ ៥៦៩
១៨-០១-២០១២-អនុក្រឹត្យលេខ ៧១ អនក្រ.តត ស្តីពី ការកែសម្រួលថ្នាក់ជូនមន្ត្រីរាជការ ៥៧២
១៩-០១-២០១២-អនុក្រឹត្យលេខ ៧២ អនក្រ.តត ស្តីពី ការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ៥៧៣
១៩-០១-២០១២-អនុក្រឹត្យលេខ ៧៣ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៧៤
១៩-០១-២០១២-អនុក្រឹត្យលេខ ៧៤ អនក្រ.តត ស្តីពី ការជូនមេដាយការងារ ៥៧៥

## ២~សេចក្តីសម្រេច

១៧-០១-២០១២-សេចក្តីសម្រេចលេខ ០៥ សសរ ស្តីពី ការបំពេញបន្ថែមសមាសភាពរបស់លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត នៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ ២០១១-២០១២ ៥៧៦

## III~ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

១៣-០១-២០១២-ប្រកាសលេខ ០៩ ប្រក ស្តីពី ការគ្រប់គ្រងអាជីវកម្ម សេវាកម្ម ថតរូប ផ្តិតរូប និងថតវីដេអូ ៥៧៨
២៣-០១-២០១២-ប្រកាសលេខ ៣៧ ប្រក ស្តីពី ការធ្វើប្រតិភូកម្មមុខងារ និង ភារកិច្ចការងារវប្បធម៌ និង វិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ ៥៨០

# ព្រះរាជក្រម

នស/រកម/០១១២/ ០០១

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី១០ នីតិកាលទី២ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការត្រួតពិនិត្យគ្រឿងញៀន

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.- គោលបំណងនៃច្បាប់នេះ**

ច្បាប់នេះមានគោលបំណងបង្ការ ទប់ស្កាត់ ប្រយុទ្ធប្រឆាំងបទល្មើសគ្រឿងញៀន ត្រួតពិនិត្យរាល់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀននៅក្នុងព្រះរាជាណាចក្រកម្ពុជា និងធានាការអនុវត្តកាតព្វកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជាដែលជាភាគីនៃអនុសញ្ញា និងពិធីសាររបស់អង្គការសហប្រជាជាតិដែលទាក់ទងនឹងគ្រឿងញៀន ។

**មាត្រា ២.- គោលដៅនៃច្បាប់នេះ**

ច្បាប់នេះមានគោលដៅដូចតទៅ :

- បង្ក្រាបការដាំដុះ ការផលិត ការជួញដូរ ការចរាចរ ការរក្សាទុក និងការចែកចាយនូវគ្រឿងញៀនខុសច្បាប់
- ទប់ស្កាត់ និងលុបបំបាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់
- ព្យាបាល ស្តារនីតិសម្បទា និងធ្វើសមាហរណកម្មអ្នកញៀនគ្រឿងញៀនចូលក្នុងសង្គមវិញ
- ការពារ និងលើកកម្ពស់សុខុមាលភាពប្រជាពលរដ្ឋ
- រួមចំណែកការពារសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសុវត្ថិភាពសង្គម ។

**មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ**

ច្បាប់នេះមានវិសាលភាព លើរាល់សកម្មភាពពាក់ព័ន្ធគ្រឿងញៀននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.- និយមន័យ**

វាក្យស័ព្ទបច្ចេកទេសនៅក្នុងច្បាប់នេះ មានន័យដូចតទៅ :

**គ្រឿងញៀន** សំដៅដល់រុក្ខជាតិញៀន សារធាតុញៀន និងសារធាតុគីមីផ្សំទាំងឡាយដែលបានកំណត់ក្នុងតារាងដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

**រុក្ខជាតិញៀន** សំដៅដល់ដើមអាភៀន ដើមកូកា ដើមកញ្ឆា និងរុក្ខជាតិផ្សេងទៀតមានផ្ទុកសារធាតុញៀនដែលកំណត់ដោយរាជរដ្ឋាភិបាល ។

**សារធាតុញៀន** សំដៅដល់សារជាតុដែលបង្កឲ្យញៀន ជាអាទិ៍ សារជាតុណាកូទិក សារជាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ដែលបានមកពីការផលិត ការធ្វើសំយោគ ឬពាក់កណ្តាលសំយោគ ដូចមានចុះក្នុងតារាងទី ១ តារាងទី ២ និងតារាងទី ៣ ដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

**សារធាតុគីមីផ្សំ** សំដៅដល់សារជាតុគីមីដែលប្រើប្រាស់ក្នុងដំណើរការផលិតសារជាតុញៀន ដូចបានកំណត់នៅក្នុងតារាងទី ៤ ដែលជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

**ការផលិត** សំដៅដល់ការចំរាញ់ ឬការញែកសារជាតុញៀនចេញពីរុក្ខជាតិ ការបន្សុទ្ធ ការបំប្លែង ការផ្សំ ឬសកម្មភាពតាមគ្រប់រូបភាពផ្សេងទៀត ដើម្បីទទួលបាននូវគ្រឿងញៀន ។

**ការរក្សាទុក** សំដៅដល់ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀត នូវគ្រឿងញៀន ។

**ការដឹកជញ្ជូន** សំដៅដល់ការបញ្ជូនតាមគ្រប់រូបភាពដែលនាំឲ្យមានការផ្លាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតនូវគ្រឿងញៀន ជាអាទិ៍ តាមរយៈការផ្ញើ ការធ្វើចរាចរ ការនាំចូល ឬការនាំចេញ ។

**ការជួញដូរ** សំដៅដល់ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរនូវគ្រឿងញៀន ។

**សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន** សំដៅដល់សកម្មភាពសិក្សាស្រាវជ្រាវ ការពិសោធ ការផលិត ការដឹកជញ្ជូន ការរក្សាទុក ការជួញដូរ ការចែកចាយ ការផ្គត់ផ្គង់ ការប្រើប្រាស់នូវគ្រឿងញៀន ឬការដាំរុក្ខជាតិញៀន និងសកម្មភាពផ្សេងទៀត ដែលទទួលបានការអនុញ្ញាត ឬទទួលអាជ្ញាបណ្ណពីស្ថាប័នមានសមត្ថកិច្ច និងស្ថិតនៅក្រោមវិធានការត្រួតពិនិត្យតឹងរ៉ឹង ស្របតាមបទប្បញ្ញត្តិនៃច្បាប់ ។

**ការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន** សំដៅដល់ការអនុញ្ញាតដោយច្បាប់នេះ ឲ្យតាមដាន ត្រួតពិនិត្យ ស្រាវជ្រាវ ស៊ើបអង្កេត ឬអធិការកិច្ច នូវរាល់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ដើម្បីចាត់វិធានការទប់ស្កាត់ ឬប្រឆាំងនឹងការប្រើប្រាស់សកម្មភាពស្របច្បាប់នេះ ក្នុងគោលដៅផ្សេងទៀត ។

**ភាពញៀនគ្រឿងញៀន** សំដៅដល់ស្ថានភាពរបស់បុគ្គលស្ថិតក្រោមឥទ្ធិពល ឬភាពចំណុះនៃគ្រឿងញៀន ដោយសារការប្រើប្រាស់គ្រឿងញៀន ។

**អ្នកញៀនគ្រឿងញៀន** សំដៅដល់អ្នកដែលបានប្រើប្រាស់គ្រឿងញៀន ហើយស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀន ។

**បរិមាណសុទ្ធ** សំដៅដល់បរិមាណគ្រឿងញៀន ដោយពុំរាប់បញ្ចូលនូវអង្គធាតុលាយ និងសារធាតុផ្សេងទៀត ដែលគ្មានផ្ទុកសារធាតុញៀន ។

**ឱសថដែលមានសារធាតុញៀន** សំដៅដល់ប្រភេទឱសថព្យាបាលជំងឺដែលមានផ្ទុកនូវសារធាតុញៀនក្នុងតារាងទី ២ និងតារាងទី ៣ ហើយត្រូវបានកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**សេវាកាត់បន្ថយគ្រោះថ្នាក់នៃគ្រឿងញៀន** សំដៅដល់កម្មវិធីសេវាកម្ម ឬសកម្មភាពទាំងឡាយ ដែលជាប្រយោជន៍ធ្វើឲ្យមានការថយចុះនូវគ្រោះថ្នាក់ប៉ះពាល់ដល់សុខភាពមនុស្ស សហគមន៍ សេដ្ឋកិច្ច និងសង្គមទាំងមូល ពាក់ព័ន្ធនឹងការប្រើប្រាស់គ្រឿងញៀន ។

**ការប្រគល់ដោយមានការឃ្លាំមើល** សំដៅដល់វិធីដែលអនុញ្ញាតឲ្យមានការដឹកជញ្ជូន ការឆ្លងកាត់ ការផ្ញើ ទំនិញដែលមានការសង្ស័យថាមានគ្រឿងញៀន ឧបករណ៍ដែលអាចជួញដូរបានរូបិយវត្ថុ ដោយខុសច្បាប់ ឬសង្ស័យថាខុសច្បាប់ ចូលមកក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ឬតាមរយៈព្រះរាជាណាចក្រកម្ពុជា ទៅកាន់ប្រទេសផ្សេងទៀត ដោយមានការដឹងឮ និងការតាមដានត្រួតពិនិត្យពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងស្វែងរកប្រភព និងអត្តសញ្ញាណជនដែលជាប់ពាក់ព័ន្ធផ្សេងទៀត រួមទាំងមេដឹកនាំក្រុមឧក្រិដ្ឋជននៅក្នុងការប្រព្រឹត្តបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៥.- ចំណាត់ថ្នាក់គ្រឿងញៀន**

គ្រឿងញៀនត្រូវបានធ្វើចំណាត់ថ្នាក់ដូចខាងក្រោមនេះ :

តារាងទី១ : រុក្ខជាតិនិងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ហើយដែលពុំមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ។

តារាងទី២ : រុក្ខជាតិ និងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ ។

តារាងទី៣ : រុក្ខជាតិ និងសារធាតុដែលបណ្តាលឲ្យមានគ្រោះថ្នាក់ ប៉ុន្តែមានផលប្រយោជន៍ខាងវេជ្ជសាស្ត្រ។

តារាងទី៤ : សារធាតុគីមីផ្សំទាំងឡាយ ដែលបានចាត់ថ្នាក់ក្នុងអនុសញ្ញារបស់អង្គការសហប្រជាជាតិ ប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ និងសារធាតុដែលធ្វើឲ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៨៨ ឬក្នុងការអនុវត្តអនុសញ្ញានេះប្រឆាំងនឹងការចរាចរគ្រឿងញៀនខុសច្បាប់ ។

តារាងទី ៤ នេះ ត្រូវបានបែងចែកជាតារាងទី ៤ (I) និងតារាងទី៤ (II) ។

តារាងទាំង ៤ ខាងលើនេះ មានចែងលំអិតនៅក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់នេះ ។

**មាត្រា ៦.- ការកែប្រែចំណាត់ថ្នាក់**

តារាងទាំង ៤ ដូចមានចែងក្នុងមាត្រា ៥ (ចំណាត់ថ្នាក់គ្រឿងញៀន) ខាងលើនេះ អាចកែប្រែជាអាទិ៍ ការចុះឈ្មោះគ្រឿងញៀនថ្មី ការលុបចេញ ឬការផ្ទេរពីតារាងមួយទៅតារាងមួយបាន ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្រោយពីបានសួរយោបល់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ជំពូកទី ២
## ស្ថាប័នប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ផ្នែកទី ១
### អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**មាត្រា ៧.- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាស្ថាប័នអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនមានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន គឺជាមជ្ឈមណ្ឌលកណ្តាលក្នុងការសម្របសម្រួលសកម្មភាពប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្នុងក្របខ័ណ្ឌនៃការអនុវត្តសេចក្តីសម្រេចទាំងឡាយរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិនេះ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

### ផ្នែកទី ២
### មន្ទីរប្រឆាំងគ្រឿងញៀន

**មាត្រា ៨.- តួនាទីមន្ទីរប្រឆាំងគ្រឿងញៀន**

មន្ទីរប្រឆាំងគ្រឿងញៀននៃអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ប្រមូលផ្តុំព័ត៌មានទាំងអស់ដែលអាចសម្រួលការស្រាវជ្រាវរក និងបង្ក្រាបបទល្មើសគ្រឿងញៀនខុសច្បាប់ ហើយសម្របសម្រួលប្រតិបត្តិការទាំងអស់នៅក្នុងផ្ទៃប្រទេស ក៏ដូចជាផ្ទៃអន្តរជាតិ ដើម្បីបង្ក្រាបបទល្មើសគ្រឿងញៀន ។

## ផ្នែកទី ៣
## ស្ថាប័នត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន

### មាត្រា ៩.- ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន

ក្នុងករណីចាំបាច់ គណៈកម្មាធិការអន្តរក្រសួងមួយអាចនឹងត្រូវបង្កើតឡើងដើម្បីជាស្ថាប័នត្រួតពិនិត្យគ្រប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

ការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

## ជំពូកទី ៣
## សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

### មាត្រា ១០.- សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន

ការដាំរុក្ខជាតិញៀន ការផលិត ការដឹកជញ្ជូន ការរក្សាទុក ការជួញដូរ ការចែកចាយ ការផ្គត់ផ្គង់ ការប្រើប្រាស់នូវគ្រឿងញៀន និងសកម្មភាពផ្សេងទៀតទាក់ទងនឹងគ្រឿងញៀន ដូចមានចុះក្នុងតារាងទី ១ តារាងទី ២ និងតារាងទី ៣ ត្រូវបានហាមឃាត់ជាដាច់ខាតនៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា លើកលែងតែបានទទួលបានការអនុញ្ញាត ឬទទួលអាជ្ញាបណ្ណដោយផ្ទាល់ពីស្ថាប័នមានសមត្ថកិច្ច និងស្ថិតនៅក្រោមវិធានការត្រួតពិនិត្យតឹងរ៉ឹង ស្របតាមបទប្បញ្ញត្តិនៃច្បាប់ ។

### មាត្រា ១១.- លក្ខខណ្ឌនៃការចេញអាជ្ញាបណ្ណ ឬការអនុញ្ញាតស្តីពីគ្រឿងញៀន

អាជ្ញាបណ្ណ ឬការអនុញ្ញាតសម្រាប់បំពេញសកម្មភាពណាមួយទាក់ទងនឹងគ្រឿងញៀន ដូចមានចែងក្នុងមាត្រា ១០ (សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន) ខាងលើនេះ អាចចេញឲ្យបានលុះត្រាតែសកម្មភាពនោះ ត្រូវបានកម្រិតសម្រាប់គោលបំណងសិក្សាស្រាវជ្រាវ ពិសោធ វិទ្យាសាស្ត្រ ឬសម្រាប់គោលបំណងវេជ្ជសាស្ត្រ ឬឧស្សាហកម្មប៉ុណ្ណោះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ចំពោះអាជ្ញាបណ្ណ ត្រូវមានសុពលភាពសម្រាប់រយៈពេលមិនលើសពី ២ (ពីរ) ឆ្នាំ ។ អាជ្ញាបណ្ណនេះ អាចបន្តជាថ្មីទៀតបាន ។ អាជ្ញាបណ្ណនេះ ត្រូវកំណត់ឲ្យបានច្បាស់អំពីប្រភេទនៃសកម្មភាពទាក់ទងនឹងគ្រឿងញៀនដែលត្រូវបានអនុញ្ញាតស្របតាមច្បាប់នេះ ។ អាជ្ញាបណ្ណត្រូវបញ្ជាក់ឲ្យបានច្បាស់អំពីទីតាំងសម្រាប់ធ្វើសកម្មភាព ។

ការចេញអាជ្ញាបណ្ណ ឬការអនុញ្ញាតតម្រូវឲ្យមានការផ្ទៀងផ្ទាត់អំពីបុគ្គលិកលក្ខណៈ និងភាពចាំបាច់នៃវិជ្ជាជីវៈរបស់អ្នកស្នើសុំ ។ អាជ្ញាបណ្ណមិនត្រូវចេញឲ្យបុគ្គលណាដែលធ្លាប់ត្រូវផ្តន្ទាទោស ពីបទល្មើសដែលពាក់ព័ន្ធនឹងគ្រឿងញៀន ឬបទល្មើសសំអាតប្រាក់ពាក់ព័ន្ធនឹងសកម្មភាពគ្រឿងញៀនឡើយ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការផ្តល់ ការបន្ត ការដកហូត ការព្យួរ និងប្រភេទនៃអាជ្ញាបណ្ណ ឬការអនុញ្ញាតត្រូវកំណត់ដោយស្ថាប័នដែលមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណនេះស្របតាមបញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១២.- ការអនុញ្ញាតសម្រាប់ការសិក្សាស្រាវជ្រាវដោយប្រើប្រាស់គ្រឿងញៀន**

ដើម្បីគោលដៅនៃការសិក្សាស្រាវជ្រាវខាងវេជ្ជសាស្ត្រ វិទ្យាសាស្ត្រ ឬនគរបាលវិទ្យាសាស្ត្រ រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចអនុញ្ញាតឲ្យបុគ្គលនៃអង្គការរដ្ឋណាមួយ ដាំ ផលិត ទិញ ប្រើប្រាស់ រក្សាទុកនូវគ្រឿងញៀន ដូចមានចុះក្នុងតារាងទី ១ ទី ២ និងតារាងទី ៣ នៃច្បាប់នេះ ក្នុងបរិមាណមិនលើសពីចំនួនត្រូវការចាំបាច់ដាច់ខាត ។

បុគ្គលទទួលការអនុញ្ញាត ត្រូវចុះក្នុងសៀវភៅបញ្ជីនូវបរិមាណនៃគ្រឿងញៀនដែលខ្លួនដាំ ផលិត ទិញ ប្រើប្រាស់ និងកម្ទេចចោល ព្រមទាំងកាលបរិច្ឆេទ ប្រតិបត្តិការ និងឈ្មោះអ្នកផ្គត់ផ្គង់ ។ បញ្ជីនេះសាមីខ្លួនត្រូវរក្សាទុក ១០(ដប់) ឆ្នាំ យ៉ាងតិច ។

រៀងរាល់ឆ្នាំ អ្នកទទួលការអនុញ្ញាតត្រូវរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាលអំពីបរិមាណប្រើប្រាស់ ឬកម្ទេចចោល និងបរិមាណដែលមាននៅក្នុងសន្និធិ ។

**មាត្រា ១៣.- លក្ខខណ្ឌនៃការអនុញ្ញាតឲ្យចែកចាយ ផ្គត់ផ្គង់ និងលក់ឱសថដែលមានសារធាតុញៀន**

ការទិញឱសថដែលមានសារធាតុញៀន ដូចមានចុះក្នុងតារាងទី ២ និងតារាងទី ៣ នៃច្បាប់នេះ ក្នុងគោលបំណងផ្គត់ផ្គង់វិជ្ជាជីវៈ អាចធ្វើបានតែជាមួយនឹងបុគ្គលឯកជន ឬសហគ្រាសរដ្ឋ ដែលមានអាជ្ញាបណ្ណចេញដោយក្រសួងមានសមត្ថកិច្ច ។



រូបវន្តបុគ្គល នីតិបុគ្គលដែលអាចទិញ និងកាន់កាប់ឱសថដែលមានសារជាតុញៀន មានចុះក្នុងតារាងទី ២ និងតារាងទី ៣ ដើម្បីប្រើប្រាស់តាមតម្រូវការក្នុងវិជ្ជាជីវៈរបស់ខ្លួន ដោយពុំចាំបាច់ដាក់ពាក្យសុំអាជ្ញាបណ្ណ ឬការអនុញ្ញាត រួមមាន :

១- ឱសថការីដែលមានអាជ្ញាបណ្ណសម្រាប់ប្រកបវិជ្ជាជីវៈ នៅពេលដែលបម្រើការងារនៅក្នុងដំណើរការធម្មតានៃវិស័យពាណិជ្ជកម្ម ជាភ្នាក់ងារ ឬនិយោជិតរបស់រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានអាជ្ញាបណ្ណ សម្រាប់ចែកចាយដោយស្របច្បាប់នូវឱសថដែលមានសារជាតុញៀនដែលមានចុះក្នុងតារាងទី ២ និងតារាងទី ៣ ។

២- ឱសថការីដែលមានអាជ្ញាបណ្ណសម្រាប់ប្រកបវិជ្ជាជីវៈបម្រើការនៅមន្ទីរពេទ្យ ឬនៅមន្ទីរថែរក្សាសុខភាពឯកជន ឬសាធារណៈដែលទទួលបានអាជ្ញាបណ្ណសម្រាប់ចែកចាយឱសថដែលមានសារជាតុញៀន នៅពេលដែលបម្រើការងារនៅក្នុងដំណើរការធម្មតានៃវិស័យពាណិជ្ជកម្ម ជាភ្នាក់ងារ ឬនិយោជិតនៃមន្ទីរពេទ្យ ឬមន្ទីរថែរក្សាសុខភាពនោះ ។

៣- ឱសថការីដែលមានអាជ្ញាបណ្ណសម្រាប់ប្រកបវិជ្ជាជីវៈដែលទទួលបន្ទុកគ្រប់គ្រងកណ្ណាគារសាធារណៈ ឬឯកជនដែលទទួលបានអាជ្ញាបណ្ណសម្រាប់ចែកចាយឱសថដែលមានសារជាតុញៀន ។

៤-មន្ទីរពេទ្យ ឬមន្ទីរថែរក្សាសុខភាពដែលពុំមានឱសថការីនៅក្នុងបន្ទុកក្នុងករណីមានអាសន្ន និងក្នុងព្រឹត្តិការណ៍មិនបានដឹងមុន ឲ្យតែគ្រូពេទ្យដែលមានគុណសម្បត្តិគ្រប់គ្រាន់ណាម្នាក់នៃគ្រឹះស្ថាននោះ ហើយដែលមានអាជ្ញាបណ្ណសម្រាប់ប្រកបវិជ្ជាជីវៈ និងសម្រាប់ចែកចាយឱសថដែលមានសារជាតុញៀន បានយល់ព្រមទទួលខុសត្រូវចំពោះការគ្រប់គ្រងសន្និធិទាំងនោះ ។

គ្រូពេទ្យ ទន្តពេទ្យ បសុពេទ្យ ឆ្មប និងគិលានុបដ្ឋាកដែលមានអាជ្ញាបណ្ណឲ្យប្រកបវិជ្ជាជីវៈ អាចទិញ និងកាន់កាប់នូវបរិមាណនៃឱសថដែលមានសារជាតុញៀន តាមតម្រូវការចាំបាច់ដែលមាននៅក្នុងបញ្ជីកំណត់ដោយក្រសួងសុខាភិបាល ។

ការផ្តល់ចំពោះមនុស្ស និងសត្វទាំងឡាយនូវគ្រឿងញៀន ដូចមានចុះក្នុងតារាងទី ២ និងតារាងទី ៣ នឹងអាចធ្វើទៅបាន លុះត្រាតែការប្រើប្រាស់នោះស្ថិតក្នុងទម្រង់ជាឱសថ ដោយយោងតាមវេជ្ជបញ្ជារបស់អ្នកមានវិជ្ជាជីវៈណាម្នាក់ ក្នុងចំណោមអ្នកមានវិជ្ជាជីវៈដូចខាងក្រោម :

១- គ្រូពេទ្យដែលមានអាជ្ញាបណ្ណសម្រាប់ប្រកបវិជ្ជាជីវៈ និងអាជ្ញាបណ្ណសម្រាប់ចែកចាយឱសថដែលមានសារជាតុញៀន សម្រាប់ការព្យាបាលអ្នកជំងឺនៅក្នុងវិជ្ជាជីវៈរបស់ខ្លួន ។

២- ទន្តពេទ្យដែលមានអាជ្ញាបណ្ណសម្រាប់ប្រកបវិជ្ជាជីវៈ និងអាជ្ញាបណ្ណសម្រាប់ចែកចាយឱសថដែលមានសារជាតុញៀន សម្រាប់ការព្យាបាលប្រភេទធ្មេញណាមួយ ។

៣- បសុពេទ្យដែលមានអាជ្ញាបណ្ណសម្រាប់ប្រកបវិជ្ជាជីវៈ និងអាជ្ញាបណ្ណសម្រាប់ចែកចាយឱសថដែលមានសារជាតុញៀន សម្រាប់ព្យាបាលសត្វ ។

៤- គិលានុបដ្ឋាក ឬឆ្មបដែលមានអាជ្ញាបណ្ណសម្រាប់ប្រកបវិជ្ជាជីវៈសម្រាប់ការព្យាបាលដែលទាក់ទងនឹងការកិច្ចវិជ្ជាជីវៈរបស់ខ្លួន និងនៅក្នុងដែនកំណត់ដែលកម្រិតដោយក្រសួងសុខាភិបាល ។

ស្ថិតក្នុងស្ថានភាពនៃសេចក្តីត្រូវការចាំបាច់ និងស្ថិតក្រោមលក្ខខណ្ឌទាំងឡាយដែលខ្លួនកំណត់ រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចអនុញ្ញាតឲ្យឱសថការីដែលមានអាជ្ញាបណ្ណ ឬអ្នកចែកចាយ ឬអ្នកលក់រាយផ្សេងទៀតដែលមានអាជ្ញាបណ្ណឲ្យផ្គត់ផ្គង់នៅលើដែនដីជាតិទាំងមូល ឬមួយផ្នែក ដោយពុំចាំបាច់មានវេជ្ជបញ្ជា នូវបរិមាណតិចតួចនៃឱសថដែលមានសារជាតុញៀនមួយ ឬច្រើនប្រភេទដូចមានចុះក្នុងតារាងទី ៣ ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចកំណត់នូវវិធានផ្សេងទៀតទាក់ទងនឹងការអនុវត្តមាត្រានេះ ជាពិសេស វិធានទាក់ទងនឹងការសរសេរ និងការបំពេញវេជ្ជបញ្ជាទាក់ទងនឹងឱសថដែលមានសារជាតុញៀនដូចមានចុះក្នុងតារាងទី ២ និងតារាងទី ៣ ។

## ផ្នែកទី ២

## ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណ ឬការអនុញ្ញាត ទាក់ទងនឹងគ្រឿងញៀន

### មាត្រា ១៤.- អាជ្ញាបណ្ណ ឬការអនុញ្ញាតសម្រាប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ១ ទី ២ និងទី ៣

ក្រសួងសុខាភិបាលត្រូវបានប្រគល់សិទ្ធិក្នុងការផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត និងការត្រួតពិនិត្យសម្រាប់គ្រប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនដូចមានចុះក្នុងតារាងទី ១ ទី ២ និងតារាងទី ៣ ជាឧបសម្ព័ន្ធនៃច្បាប់នេះ ។

ប្រសិនបើមានភាពចាំបាច់ក្នុងការប្រើប្រាស់គ្រឿងញៀន ដូចមានចុះក្នុងតារាងទី ១ ទី ២ និងតារាងទី ៣ ខាងលើ សម្រាប់គោលដៅបម្រើឲ្យផលិតកម្មឧស្សាហកម្ម ក្រសួងសុខាភិបាលក៏អាចផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាតឲ្យផងដែរ ។ ក្នុងករណីនេះ អ្នកស្នើសុំត្រូវបង្ហាញឲ្យបានច្បាស់លាស់ និងគ្រប់គ្រាន់ថា ការប្រើប្រាស់គ្រឿងញៀននេះមានភាពចាំបាច់ចំពោះដំណើរការផលិតកម្មឧស្សាហកម្ម ហើយ

គ្រឿងញៀនដែលអនុញ្ញាតឲ្យយកទៅប្រើប្រាស់ ផ្សំ ឬបង្កើតជាផលិតផលឧស្សាហកម្មណាមួយនោះ នឹងមិនអាចយកចេញពីផលិតផលឧស្សាហកម្មនេះវិញបានដោយងាយស្រួលឡើយ ។ អ្នកស្នើសុំត្រូវភ្ជាប់មកជាមួយពាក្យសុំអាជ្ញាបណ្ណនូវលិខិតបញ្ជាក់ពីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**មាត្រា ១៥.- អាជ្ញាបណ្ណ ឬការអនុញ្ញាតសម្រាប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ៤**

ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវបានប្រគល់សិទ្ធិក្នុងការផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត និងការត្រួតពិនិត្យ សម្រាប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនដូចមានចុះក្នុងតារាងទី ៤ ជាឧបសម្ព័ន្ធនៃច្បាប់នេះ សម្រាប់គោលដៅបម្រើឲ្យផលិតកម្មឧស្សាហកម្មប៉ុណ្ណោះ ។

ក្រៅពីគោលដៅបម្រើឲ្យផលិតកម្មឧស្សាហកម្ម ការផ្តល់អាជ្ញាបណ្ណ ឬការអនុញ្ញាត និងការត្រួតពិនិត្យសម្រាប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនដូចមានចុះក្នុងតារាងទី ៤ គឺជាសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល ។

## ជំពូកទី ៣
## ការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន

**មាត្រា ១៦.- វិធានការត្រួតពិនិត្យផលិតផលលាយផ្សំ**

ចំពោះផលិតផលដែលលាយផ្សំឡើងដោយគ្រឿងញៀនមួយ ឬច្រើនមុខ ទោះបីក្នុងទម្រង់ជាល្បាយរឹង ឬរាវក៏ដោយ ត្រូវស្ថិតនៅក្រោមវិធានការគ្រប់គ្រង និងត្រួតពិនិត្យដូចគ្នាទៅនឹងគ្រឿងញៀនដែលជាសារធាតុផ្សំ ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១៧.- ការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម**

ត្រូវហាមឃាត់ :

- ការផ្សព្វផ្សាយពាណិជ្ជកម្មអំពីរុក្ខជាតិ សារធាតុ និងគ្រឿងផ្សំ ឬឱសថ ដូចមានចុះក្នុងតារាងទី ២ និងតារាងទី ៣ នៃច្បាប់នេះ
- ការផ្តល់គំរូ ឬរូបមន្តឱសថទៅឲ្យឯកជន ការផ្តល់គំរូរុក្ខជាតិ សារធាតុ ឬគំរូគ្រឿងផ្សំ ដូចមានចុះក្នុងតារាងទី ២ និងតារាងទី ៣ នៃច្បាប់នេះ

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវធ្វើសេចក្តីណែនាំបន្ថែម ពាក់ព័ន្ធទៅនឹងការផ្សាយពាណិជ្ជកម្មឱសថដែលមានផ្ទុកសារធាតុដូចមានចុះក្នុងតារាងទី ៤ ។

**មាត្រា ១៨.- ការត្រួតពិនិត្យការឆ្លងកាត់ ឬការឈប់សំចតនៃគ្រឿងញៀន**

ការឆ្លងកាត់និងការសំចតនៃគ្រឿងញៀន ដូចមានចុះក្នុងតារាងទី ២ និងតារាងទី ៣ លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់ ទោះបីគ្រឿងញៀននោះដាក់ចុះ ឬមិនដាក់ចុះពីមធ្យោបាយដឹកជញ្ជូនក៏ដោយ លើកលែងតែការទិញ ការដឹកជញ្ជូន និងការរក្សាទុកដើម្បីផលិតឱសថ ឬផលិតផលសម្រេចសម្រាប់ព្យាបាលមនុស្ស ឬសត្វដែលត្រូវស្ថិតនៅក្រោមការអនុញ្ញាត ឬអាជ្ញាបណ្ណ និងការត្រួតពិនិត្យដោយក្រសួងសុខាភិបាល ។

**មាត្រា ១៩.- បទប្បញ្ញត្តិចំពោះសារធាតុគីមីផ្សំក្នុងតារាងទី ៤**

ការផលិត ការនាំចេញ ការនាំចូល ការកាន់កាប់ ការលក់ ការទិញ ឬការចែកចាយនូវសារធាតុគីមីផ្សំដូចមានចុះក្នុងតារាងទី ៤ ត្រូវគោរពតាមបទប្បញ្ញត្តិដូចខាងក្រោម :

១- ការអនុញ្ញាតឲ្យមានការនាំចូល ឬការនាំចេញ ត្រូវបដិសេធ ប្រសិនបើទំនិញអាចត្រូវបានប៉ុនប៉ងប្រគល់ឲ្យសម្រាប់ផលិតដោយខុសច្បាប់នូវគ្រឿងញៀន ។

២- ទំនិញនាំចូល ឬនាំចេញ ជាសារធាតុដូចមានចុះក្នុងតារាងទី ៤ ជាឧបសម្ព័ន្ធនៃច្បាប់នេះត្រូវបិទស្លាកសញ្ញាឲ្យបានច្បាស់ តាមបទប្បញ្ញត្តិជាធរមាន ។

៣- បុគ្គលណាដែលបានដឹងព្រោះតែតម្រូវការនៃមុខរបររបស់ខ្លួននូវអាថ៌កំបាំងខាងសេដ្ឋកិច្ច ឧស្សាហកម្ម ឬវិជ្ជាជីវៈ ឬដំណើរការពាណិជ្ជកម្មនៃសារធាតុគីមីផ្សំដូចមានចុះក្នុងតារាងទី ៤ មិនត្រូវប្រាប់ដល់តតិយជនឡើយ ។

៤-អ្នកផលិត អ្នកនាំចូល អ្នកនាំចេញ អ្នកលក់ដុំ និងអ្នកលក់រាយនូវសារធាតុគីមីផ្សំដូចមានចុះក្នុងតារាងទី ៤ ត្រូវផ្តល់ដំណឹងដល់នគរបាល ឬមន្ត្រីមានសមត្ថកិច្ចអំពីការបញ្ជាទិញ ឬកិច្ចការជំនួញដែលសំដែងឲ្យមានការសង្ស័យ ជាពិសេសដោយមូលហេតុបរិមាណនៃសារធាតុដែលត្រូវបានទិញ ឬបញ្ជាទិញចំនួនច្រើនដងនៃការបញ្ជាទិញ ឬការទិញ ឬមធ្យោបាយដែលប្រើប្រាស់សម្រាប់ការបង់ប្រាក់ ឬការដឹកជញ្ជូន ។

៥- ប្រសិនបើមានតម្រុយដែលបង្ហាញឲ្យឃើញថាសារធាតុគីមីផ្សំណាមួយ ដូចមានចុះក្នុងតារាងទី ៤ ត្រូវយកទៅប្រើប្រាស់ក្នុងគោលបំណងសម្រាប់ផលិតដោយខុសច្បាប់នូវគ្រឿងញៀន ត្រូវចាប់យកសារធាតុនោះភ្លាម រង់ចាំលទ្ធផលនៃការស៊ើបអង្កេតរបស់តុលាការ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ២០.- ព័ត៌មានដែលត្រូវរាយការណ៍**

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវផ្តល់របាយការណ៍ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងត្រូវចម្លងជូនទៅក្រសួងសុខាភិបាលនូវព័ត៌មាន ដូចខាងក្រោមនេះ :

១- ការផ្តល់ ការបន្ត ការដកហូត និងការព្យួរអាជ្ញាបណ្ណដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន ។

២- ការផ្តល់ ការបន្ត ការដកហូត និងការព្យួរលិខិតអនុញ្ញាត ជាពិសេស លិខិតអនុញ្ញាតទាក់ទងនឹងការនាំចេញ ការនាំចូល ដោយមានបញ្ជាក់អំពីសារធាតុគីមីផ្សំដូចមានចុះក្នុងតារាងទី ៤ ។

៣- ចំនួនពិតនៃការនាំចូល និងការនាំចេញនូវសារធាតុគីមីផ្សំដូចមានចុះក្នុងតារាងទី ៤ ។

៤- ចំនួនដែលមានការប៉ាន់ស្មានប្រចាំឆ្នាំដែលគម្រោងនាំចូល និងនាំចេញនូវសារធាតុគីមីផ្សំដូចមានចុះក្នុងតារាងទី ៤ ។

៥- ចំនួនជាក់ស្តែងនៃគម្រោងនាំចេញ នាំចូលសារធាតុគីមីផ្សំដូចមានចុះក្នុងតារាងទី ៤ ។

៦- ព័ត៌មានដែលទទួលបានទាក់ទងនឹងសារធាតុគីមីផ្សំ ដូចមានចុះនៅក្នុងតារាងទី ៤ ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវផ្តល់របាយការណ៍ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀននូវព័ត៌មានអំពីការនាំចូល ការនាំចេញ និងសន្និធិនូវសារធាតុគីមីផ្សំដូចមានចុះក្នុងតារាងទី ៤ ។

**មាត្រា ២១.- ការកំណត់បរិមាណនៃសេចក្តីត្រូវការនូវគ្រឿងញៀន**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលកំណត់ ១ (មួយ) ឆ្នាំម្តង នូវបរិមាណអតិបរមានៃគ្រឿងញៀនដែលសហគ្រាសរដ្ឋ និងសហគ្រាសឯកជនត្រូវការប្រើប្រាស់ និងផលិតតាមសេចក្តីត្រូវការជាក់ស្តែង និងត្រូវរាយការណ៍ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនក្នុង ១ (មួយ) ឆ្នាំម្តង នូវបរិមាណគ្រឿងញៀនដែលបានកំណត់ប្រចាំឆ្នាំ និងដែលបានប្រើប្រាស់ ព្រមទាំងបរិមាណដែលនៅសល់ក្នុងសន្និធិ ។

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កំណត់ ១ (មួយ) ឆ្នាំម្តង នូវបរិមាណអតិបរមានៃសារធាតុគីមីផ្សំតាមសេចក្តីត្រូវការជាក់ស្តែង និងត្រូវរាយការណ៍ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ក្នុង ១ (មួយ) ឆ្នាំម្តង នូវបរិមាណសារធាតុគីមីផ្សំដែលបានកំណត់ប្រចាំឆ្នាំ និងដែលបានប្រើប្រាស់ ព្រមទាំងបរិមាណដែលនៅសល់ក្នុងសន្និធិ ។

**មាត្រា ២២.- ភាតព្វកិច្ចក្នុងការចុះបញ្ជី**

អ្នកផលិត អ្នកនាំចូល អ្នកនាំចេញ អ្នកលក់ដុំ និងអ្នកលក់រាយដែលបានទទួលអាជ្ញាបណ្ណ ឬការអនុញ្ញាតដើម្បីធ្វើសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬពី

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវតែចុះក្នុងសៀវភៅបញ្ជីដែលមានបង់លេខទំព័រ និងចុះហត្ថលេខាសង្ខេបរបស់អាជ្ញាធរមានសមត្ថកិច្ច នូវរាល់ការទិញ ការលក់ ការប្រើប្រាស់ និងប្រតិបត្តិការផ្សេងទៀតដែលប៉ះពាល់ដល់បរិមាណសារធាតុដូចមានចុះក្នុងតារាងទី ២ តារាងទី ៣ និងតារាងទី ៤ ។

ការចុះក្នុងសៀវភៅបញ្ជីនេះត្រូវធ្វើនៅពេលប្រតិបត្តិការ ដោយឥតទុកចន្លោះ ឥតកោសលុប និងឥតសរសេរត្រួតគ្នា ។

ការចុះក្នុងសៀវភៅបញ្ជីនេះត្រូវសរសេរបញ្ជាក់ថ្ងៃខែឆ្នាំនៃប្រតិបត្តិការ ឈ្មោះ និងចំនួននៃផលិតផលដែលទទួលបាន ឬលក់ចេញ នាម អាសយដ្ឋាន និងមុខរបររបស់អ្នកទទួលទិញ ឬអ្នកលក់ ។

សៀវភៅបញ្ជីនេះត្រូវរក្សាទុកក្នុងរយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីថ្ងៃចុះបញ្ជីចុងក្រោយតាមលក្ខខណ្ឌកំណត់របស់គណៈកម្មការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ត្រូវធ្វើការណែនាំបន្ថែមអំពីការរៀបចំសៀវភៅបញ្ជីនេះ ។

**មាត្រា ២៣.- ការធ្វើបញ្ជីសារពើភណ្ឌ និងការគណនាសមតុល្យ**

សហគ្រាសរដ្ឋ សហគ្រាសឯកជន ស្ថាប័នវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រ ព្រមទាំងបុគ្គលផ្សេងទៀតដែលធ្វើសកម្មភាព ឬអ្នកមានអាជ្ញាបណ្ណប្រតិបត្តិការ និងការអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ត្រូវធ្វើនៅរៀងរាល់ដើមឆ្នាំនូវបញ្ជីសារពើភណ្ឌគ្រឿងញៀន មានចុះក្នុងតារាងទី ១ តារាងទី ២ តារាងទី ៣ ដែលខ្លួនកាន់កាប់ និងប្រៀបធៀបទៅនឹងបរិមាណសរុបនៅក្នុងសន្និធិនៃបញ្ជីសារពើភណ្ឌមុនដែលត្រូវគណនារួមគ្នាជាមួយបរិមាណដែលកាន់កាប់នៅក្នុងបញ្ជីសារពើភណ្ឌចុងក្រោយបង្អស់ ។

ម្ចាស់អាជ្ញាបណ្ណ ឱសថការី និងបុគ្គលទាំងឡាយដែលបានទទួលអាជ្ញាបណ្ណ ឬការអនុញ្ញាតឲ្យចែកចាយឱសថដែលមានសារធាតុញៀន តាមរយៈកន្លែងលក់ដុំ តាមឱសថស្ថាន ឬឱសថស្ថានរង ត្រូវធ្វើបញ្ជីសារពើភណ្ឌ និងគណនាសមតុល្យដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

ភាពខុសគ្នាណាមួយដែលកត់សម្គាល់ឃើញនៅក្នុងលទ្ធផលប្រៀបធៀបសមតុល្យ ឬរវាងលទ្ធផលសមតុល្យ និងបញ្ជីសារពើភណ្ឌ ម្ចាស់អាជ្ញាបណ្ណ ឱសថការី អ្នកទទួលអាជ្ញាបណ្ណ ឬការអនុញ្ញាតឲ្យចែកចាយឱសថដែលមានសារធាតុញៀន ត្រូវរាយការណ៍ភ្លាមជូនក្រសួងសុខាភិបាល ដែលត្រូវបញ្ជាក់ថាបានទទួលលិខិតជូនដំណឹងនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា ២៤.- ការវេចខ្ចប់ និងការដាក់ស្លាកសញ្ញា

ការចែកចាយគ្រឿងញៀន ដូចមានចុះក្នុងតារាងទី ២ និងតារាងទី ៣ អាចធ្វើទៅបាន លុះត្រាតែគ្រឿងញៀននោះត្រូវបានវេចខ្ចប់នៅក្នុងកញ្ចប់ ឬប្រអប់ដែលមានសរសេរឈ្មោះរបស់វា និងក្នុងករណីដែលមានការផ្ញើគ្រឿងញៀន ដូចមានចុះក្នុងតារាងទី ២ កញ្ចប់ ឬប្រអប់នោះ ត្រូវតែបិទជិតបោះត្រាសម្គាល់ និងវេចខ្ចប់ដោយចំណងសុវត្ថិភាព ។

ការវេចខ្ចប់ជាកញ្ចប់ខាងក្រៅ ដូចចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវដាក់ព័ត៌មានអ្វីក្រៅពីឈ្មោះ និងអាសយដ្ឋានរបស់អ្នកផ្ញើ និងអ្នកទទួលឡើយ ។ កញ្ចប់ទាំងនេះត្រូវបិទជិត និងបោះត្រាដែលជានិមិត្តសញ្ញារបស់អ្នកផ្ញើ ។

ស្លាកសញ្ញាដែលក្នុងនោះមានឱសថដែលមានសារជាតុញៀនណាមួយ ត្រូវបានប្រគល់ជូនសម្រាប់លក់ ត្រូវចង្អុលបង្ហាញឈ្មោះនៃសារជាតុញៀនដែលជាធាតុផ្សំរបស់វា រួមជាមួយគ្នានឹងភាគរយ និងទម្ងន់របស់សារជាតុនោះ ។

ស្លាកសញ្ញាដែលភ្ជាប់មកជាមួយនឹងកញ្ចប់សម្រាប់លក់រាយ ឬចែកចាយដូចមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវចង្អុលបង្ហាញការណែនាំសម្រាប់ការប្រើប្រាស់ ព្រមទាំងការប្រុងប្រយ័ត្ន និងការប្រាប់ឲ្យដឹងមុនជាចាំបាច់ សម្រាប់សុវត្ថិភាពរបស់អ្នកប្រើប្រាស់ ។

ក្នុងករណីចាំបាច់ លក្ខខណ្ឌបន្ថែមទាក់ទងនឹងការវេចខ្ចប់ និងការដាក់ស្លាកសញ្ញាត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## មាត្រា ២៥.- ការត្រួតពិនិត្យ និងអធិការកិច្ច

គ្រប់បុគ្គល សហគ្រាសឯកជន សហគ្រាសរដ្ឋ គ្រឹះស្ថានវេជ្ជសាស្ត្រ គ្រឹះស្ថានឱសថសាស្ត្រ និងគ្រឹះស្ថានវិទ្យាសាស្ត្រដែលធ្វើសកម្មភាព ឬប្រតិបត្តិការណាមួយដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាតស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការឃ្លាំមើលរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដែលត្រូវចាត់អធិការឱសថសាស្ត្រឲ្យធ្វើអធិការកិច្ចសាមញ្ញ យ៉ាងតិច ១ (មួយ) ឆ្នាំម្តង និងធ្វើអធិការកិច្ចវិសាមញ្ញតាមការចាំបាច់ លើគ្រឹះស្ថាន កន្លែងសន្និធិ និងលើការកត់ត្រាចុះបញ្ជី ។ អធិការនៃក្រសួងសុខាភិបាលអាចសុំកម្លាំងជំនួយចាំបាច់ដើម្បីធ្វើអធិការកិច្ច ។

ត្រូវស្ថិតក្រោមការត្រួតពិនិត្យ និងការឃ្លាំមើលខាងលើនេះដែរ បន្ទប់ដែលតម្កល់ប្រអប់ដាក់ថ្នាំសម្រាប់សង្គ្រោះ ដែលមាននៅក្នុងមធ្យោបាយដឹកជញ្ជូនសាធារណៈដែលធ្វើការដឹកជញ្ជូនអន្តរជាតិ ។

គ្រប់បុគ្គល ក្រុមហ៊ុន រោងចក្រ សហគ្រាសដែលធ្វើសកម្មភាព ឬប្រតិបត្តិការណាមួយ ដែលមានអាជ្ញាបណ្ណ ឬការអនុញ្ញាត ស្របតាមកថាខណ្ឌទី ១ មាត្រា ១៥ (អាជ្ញាបណ្ណ ឬការអនុញ្ញាតសម្រាប់

សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ៤) នៃច្បាប់នេះ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យ និងការឃ្លាំមើលរបស់រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវចាត់អធិការឲ្យធ្វើអធិការកិច្ចសាមញ្ញ យ៉ាងតិច ១(មួយ) ឆ្នាំម្តង និងធ្វើអធិការកិច្ចវិសាមញ្ញតាមការចាំបាច់លើគ្រឹះស្ថានកន្លែងសន្និធិ និងលើការកត់ត្រាចុះបញ្ជី ។ អធិការនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល អាចសុំកម្លាំងជំនួយចាំបាច់ដើម្បីធ្វើអធិការកិច្ច ។

បែបបទនិងនីតិវិធីនៃការត្រួតពិនិត្យ និងធ្វើអធិការកិច្ច ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងសាមី ។

**មាត្រា ២៦.- ការត្រួតពិនិត្យតាមដាននៅកំពង់ផែរួចពន្ធ និងតំបន់រួចពន្ធ**

វិធានការត្រួតពិនិត្យ និងតាមដានដែលមានចែងក្នុងច្បាប់នេះ ក៏ត្រូវប្រព្រឹត្តទៅនៅកំពង់ផែរួចពន្ធ និងនៅតំបន់រួចពន្ធដែរ ។

## ជំពូកទី ៤
## បទប្បញ្ញត្តិព្រហ្មទណ្ឌ

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ២៧.- ការអនុវត្តបទប្បញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ**

បទប្បញ្ញត្តិនៃគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងពិសេសផ្សេងនៅក្នុងច្បាប់នេះ ។

**មាត្រា ២៨.- ការប្រកាសមូលទោស**

បទប្បញ្ញត្តិនៃមាត្រា ៩៧ (ការប្រកាសមូលទោស) នៃក្រមព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តឡើយ ចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ ។ ការប្រកាសមូលទោសត្រូវអនុវត្ត ដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មូលទោសចំពោះបទល្មើសទាំងឡាយដូចមានចែងក្នុងច្បាប់នេះ មិនអាចត្រូវបានជំនួសដោយទោសជំនួស ឬទោសបន្ថែមតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌឡើយ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ២៩.- និយមន័យនៃការប៉ុនប៉ង**

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងបទមជ្ឈិម អាចត្រូវផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

- ចារីបានចាប់ផ្តើមអនុវត្តបទល្មើស មានន័យថាចារីបានប្រព្រឹត្តអំពើដែលមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស និង
- ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខានដោយឥទ្ធិពលនៃកាលៈទេសៈក្រៅឆន្ទៈរបស់ខ្លួន ។

អំពើត្រៀមបម្រុងដែលពុំមានគោលបំណងដោយផ្ទាល់ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្តើមអនុវត្តទេ ។

ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវផ្តន្ទាទោសដូចគ្នានឹងបទឧក្រិដ្ឋ ឬបទមជ្ឈិមបានសម្រេចដែរ ។

**មាត្រា ៣០.- ការបង្ខំឲ្យទទួលការព្យាបាល**

តុលាការត្រូវសម្រេចបង្ខំឲ្យទទួលការព្យាបាលដូចមានចែងក្នុងជំពូកទី ៦ (វិធានការព្យាបាល និងស្តារនីតិសម្បទា) នៃច្បាប់នេះ ចំពោះបុគ្គលដែលត្រូវបានផ្តន្ទាទោសចំពោះបទល្មើសណាមួយដែលមានចែងក្នុងច្បាប់នេះ ប្រសិនបើបុគ្គលនេះស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀន ។

**មាត្រា ៣១.- ការលើកលែងឲ្យរួចផុតពីទោស**

បុគ្គលណាដែលបានចូលរួមក្នុងក្រុមឧក្រិដ្ឋជន ដើម្បីប្រព្រឹត្តបទល្មើសណាមួយដូចមានចែងក្នុងច្បាប់នេះ ត្រូវបានលើកលែងឲ្យរួចផុតពីការទទួលទោស ដូចមានចែងក្នុងមាត្រា ៥៩ (បទចូលរួមក្នុងក្រុមឧក្រិដ្ឋជន) នៃច្បាប់នេះ ប្រសិនបើបុគ្គលនោះបានរាយការណ៍មុនពេលបទល្មើសនោះកើតឡើងអំពីអត្ថិភាពនៃក្រុមឧក្រិដ្ឋជននេះ ជូនអាជ្ញាធរមានសមត្ថកិច្ចឲ្យមានពេលវេលាគ្រប់គ្រាន់ដើម្បីចាត់វិធានការចំពោះបទល្មើសនោះ ហើយបាននាំឲ្យស្គាល់អត្តសញ្ញាណនៃអ្នកចូលរួមដទៃទៀត ។

**មាត្រា ៣២.- ការសម្រាលទោស**

ក្រៅពីករណីដែលមានចែងក្នុងមាត្រាខាងលើនេះ ចារី សហចារី អ្នកសមគំនិត ឬអ្នកផ្តើមគំនិតក្នុងបទល្មើសដែលមានចែងក្នុងជំពូកទី ៤ (បទប្បញ្ញត្តិព្រហ្មទណ្ឌ) នៃច្បាប់នេះ ដែលបានរាយការណ៍ឲ្យស្គាល់អំពីអត្តសញ្ញាណអ្នកចូលរួមដទៃទៀតមុនពេលដែលខ្លួនត្រូវបានចោទប្រកាន់ ឬដែលបានជួយ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

សម្រួលឲ្យមានការចាប់ខ្លួនជនដទៃទៀត ក្រោយពេលដែលខ្លួនត្រូវបានចោទប្រកាន់ ត្រូវបានបន្ថយទោសនៅក្នុងលក្ខខណ្ឌដូចតទៅ :

១- អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២- ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣- អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ៣៣.- ការអនុវត្តស្ថានសម្រាលទោស**

បទប្បញ្ញត្តិនៃមាត្រា ៩៣ (និយមន័យនៃស្ថានសម្រាលទោស) ដល់មាត្រា ៩៥ (ទោសដាក់ពន្ធនាគារអស់មួយជីវិត និងស្ថានសម្រាលទោស) នៃក្រមព្រហ្មទណ្ឌ មិនត្រូវយកមកអនុវត្តឡើយ ចំពោះបទឧក្រិដ្ឋទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ។

ចំពោះបទមជ្ឈិមដែលមានចែងក្នុងច្បាប់នេះ តុលាការអាចសម្រេចឲ្យជនជាប់ចោទបានទទួលនូវស្ថានសម្រាលទោសតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ ។ ក្នុងករណីនេះ អប្បបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសនោះត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារលើសពី ១ (មួយ) ថ្ងៃ ។

**មាត្រា ៣៤.- ទោសបន្ថែមសម្រាប់រូបវន្តបុគ្គល**

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ៥៤ (លក្ខខណ្ឌនៃការប្រកាសទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងផ្នែកទី ២ (ទោសបន្ថែម) ជំពូកទី ១ (ប្រភេទនៃទោស) មាតិកាទី ៣ (ទោស) គន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា ៣៥.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល**

នីតិបុគ្គល លើកលែងតែរដ្ឋចេញ អាចត្រូវបានប្រកាសឲ្យទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ ក្នុងលក្ខខណ្ឌដែលបទល្មើសនេះ ត្រូវបានប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួនដើម្បីជាប្រយោជន៍ដល់នីតិបុគ្គលនោះ ។

ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល មិនលើកលែងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលនោះទេ ។

**មាត្រា ៣៦.- មូលទោសអនុវត្តចំពោះនីតិបុគ្គល**

ក្នុងករណីដែលតុលាការប្រកាសឲ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌ តុលាការត្រូវប្រកាសទោសពិន័យក្នុងឋានៈជាមូលទោស ដែលមានទឹកប្រាក់អតិបរមាស្មើនឹង ៥ (ប្រាំ) ដង នៃអតិបរមាទោសពិន័យជាប្រាក់សម្រាប់រូបវន្តបុគ្គលដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣៧.- ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល**

ជាបដិប្បញ្ញត្តិទៅនឹងមាត្រា ១៦៩ (លក្ខខណ្ឌនៃការសម្រេចអំពីទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងនៅក្នុងផ្នែកទី ២ (ទោសបន្ថែម) ជំពូកទី ៧ (ទោសដែលត្រូវអនុវត្តចំពោះនីតិបុគ្គល) មាតិកាទី ៣ (ទោស) គន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមព្រហ្មទណ្ឌ ។

## ផ្នែកទី ២
## បទល្មើសទាក់ទងនឹងគ្រឿងញៀន
## ក្នុងតារាងទី ១ និងតារាងទី ២

**មាត្រា ៣៨.- បទជាំដោយខុសច្បាប់នូវរុក្ខជាតិញៀន**

ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការដាំរុក្ខជាតិញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ :

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១.០០០.០០០(មួយលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសនេះធ្វើឡើងក្នុងគោលបំណងចែកចាយ ផលិត ឬធ្វើពាណិជ្ជ-កម្ម ។

ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្តក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន មានបរិមាណតិចតួច និងប្រព្រឹត្តក្នុងក្របខ័ណ្ឌទទួលទានតាមទម្លាប់ ព្រះរាជអាជ្ញាអាចឲ្យជនប្រព្រឹត្តរួចខ្លួនពីបទចោទ ។ ប្រសិនបើរឿងនេះទៅដល់តុលាការ តុលាការអាចសម្រេចឲ្យចារីនៃហេតុការណ៍នេះ មិនបាច់ទទួលទោស ឬគ្រាន់តែស្តីបន្ទោសជននោះតែប៉ុណ្ណោះ ។ ត្រូវចាត់ទុកថាជាការទទួលទានតាមទម្លាប់ ការទទួលទាន ដែលមិនបណ្តាលឲ្យញៀន ហើយអ្នកទទួលទានជាអ្នកស្រុកទទួលទានតាមជូនតាធ្លាប់ប្រព្រឹត្តជាយូរមកហើយ ។

**មាត្រា ៣៩.- បទផលិតដោយខុសច្បាប់នូវសារធាតុញៀន**

ការចំរាញ់ ឬការញែកសារធាតុញៀនចេញពីរុក្ខជាតិ ការបន្សុទ្ធ ការបំប្លែង ការផ្សំ ឬសកម្មភាពតាមគ្រប់រូបភាពផ្សេងទៀតដោយខុសច្បាប់ដើម្បីទទួលបាននូវគ្រឿងញៀន គឺជាអំពើផលិតដោយខុសច្បាប់នូវសារធាតុញៀន ។

បទផលិតដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

៣- បើការផលិតជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ៤០០(បួនរយ) ក្រាម រហូតដល់ក្រោម ៨០០ (ប្រាំបីរយ) ក្រាម ។

៤-បើការផលិតប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ២០០ (ពីររយ) ក្រាម រហូតដល់ក្រោម ៤០០ (បួនរយ) ក្រាម ។

៥- បើការផលិតម៉ាហ្វេីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ៤ (បួន) ក្រាម រហូតដល់ក្រោម ២៥ (ម្ភៃប្រាំ) ក្រាម ។

៦- បើការផលិតអំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ។

៧- បើការផលិតបណ្តាសារធាតុញៀនផ្សេងទៀតដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ។

៨- បើការផលិតសារធាតុញៀនចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពីចំណុចទី ៣ ដល់ចំណុចទី ៧ នៃកថាខណ្ឌនេះ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- មានលក្ខណៈជាមុខរបរ ។

២- បើការផលិតជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ៨០០ (ប្រាំបីរយ) ក្រាម រហូតដល់ក្រោម ១.៦០០ (មួយពាន់ប្រាំមួយរយ) ក្រាម ។

៣- បើការផលិតប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៤០០ (បួនរយ) ក្រាម រហូតដល់ក្រោម ៨០០ (ប្រាំបីរយ) ក្រាម ។

៤- បើការផលិតម៉ាហ្វេីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ២៥ (ម្ភៃប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ។

៥- បើការផលិតអំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រោម ២៤០ (ពីររយសែសិប) ក្រាម ។

៦- បើការផលិតបណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ផ្សេងទៀតមានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រោម ២៤០ (ពីររយសែសិប) ក្រាម ។

៧- បើការផលិតសារធាតុញៀនចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពីចំណុចទី ២ ដល់ចំណុចទី ៦ ក្នុងកថាខណ្ឌទី ៤ ខាងលើនេះ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និង ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចមាន ខាងក្រោមនេះ :

១- បើការផលិតជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ១.៦០០ (មួយ ពាន់ប្រាំមួយរយ) ក្រាមឡើងទៅ ។

២- បើការផលិតប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៨០០ (ប្រាំបីរយ) ក្រាម ឡើងទៅ ។

៣- បើការផលិតម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីន មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាមឡើងទៅ ។

៤- បើការផលិតអំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ២៤០ (ពីររយសែសិប) ក្រាមឡើងទៅ ។

៥- បើការផលិតបណ្តាសារធាតុញៀនផ្សេងទៀតដែលស្ថិតនៅក្នុងតារាងទី ១ និងតារាង ទី ២ មានបរិមាណសុទ្ធចាប់ពី ២៤០ (ពីររយសែសិប) ក្រាមឡើងទៅ ។

៦- បើការផលិតសារធាតុញៀនចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុប នៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចទី ១ ដល់ចំណុចទី ៥ នៃកថាខណ្ឌនេះ ។

**មាត្រា ៤០.- បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**

ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់នូវ សារធាតុញៀន គឺជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។

ការបញ្ជូនតាមគ្រប់រូបភាពដែលនាំឲ្យមានការផ្លាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ពី មនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀន ជាអាទិ៍ តាមរយៈការផ្ញើ ការធ្វើចរាចរ ការនាំចូល ឬការនាំចេញ គឺជាអំពើដឹកជញ្ជូនដោយខុសច្បាប់នូវ សារធាតុញៀន ។

ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារ-ធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់

ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០(បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

៣- ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ៤០០ (បួនរយ) ក្រាម រហូតដល់ក្រោម ៨០០ (ប្រាំបីរយ) ក្រាម ។

៤- ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ២០០ (ពីររយ) ក្រាម រហូតដល់ក្រោម ៤០០ (បួនរយ) ក្រាម ។

៥- ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ៤ (បួន) ក្រាម រហូតដល់ក្រោម ២៥ (ម្ភៃប្រាំ)ក្រាម។

៦- អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ។

៧- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៨ (ប្រាំបី) គីឡូក្រាម រហូតដល់ក្រោម ២០ (ម្ភៃ) គីឡូក្រាម ។

៨- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ៨ (ប្រាំបី) គីឡូក្រាម រហូតដល់ក្រោម ៤០ (សែសិប) គីឡូក្រាម ។

៩- ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ៤០ (សែសិប) គីឡូក្រាម រហូតដល់ក្រោម ១៦០ (មួយរយ ហុកសិប) គីឡូក្រាម ។

១០- បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ១៥ (ដប់ប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ។

១១- សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុស្មើនឹងបរិមាណសុទ្ធសារធាតុញៀន ដែលបានកំណត់នៅក្នុងចំណុចណាមួយចាប់ពីចំណុចទី ៣ ដល់ចំណុចទី ១០ នៃកថាខណ្ឌនេះ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធចាប់ពី ៨០០ (ប្រាំបីរយ) ក្រាម រហូតដល់ក្រោម ១.៦០០ (មួយពាន់ប្រាំមួយរយ) ក្រាម ។

២- ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៤០០ (បួនរយ) ក្រាម រហូតដល់ក្រោម ៨០០ (ប្រាំបីរយ) ក្រាម ។

៣- ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធចាប់ពី ២៥ (ម្ភៃប្រាំ) ក្រាម រហូតដល់ក្រោម ៨០ (ប៉ែតសិប) ក្រាម ។

៤- អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ី មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រោម ២៤០ (ពីររយសែសិប) ក្រាម ។

៥- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ២០ (ម្ភៃ) គីឡូក្រាម រហូតដល់ក្រោម ៦០ (ហុកសិប) គីឡូក្រាម ។

៦- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ៤០ (សែសិប) គីឡូក្រាម រហូតដល់ក្រោម ១២០ (មួយរយម្ភៃ) គីឡូក្រាម ។

៧- ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ១៦០ (មួយរយហុកសិប) គីឡូក្រាម រហូតដល់ក្រោម ៤៨០ (បួនរយប៉ែតសិប) គីឡូក្រាម ។

៨- បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ៨០ (ប៉ែតសិប) ក្រាម រហូតដល់ក្រោម ២៤០ (ពីររយសែសិប) ក្រាម ។

៩- សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចទី ១ ដល់ចំណុចទី ៨ នៃកថាខណ្ឌនេះ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

១- ជ័រអាភៀន ជ័រកញ្ឆា ឬការកូកា មានបរិមាណសុទ្ធ ចាប់ពី ១.៦០០ (មួយពាន់ប្រាំមួយរយ) ក្រាម ឡើងទៅ ។

២- ប្រេងកញ្ឆាមានបរិមាណសុទ្ធចាប់ពី ៨០០ (ប្រាំបីរយ) ក្រាម ឡើងទៅ ។

៣- ម័រហ្វីន ហេរ៉ូអ៊ីន ឬកូកាអ៊ីនមានបរិមាណសុទ្ធ ចាប់ពី ៨០ (ប៉ែតសិប) ក្រាម ឡើងទៅ ។

៤- អំហ្វេតាមីន មេតំហ្វេតាមីន ឬអ៊ិចស្តាស៊ីមានបរិមាណសុទ្ធ ចាប់ពី ២៤០ (ពីររយសែសិប) ក្រាម ឡើងទៅ ។

៥- កញ្ឆាស្ងួត ឬស្លឹកកូកា មានបរិមាណចាប់ពី ៦០ (ហុកសិប) គីឡូក្រាម ឡើងទៅ ។

៦- ផ្លែអាភៀនស្រស់មានបរិមាណចាប់ពី ១២០ (មួយរយម្ភៃ) គីឡូក្រាម ឡើងទៅ ។

៧- ផ្លែអាភៀនស្ងួតមានបរិមាណចាប់ពី ៤៨០ (បួនរយប៉ែតសិប) គីឡូក្រាម ឡើងទៅ ។

៨- បណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ផ្សេងទៀត មានបរិមាណសុទ្ធចាប់ពី ២៤០ (ពីររយសែសិប) ក្រាម ឡើងទៅ។

៩- សារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុ ស្មើនឹងបរិមាណសុទ្ធសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចណាមួយ ចាប់ពីចំណុចទី ១ ដល់ចំណុចទី ៨ នៃកថាខណ្ឌនេះ ។

## មាត្រា ៤១.- បទរឹបយកសារធាតុញៀន

អំពើដោយចេតនាផ្លាស់ប្តូរដោយផ្ទុយច្បាប់នូវសារធាតុញៀន ដែលស្ថិតក្រោមការកាន់កាប់របស់អ្នកដទៃ មកដាក់ឲ្យស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន គឺជាអំពើរឹបយកសារធាតុញៀន ។

បទរឹបយកសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

ក្នុងករណីដែលការរឹបយកអាចកំណត់បានជាបទល្មើសផ្សេង ហើយបទល្មើសនេះត្រូវបានផ្តន្ទាទោសដែលអតិបរមានៃទោសដាក់ពន្ធនាគារ ធ្ងន់ជាងអតិបរមានៃទោសដាក់ពន្ធនាគារដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ ការរឹបយក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដូចបទល្មើសផ្សេងនោះ ។

**មាត្រា ៤២.- បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**

អំពើជួយដល់អ្នកដទៃឲ្យប្រើប្រាស់គ្រឿងញៀនតាមគ្រប់រូបភាព អំពើដឹកនាំ បែងចែក បញ្ជា ឬចែកចាយ ដើម្បីបញ្ចូលសារធាតុញៀនទៅក្នុងរាងកាយអ្នកដទៃ គឺជាអំពើចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ តាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារជនល្មើស អាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- ចំពោះមនុស្សច្រើននាក់ ។

៣- ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

៤- ចំពោះស្ត្រីដែលជនល្មើសដឹងថាមានគភ៌ ។

៥- បង្កឲ្យមានជំងឺប្រកបដោយគ្រោះថ្នាក់ដល់អ្នកដទៃ ។

៦- បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកដទៃ ។

៧- ចំពោះបុគ្គលដែលកំពុងទទួលវិធានការព្យាបាល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀលទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកដទៃច្រើននាក់ ។

២- បង្កឲ្យមានជំងឺប្រកបដោយគ្រោះថ្នាក់ដល់អ្នកដទៃច្រើននាក់ ។

៣- ចំពោះអនីតិជនដែលមានអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ ។

៤- បង្កឲ្យស្លាប់មនុស្ស ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសបណ្តាលឲ្យស្លាប់មនុស្សច្រើននាក់ ។

**មាត្រា ៤៣.- បទបង្ខំ អូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**

អំពើហិង្សា គំរាមកំហែងប្រើហិង្សា ឬសកម្មភាពផ្សេងទៀតដែលធ្វើឲ្យអ្នកដទៃស្ថិតនៅក្នុងភាពភ័យខ្លាច ហើយទទួលយកការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើបង្ខំអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

អំពើបញ្ចុះបញ្ចូល លួងលោម ញុះញង់ ឬប្រើឧបាយកលផ្សេងទៀត ធ្វើឲ្យអ្នកដទៃទទួលយកការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើអូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

បទបង្ខំ អូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។
២- ដោយមូលហេតុគំនុំ ឬព្យាបាទ ។
៣- ចំពោះមនុស្សច្រើននាក់ ។
៤- ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។
៥- ចំពោះស្ត្រីដែលជនល្មើសដឹងថាមានគភ៌ ។
៦- បង្កឲ្យមានជំងឺប្រកបដោយគ្រោះថ្នាក់ដល់អ្នកដទៃ ។
៧- បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកដទៃ ។
៨- ចំពោះបុគ្គលដែលកំពុងទទួលវិធានការព្យាបាល ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកដទៃច្រើននាក់ ។

២- បង្កឲ្យមានជំងឺប្រកបដោយគ្រោះថ្នាក់ដល់អ្នកដទៃច្រើននាក់ ។

៣- ចំពោះអនីតិជនដែលមានអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ ។

៤- បង្កឲ្យស្លាប់មនុស្ស ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសបណ្តាលឲ្យស្លាប់មនុស្សច្រើននាក់ ។

**មាត្រា ៤៤.- បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**

អំពើជួលទីកន្លែង ផ្តល់ទីកន្លែង ឬអំពើផ្សេងទៀតដែលបង្កលក្ខណៈងាយស្រួលដល់ការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ គឺជាបទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

២- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

៣- ចំពោះអនីតិជន ។

៤- ចំពោះមនុស្សច្រើននាក់ ។

៥- ចំពោះស្ត្រីដែលជនល្មើសដឹងថាមានគភ៌ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៤៥.- បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**

ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាងទី ២ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និង អាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ខាងលើនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្តដោយសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ១ និងតារាង ទី ២ មានបរិមាណតិចតួច និងប្រព្រឹត្តក្នុងក្របខ័ណ្ឌទទួលទានតាមទម្លាប់ ព្រះរាជអាជ្ញាអាចឲ្យជនប្រព្រឹត្តរួចខ្លួនពីបទចោទ ។ ប្រសិនបើរឿងនេះទៅដល់តុលាការ តុលាការអាចសម្រេចឲ្យចារីនៃហេតុការណ៍នេះមិនបាច់ទទួលទោស ឬគ្រាន់តែស្តីបន្ទោសជននោះតែប៉ុណ្ណោះ ។ ត្រូវចាត់ទុកថាជាការទទួលទានតាមទម្លាប់ ការទទួលទានដែលមិនបណ្តាលឲ្យញៀន ហើយអ្នកទទួលទានជាអ្នកស្រុកទទួលទានតាមដូនតាធ្លាប់ប្រព្រឹត្តជាយូរមកហើយ ។

## ផ្នែកទី ៣
## បទល្មើសទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ៣

**មាត្រា ៤៦.- បទដាំដោយខុសច្បាប់នូវរុក្ខជាតិញៀន**

ជនណាប្រព្រឹត្តដោយចេតនាល្មើសនឹងបទប្បញ្ញត្តិនៃច្បាប់នេះ និងបទបញ្ជាទាក់ទងនឹងការដាំរុក្ខជាតិញៀនដែលស្ថិតនៅក្នុងតារាងទី ៣ :

១- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣ (បី) ខែ ទៅ ១៨ (ដប់ប្រាំបី) ខែ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៦០០.០០០ (ប្រាំមួយសែន) រៀល ទៅ ៣.០០០.០០០ (បីលាន) រៀល ។

២- ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៨ (ដប់ប្រាំបី) ខែ ទៅ ៤ (បួន) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៣.០០០.០០០ (បីលាន) រៀល ទៅ ៨.០០០.០០០ (ប្រាំបី

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

លាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសនេះធ្វើឡើងក្នុងគោលបំណងចែកចាយ ផលិត ឬធ្វើពាណិជ្ជកម្ម ។

ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្តក្នុងគោលបំណងប្រើប្រាស់ផ្ទាល់ខ្លួន មានបរិមាណតិចតួច និងប្រព្រឹត្តក្នុងក្របខ័ណ្ឌទទួលទានតាមទម្លាប់ ព្រះរាជអាជ្ញាអាចឲ្យជនប្រព្រឹត្តរួចខ្លួនពីបទចោទ ។ ប្រសិនបើរឿងនេះទៅដល់តុលាការ តុលាការអាចសម្រេចឲ្យចារីនៃហេតុការណ៍នេះ មិនបាច់ទទួលទោស ឬគ្រាន់តែស្តីបន្ទោសជននោះតែប៉ុណ្ណោះ ។ ត្រូវចាត់ទុកថាជាការទទួលទានតាមទម្លាប់ ការទទួលទានដែលមិនបណ្តាលឲ្យញៀន ហើយអ្នកទទួលទានជាអ្នកស្រុកទទួលទានតាមដូនតាធ្លាប់ប្រព្រឹត្តជាយូរមកហើយ ។

## មាត្រា ៤៧.- បទផលិតដោយខុសច្បាប់នូវសារធាតុញៀន

ការចំរាញ់ ឬការញែកសារធាតុញៀនចេញពីរុក្ខជាតិ ការបន្សុទ្ធ ការបំប្លែង ការផ្សំ ឬសកម្មភាពតាមគ្រប់រូបភាពផ្សេងទៀតដោយខុសច្បាប់ ដើម្បីទទួលបាននូវគ្រឿងញៀន គឺជាអំពើផលិតដោយខុសច្បាប់នូវសារធាតុញៀន ។

បទផលិតដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

៣- បើការផលិតបណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ មានបរិមាណសុទ្ធចាប់ពី ១០០ (មួយរយ) ក្រាម រហូតដល់ក្រោម ៣០០(បីរយ) ក្រាម ។

៤- បើការផលិតសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចទី ៣ ខាងលើនេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បើការផលិតបណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ មានបរិមាណសុទ្ធចាប់ពី ៣០០ (បីរយ) ក្រាម ឡើងទៅ ។

២- បើការផលិតសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចទី ១ នៃកថាខណ្ឌនេះ ។

**មាត្រា ៤៨.- បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន**

ការកាន់កាប់ ការលាក់ទុក សន្និធិ និងសកម្មភាពប្រហាក់ប្រហែលផ្សេងទៀតដោយខុសច្បាប់ នូវសារធាតុញៀន គឺជាអំពើរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន ។

ការបញ្ជូនតាមគ្រប់រូបភាពដែលនាំឲ្យមានការផ្លាស់ទី ពីទីកន្លែងមួយទៅទីកន្លែងមួយទៀត ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ឬពីប្រទេសមួយទៅប្រទេសមួយទៀតដោយខុសច្បាប់នូវសារធាតុញៀន ជាអាទិ៍ តាមរយៈការផ្ញើ ការធ្វើចរាចរ ការនាំចូល ឬការនាំចេញ គឺជាអំពើដឹកជញ្ជូនដោយខុសច្បាប់នូវសារធាតុញៀន ។

ការផ្តល់សម្រាប់លក់ ការលក់ ការទិញដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ។

បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣- បើបណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ មានបរិមាណសុទ្ធចាប់ពី ១០០ (មួយរយ) ក្រាម រហូតដល់ក្រោម ៣០០ (បីរយ) ក្រាម ។

៤- បើសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចទី ៣ ខាងលើនេះ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើស ស្ថិតនៅក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បើបណ្តាសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ មានបរិមាណសុទ្ធចាប់ពី ៣០០ (បីរយ) ក្រាម ឡើងទៅ ។

២- បើសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ ចាប់ពីពីរប្រភេទឡើងទៅ ហើយមានបរិមាណសុទ្ធសរុបនៃសារធាតុទាំងនោះ ស្មើនឹងបរិមាណសុទ្ធនៃសារធាតុញៀនដែលបានកំណត់នៅក្នុងចំណុចទី ១ នៃកថាខណ្ឌនេះ ។

**មាត្រា ៤៩.- បទរឹបយកសារធាតុញៀន**

អំពើដោយចេតនាផ្លាស់ប្តូរដោយផ្ទុយនឹងច្បាប់នូវសារធាតុញៀន ដែលស្ថិតក្រោមការកាន់កាប់របស់អ្នកដទៃមកដាក់ឲ្យស្ថិតនៅក្រោមការកាន់កាប់របស់ខ្លួន គឺជាអំពើរឹបយកសារធាតុញៀន ។

បទរឹបយកសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀលទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្ត នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

ក្នុងករណីដែលការរឹបយកអាចកំណត់បានជាបទល្មើសផ្សេង ហើយបទល្មើសនេះត្រូវបានផ្តន្ទាទោស ដែលអតិបរមានៃទោសដាក់ពន្ធនាគារធ្ងន់ជាងអតិបរមានៃទោសដាក់ពន្ធនាគារដែលមានចែងក្នុងកថាខណ្ឌខាងលើនេះ ការរឹបយកត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដូចបទល្មើសផ្សេងនោះ ។



**មាត្រា ៥០.- បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**

អំពើជួយដល់អ្នកដទៃឲ្យប្រើប្រាស់គ្រឿងញៀនតាមគ្រប់រូបភាព អំពើដឹកនាំ បែងចែក បញ្ជា ឬចែកចាយ ដើម្បីបញ្ចូលសារធាតុញៀនទៅក្នុងរាងកាយអ្នកដទៃ គឺជាអំពើចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី ៣ តាមគ្រប់មធ្យោបាយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- ចំពោះមនុស្សច្រើននាក់ ។

៣- ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

៤- ចំពោះស្ត្រីដែលជនល្មើសដឹងថាមានគភ៌ ។

៥- បង្កឲ្យមានជំងឺប្រកបដោយគ្រោះថ្នាក់ដល់អ្នកដទៃ ។

៦- បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកដទៃ ។

៧- ចំពោះបុគ្គលដែលកំពុងទទួលវិធានការព្យាបាល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកដទៃច្រើននាក់ ។

២- បង្កឲ្យមានជំងឺប្រកបដោយគ្រោះថ្នាក់ដល់អ្នកដទៃច្រើននាក់ ។

៣- ចំពោះអនីតិជនដែលមានអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ ។

៤- បង្កឲ្យស្លាប់មនុស្ស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសបណ្តាលឲ្យស្លាប់មនុស្សច្រើននាក់ ។

**មាត្រា ៥១.- បទបង្ខំ អូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**

អំពើហិង្សា គំរាមកំហែងប្រើហិង្សា ឬសកម្មភាពផ្សេងទៀតដែលធ្វើឲ្យអ្នកដទៃស្ថិតនៅក្នុងភាពភ័យខ្លាច ហើយទទួលយកការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើបង្ខំអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

អំពើបញ្ចុះបញ្ចូល លួងលោម ញុះញង់ ឬប្រើឧបាយកលផ្សេងទៀត ធ្វើឲ្យអ្នកដទៃទទួលយកការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺជាអំពើអូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ។

បទបង្ខំ អូសទាញអ្នកដទៃ ឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- ដោយមូលហេតុគំនុំ ឬព្យាបាទ ។

៣- ចំពោះមនុស្សច្រើននាក់ ។

៤- ចំពោះអនីតិជនដែលមានអាយុចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំ ឡើងទៅ ។

៥- ចំពោះស្ត្រីដែលជនល្មើសដឹងថាមានគភ៌ ។

៦- បង្កឲ្យមានជំងឺប្រកបដោយគ្រោះថ្នាក់ដល់អ្នកដទៃ ។

៧-បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកដទៃ ។

៨-ចំពោះបុគ្គលដែលកំពុងទទួលវិធានការព្យាបាល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បង្កឲ្យមានការខូចខាតធ្ងន់ធ្ងរដល់សុខភាពរបស់អ្នកដទៃច្រើននាក់ ។

២- បង្កឲ្យមានជំងឺប្រកបដោយគ្រោះថ្នាក់ដល់អ្នកដទៃច្រើននាក់ ។

៣- ចំពោះអនីតិជនដែលមានអាយុក្រោម ១៥ (ដប់ប្រាំ) ឆ្នាំ ។

៤- បង្កឲ្យស្លាប់មនុស្ស ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសបណ្តាលឲ្យស្លាប់មនុស្សច្រើននាក់ ។

**មាត្រា ៥២.- បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន**

អំពើជួលទីកន្លែង ផ្តល់ទីកន្លែង ឬអំពើផ្សេងទៀតដែលបង្កលក្ខណៈងាយស្រួលដល់ការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ គឺជាបទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តនៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

២- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

៣- ចំពោះអនីតិជន ។

៤- ចំពោះមនុស្សច្រើននាក់ ។

៥-ចំពោះស្ត្រីដែលជនល្មើសដឹងថាមានគភ៌ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

### មាត្រា ៥៣.- បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន

ជនណាប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀនដែលស្ថិតនៅក្នុងតារាងទី ៣ តាមគ្រប់រូបភាព និងធ្លាប់ត្រូវបានទទួលរងនូវវិធានការព្យាបាលដោយបង្ខំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០ (មួយលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងអាចត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ការប៉ុនប៉ងប្រព្រឹត្តបទមជ្ឈិមដែលមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ខាងលើនេះ ត្រូវផ្តន្ទាទោសដូចគ្នានឹងបទមជ្ឈិមខាងលើដែរ ។

ប្រសិនបើបទល្មើសត្រូវបានប្រព្រឹត្តដោយសារធាតុញៀន ដែលស្ថិតនៅក្នុងតារាងទី ៣ មានបរិមាណតិចតួច និងប្រព្រឹត្តក្នុងក្របខ័ណ្ឌទទួលទានតាមទម្លាប់ ព្រះរាជអាជ្ញាអាចឲ្យជនប្រព្រឹត្តរួចខ្លួនពីបទចោទ ។ ប្រសិនបើរឿងនេះទៅដល់តុលាការ តុលាការអាចសម្រេចឲ្យចារីនៃហេតុការណ៍នេះមិនបាច់ទទួលទោស ឬគ្រាន់តែស្តីបន្ទោសជននោះតែប៉ុណ្ណោះ ។ ត្រូវចាត់ទុកថាជាការទទួលទានតាមទម្លាប់ ការទទួលទានដែលមិនបណ្តាលឲ្យញៀន ហើយអ្នកទទួលទានជាអ្នកស្រុកទទួលទានតាមដូនតាធ្លាប់ប្រព្រឹត្តជាយូរមកហើយ ។

## ផ្នែកទី ៤
## បទល្មើសទាក់ទងនឹងសារធាតុគីមីផ្សំក្នុងតារាងទី ៤

### មាត្រា ៥៤.- បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុគីមីផ្សំ

ជនណាផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរនូវសារធាតុគីមីផ្សំដែលស្ថិតនៅក្នុងតារាងទី ៤ ក្នុងគោលដៅយកទៅផលិតដោយខុសច្បាប់សារធាតុញៀន ឬដោយដឹងច្បាស់ថា សារធាតុគីមីផ្សំទាំងនោះនឹងត្រូវបានយកទៅប្រើប្រាស់សម្រាប់ផលិតដោយខុសច្បាប់នូវសារធាតុញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជនណាផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរនូវសារធាតុគីមីផ្សំដែលស្ថិតនៅក្នុងតារាងទី ៤ ក្នុងគោលដៅយកទៅផលិតដោយខុសច្បាប់សារធាតុញៀន ឬដោយដឹងច្បាស់ថា សារធាតុគីមីផ្សំទាំងនោះនឹងត្រូវបានយកទៅប្រើប្រាស់សម្រាប់ផលិតដោយខុសច្បាប់នូវសារធាតុញៀន ត្រូវផ្តន្ទាទោស :

១- ដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីណាមួយដូចខាងក្រោមនេះ :

- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង
- មានលក្ខណៈជាមុខរបរ
- នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ
- សារធាតុគីមីផ្សំមានបរិមាណសុទ្ធ ចាប់ពី ១ (មួយ) គីឡូក្រាម រហូតដល់ក្រោម ៥ (ប្រាំ) គីឡូក្រាម ។

២- ដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២០.០០០.០០០ (ម្ភៃលាន) រៀល ទៅ ៤០.០០០.០០០ (សែសិបលាន) រៀល បើសារធាតុគីមីផ្សំមានបរិមាណសុទ្ធ ចាប់ពី ៥ (ប្រាំ) គីឡូក្រាម រហូតដល់ក្រោម ១០(ដប់) គីឡូក្រាម ។

៣- ដាក់ពន្ធនាគារពី ២០ (ម្ភៃ) ឆ្នាំ ទៅ ៣០ (សាមសិប) ឆ្នាំ ឬអស់មួយជីវិត និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤០.០០០.០០០ (សែសិបលាន) រៀល ទៅ ១០០.០០០.០០០ (មួយរយលាន) រៀល បើសារធាតុគីមីផ្សំមានបរិមាណសុទ្ធ ចាប់ពី ១០ (ដប់) គីឡូក្រាម ឡើងទៅ ។

**មាត្រា ៥៥.- បទផ្តល់ឲ្យអនីតិជនហិត ស្រូបនូវសារធាតុគីមីផ្សំ ជាអាទិ៍**

ជនណាដែលផ្តល់ឲ្យអនីតិជននូវសារធាតុគីមីផ្សំ ឬសារធាតុផ្សេងទៀតដែលប៉ះពាល់ដល់ប្រព័ន្ធសរសៃប្រសាទ ដោយដឹងច្បាស់ថាអនីតិជននោះនឹងយកសារធាតុទាំងនោះទៅហិត ស្រូប ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- ចំពោះជនរងគ្រោះច្រើននាក់ ។

៣- បណ្តាលឲ្យមានជំងឺគ្រោះថ្នាក់ធ្ងន់ធ្ងរ ។

## ផ្នែកទី ៥
## បទល្មើសទាក់ទងនឹងបរិក្ខារ និងសម្ភារៈ

### មាត្រា ៥៦.- បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរបរិក្ខារឬសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការផលិត ឬការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន

ជនណាផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរបរិក្ខារ ឬសម្ភារៈក្នុងគោលដៅផលិត ឬប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ឬដោយដឹងច្បាស់ថាបរិក្ខារ ឬសម្ភារៈនោះ នឹងត្រូវបានយកទៅប្រើប្រាស់សម្រាប់ការផលិត ឬការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងករណីណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- មានលក្ខណៈជាមុខរបរ ។

៣- នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងឱកាសនៃការបំពេញមុខងារ ។

មិនមែនជាបទល្មើសទេ ក្នុងករណីដែលការផលិត ការរក្សាទុក ការដឹកជញ្ជូន ឬការជួញដូរបរិក្ខារ ឬសម្ភារៈសម្រាប់ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន មានគោលដៅបំរើដល់សេវាផ្នែកសុខភាពនានា និងសេវាកាត់បន្ថយគ្រោះថ្នាក់សម្រាប់អ្នកប្រើប្រាស់គ្រឿងញៀន និងមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ច ។

## ផ្នែកទី ៦
## បទល្មើសទាក់ទងនឹងការញុះញង់

### មាត្រា ៥៧.- បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស

អំពើញុះញង់ដោយផ្ទាល់ ឬដោយប្រយោល តាមមធ្យោបាយណាក៏ដោយ ឲ្យអ្នកដទៃប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងផ្នែកទី ២ ដល់ផ្នែកទី ៥ នៃជំពូកនេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

(ប្រាំមួយ) ខែ ទៅ ២ (ពីរ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល បើការញុះញង់មិនបានសម្រេចផល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បើការញុះញង់នេះបានប្រព្រឹត្តទៅលើអនីតិជន ។

## ផ្នែកទី ៧
## បទល្មើសផ្សេងទៀត

### មាត្រា ៥៨.- បទទទួលផលបទល្មើស

អំពើទទួលផលបទល្មើស គឺជាអំពើទទួល លាក់បំបាំង រក្សាទុក ឬបញ្ជូនវត្ថុអ្វីមួយដោយដឹងថា វត្ថុនោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនៃច្បាប់នេះ ។

ត្រូវចាត់ទុកជាអំពើទទួលផលបទល្មើសផងដែរ :

១- អំពើធ្វើជាអន្តរការី ដើម្បីបញ្ជូនវត្ថុអ្វីមួយ ដោយដឹងថា របស់នោះបានមកពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនៃច្បាប់នេះ ។

២- អំពើដែលបានទទួលផលពីផលនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមនៃច្បាប់នេះដោយដឹងហេតុការណ៍ច្បាស់ ។

អំពើទទួលផលបទល្មើស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

អំពើទទួលផលបទល្មើស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ទៅ ១០ (ដប់) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល បើការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- ដោយប្រើប្រាស់ភាពងាយស្រួលដែលការប្រកបសកម្មភាពវិជ្ជាជីវៈផ្តល់ឲ្យ ។

**មាត្រា ៥៩.- បទចូលរួមក្នុងក្រុមឧក្រិដ្ឋជន**

ក្រុមឧក្រិដ្ឋជន គឺជាក្រុមមនុស្សចាប់ពី ៣ (បី) នាក់ឡើងទៅ ដែលត្រូវបានបង្កើតឡើងដោយមានអង្គការចាត់តាំងជារចនាសម្ព័ន្ធ ទោះជាផ្លូវការ ឬមិនផ្លូវការក៏ដោយ ដើម្បីប្រព្រឹត្តបទល្មើសក្នុងច្បាប់នេះ ។

អំពើចូលរួមក្នុងក្រុមឧក្រិដ្ឋជន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦០.- ការផ្តន្ទាទោសចំពោះមេដឹកនាំក្រុមឧក្រិដ្ឋជន**

ក្នុងករណីដែលក្រុមឧក្រិដ្ឋជនបានប្រព្រឹត្តបទល្មើសដូចមានចែងចាប់ពីមាត្រា ៣៨ (បទដាំដោយខុសច្បាប់នូវរុក្ខជាតិញៀន) ដល់មាត្រា ៤២ (បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) ពីមាត្រា ៤៧ (បទផលិតដោយខុសច្បាប់នូវសារធាតុញៀន) ដល់មាត្រា ៥០ (បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៥៦ (បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរបរិក្ខារ ឬសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការផលិត ឬការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) និងមាត្រា ៧១ (បទសំអាតប្រាក់) នៃច្បាប់នេះ មេដឹកនាំក្រុមនេះត្រូវផ្តន្ទាទោសដូចខាងក្រោម :

១- ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសនោះតិចជាង ឬស្មើនឹង ១០ (ដប់) ឆ្នាំ អតិបរមានៃទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ត្រូវទ្វេឡើង ។

២- ប្រសិនបើអតិបរមានៃទោសដាក់ពន្ធនាគារចំពោះបទល្មើសមានរយៈពេលលើសពី ១០ (ដប់) ឆ្នាំ អតិបរមានៃទោស គឺដាក់ពន្ធនាគារអស់មួយជីវិត ។ ក្រៅពីទោសដាក់ពន្ធនាគារ ជនល្មើសនឹងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០០.០០០.០០០ (មួយរយលាន) រៀល ទៅ ៥០០.០០០.០០០(ប្រាំរយលាន) រៀល ។

**មាត្រា ៦១.- បទប្រឆាំងនឹងវិធានការផែកធេរសេរីវាង្គ**

អំពើប្រឆាំងនឹងវិធានការផែកធេរសេរីវាង្គដែលមានបញ្ញត្តនៅក្នុងមាត្រា ៧៦ (ការផែកធេរសេរីវាង្គដោយប្រើបច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រ) ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ ឬពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

**មាត្រា ៦២.- បទបំពានលើបទប្បញ្ញត្តិ ឬបទបញ្ជាស្តីពីការគ្រប់គ្រង ការប្រើប្រាស់ ឱសថដែលមានសារធាតុញៀន សារធាតុញៀន ឬសារធាតុគីមីផ្សំ**

ជនណាដែលមានភារកិច្ចទទួលខុសត្រូវក្នុងការគ្រប់គ្រង ត្រួតពិនិត្យ អធិការកិច្ច ការនាំចេញ ការនាំចូល ការដឹកជញ្ជូន ការលក់ ការទិញ ការរក្សាទុក ការបែងចែក ការចែកចាយ ការប្រើប្រាស់ ជាអាទិ៍ នូវឱសថដែលមានសារធាតុញៀន សារធាតុញៀន ឬសារធាតុគីមីផ្សំ បានបំពានលើបទប្បញ្ញត្តិ ឬបទបញ្ជាស្តីពីការគ្រប់គ្រង ការប្រើប្រាស់ឱសថ និងសារធាតុទាំងនោះ នៅក្នុងក្របខ័ណ្ឌនៃសកម្មភាពស្របច្បាប់ណាមួយដែលធ្វើឡើងក្នុងប្រយោជន៍វេជ្ជសាស្ត្រ ឱសថសាស្ត្រ ឬនគរបាលវិទ្យាសាស្ត្រ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល បើការប្រព្រឹត្តបទល្មើសស្ថិតក្នុងស្ថានភាពណាមួយដូចមានខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- បង្កឲ្យមានព្យសនកម្មធ្ងន់ធ្ងរ ។

**មាត្រា ៦៣.- បទបើកបរក្រោមឥទ្ធិពលនៃគ្រឿងញៀន**

បុគ្គលណាដែលបើកបរយានយន្តតាមផ្លូវគោក ផ្លូវទឹក ឬផ្លូវអាកាស នៅពេលដែលខ្លួនស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងញៀនដែលខ្លួនបានប្រើប្រាស់ដោយខុសច្បាប់ ទោះបីគ្មានសញ្ញាបង្ហាញឲ្យឃើញពីខាងក្រៅថាបានប្រើប្រាស់គ្រឿងញៀនក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០០.០០០(មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ប្រសិនបើឥទ្ធិពលនៃគ្រឿងញៀននេះបណ្តាលឲ្យប៉ះពាល់ដល់សុវត្ថិភាពនៃការបើកបរ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ២ (ពីរ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ៤.០០០.០០០ (បួនលាន) រៀល ក្នុងករណីដែលការបើកបរខាងលើនេះបង្កឲ្យមានរបួសដល់អ្នកដទៃ ហើយបណ្តាលឲ្យមានអសមត្ថភាពធ្វើការងារស្មើ ឬលើសពី ៨ (ប្រាំបី) ថ្ងៃ ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ក្នុងករណីដែលការបើកបរខាងលើនេះបង្កឲ្យមានរបួសដល់អ្នកដទៃ ហើយបណ្តាលឲ្យពិការអចិន្ត្រៃយ៍ ឬស្លាប់ ។

**មាត្រា ៦៤.- បទបំពានលើការសម្ងាត់នៃវិធានការតាមដាន**

ជនណាដែលបានដឹងដោយសារការប្រកបវិជ្ជាជីវៈរបស់ខ្លួន អំពីវិធានការណាមួយដែលមានបញ្ញត្តនៅក្នុងកថាខណ្ឌទី ១ មាត្រា ៨៥ (ការតាមដាន) នៃច្បាប់នេះ ហើយបានប្រាប់ដោយចេតនាដល់បុគ្គលដែលស្ថិតនៅក្រោមការអនុវត្តវិធានការទាំងនោះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០(ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

ជនណាដែលបានផ្តល់ទៅអាជ្ញាធរមានសមត្ថកិច្ចនូវឯកសារ ឬលិខិតដែលមានចែងក្នុងចំណុចទី ៤ កថាខណ្ឌទី ១ នៃមាត្រា ៨៥ (ការតាមដាន) នៃច្បាប់នេះ ដែលខ្លួនបានដឹងថាជាឯកសារក្លែងក្លាយ ឬឯកសារដែលមានការដកចេញខ្លះ ឬជាឯកសារកន្លែងច្រឡំ ប៉ុន្តែមិនបានជម្រាបអាជ្ញាធរទាំងនោះឲ្យបានដឹង ត្រូវផ្តន្ទាទោសដូចកថាខណ្ឌទី ១ ខាងលើនេះដែរ ។

**មាត្រា ៦៥.- បទរារាំងការធ្វើអធិការកិច្ច**

ជនណាដែលបង្កឧបសគ្គរារាំងដល់ការបំពេញមុខងាររបស់អធិការផ្នែកឱសថសាស្ត្រ ទោះដោយមធ្យោបាយណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ១.០០០.០០០(មួយលាន) រៀល ។

**មាត្រា ៦៦.- បទបំពានវិធានការបណ្តោះអាសន្នសម្រាប់ធានាការរឹបអូស**

អំពើបំផ្លិចបំផ្លាញ លាក់បំបាំង ឬកែបំបាត់វត្ថុ ឬទ្រព្យសម្បត្តិដែលត្រូវបានបង្កក ឬឃាត់ទុក ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៧.- បទមិនគោរពការរឹបអូស**

អំពើបំផ្លិចបំផ្លាញ លាក់បំបាំង ឬកែបំបាត់វត្ថុ ឬទ្រព្យសម្បត្តិរឹបអូស ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។

**មាត្រា ៦៨.- បទគេចវេះពីភាតព្វកិច្ចព្យាបាលដោយបង្ខំ**

ជនណាគេចវេះពីវិធានការព្យាបាលដោយបង្ខំដែលមានចែងក្នុងផ្នែកទី ៤ (ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ) ជំពូកទី ៦ (វិធានការព្យាបាលនិងស្តារនីតិសម្បទា) នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ១ (មួយ) ឆ្នាំ និងអាចទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០០.០០០ (មួយសែន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ។

## ផ្នែកទី ៨

## បទប្បញ្ញត្តិស្តីពីការសំអាតប្រាក់ទាក់ទងនឹងបទល្មើសគ្រឿងញៀន

**មាត្រា ៦៩.- បទប្បញ្ញត្តិទូទៅ**

បទប្បញ្ញត្តិនៃច្បាប់ស្តីពីការប្រឆាំងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះវិធានការប្រឆាំងការសំអាតប្រាក់ដែលបានមកពីបទល្មើសដូចមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៧០.- និយមន័យនៃការសំអាតប្រាក់**

ការបំប្លែង ការផ្ទេរ ការធ្វើលទ្ធកម្ម ការកាន់កាប់ ឬការប្រើប្រាស់ទ្រព្យសម្បត្តិ ការបិទបាំង ឬការក្លែងសភាវៈពិត ប្រភព ទីតាំង សិទ្ធិចាត់ចែង ចលនា កម្មសិទ្ធិ ឬសិទ្ធិលើទ្រព្យសម្បត្តិ ដោយដឹងថាទ្រព្យសម្បត្តិនេះជាផលនៃបទល្មើសដែលមានចែងចាប់ពីមាត្រា ៣៩ (បទផលិតដោយខុសច្បាប់នូវសារធាតុញៀន) ដល់មាត្រា ៤២ (បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) ពីមាត្រា ៤៧ (បទផលិតដោយខុសច្បាប់នូវសារធាតុញៀន) ដល់មាត្រា ៥០(បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៥៤ (បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុគីមីផ្សំ) និងមាត្រា ៥៦ (បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរ បរិក្ខារ ឬសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការផលិត ឬការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) នៃច្បាប់នេះ ក្នុងគោលបំណងបិទបាំង

ឬក្លែងប្រភពដើមមិនស្របច្បាប់នៃទ្រព្យសម្បត្តិទាំងនេះ ឬជួយបុគ្គលណាដែលបានពាក់ព័ន្ធក្នុងបទល្មើស ដើម្បីឲ្យបុគ្គលនោះគេចផុតពីផលវិបាកតាមផ្លូវច្បាប់នូវសកម្មភាពរបស់ខ្លួន គឺជាអំពើសំអាតប្រាក់ ។

ត្រូវចាត់ទុកជាអំពើសំអាតប្រាក់ផងដែរ អំពើជួយដល់ប្រតិបត្តិការនៃការបណ្តាក់ទុននៃការបិទបាំង ឬនៃការផ្លាស់ប្តូរផលដោយផ្ទាល់ ឬប្រយោលនៃបទល្មើសដូចមានយោងនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ៧១.- បទសំអាតប្រាក់**

ការសំអាតប្រាក់ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងអាចត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន) រៀល រហូតស្មើនឹងតម្លៃមូលនិធិ ឬតម្លៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសំអាតប្រាក់ ។

ក្នុងករណីបទល្មើសដែលជាប្រភពនៃទ្រព្យសម្បត្តិ ឬមូលនិធិដែលជាកម្មវត្ថុនៃការសំអាតប្រាក់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារធ្ងន់ជាងទោសដាក់ពន្ធនាគារដែលមានចែងនៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ ការសំអាតប្រាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារដូចបទល្មើសដែលចារីបានដឹង ហើយក្នុងករណីបទល្មើសមានភ្ជាប់មកជាមួយនូវស្ថានទម្ងន់ទោសច្រើននោះ ចារីត្រូវទទួលទណ្ឌកម្ម ដោយយោងទៅតាមស្ថានទម្ងន់ទោសដែលខ្លួនបានដឹងប៉ុណ្ណោះ ។

**មាត្រា ៧២.- ស្ថានទម្ងន់ទោស**

ការសំអាតប្រាក់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងត្រូវទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល រហូតស្មើនឹងតម្លៃមូលនិធិ ឬតម្លៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការសំអាតប្រាក់ ក្នុងករណីដែលការប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងស្ថានភាពណាមួយដូចខាងក្រោមនេះ :

១- បទល្មើសត្រូវបានប្រព្រឹត្តច្រើនដង ។

២- ដោយប្រើភាពងាយស្រួលដែលការប្រកបនូវសកម្មភាពវិជ្ជាជីវៈផ្តល់ឲ្យ ។

# ជំពូកទី ៥
# បទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ

## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ៧៣.- ការអនុវត្តបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ**

បទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត លើកលែងតែក្នុងករណីដែលមានចែងពិសេសផ្សេងនៅក្នុងជំពូកនេះ ។

**មាត្រា ៧៤.- ការចូលរួមក្នុងនីតិវិធី**

ក្នុងនីតិវិធីនៃការស៊ើបសួរ និងការជំនុំជម្រះ តុលាការត្រូវកោះហៅ និងស្តាប់ចម្លើយមន្ត្រីនគរបាល ឬភ្នាក់ងារនគរបាលយុត្តិធម៌ដែលបានចូលរួមក្នុងការស៊ើបអង្កេត និងស៊ើបសួរ ក្នុងឋានៈជាសាក្សី ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឬអ្នកតំណាងស្របច្បាប់ អាចធ្វើសំណើទៅព្រះរាជអាជ្ញា ដើម្បីធ្វើបណ្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ឬតុលាការ ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ឬអ្នកតំណាងស្របច្បាប់ ក៏អាចធ្វើសំណើទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឲ្យប្រើប្រាស់អំណាចរបស់ខ្លួនដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌដើម្បីធ្វើអធិបញ្ញា ឬប្តឹងឧទ្ធរណ៍ចំពោះសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ឬតុលាការ ។

## ផ្នែកទី ២
## វិធានការស៊ើបអង្កេត និងស៊ើបសួរ

**មាត្រា ៧៥.- ការឆែកឆេរនៅតាមព្រំដែន**

មន្ត្រីនគរបាលយុត្តិធម៌ ដែលមាននីតិសម្បទាពិនិត្យកត់ត្រាបទល្មើសដូចមានចែងក្នុងច្បាប់នេះ ត្រូវបានអនុញ្ញាតឲ្យឆែកឆេរនៅតាមព្រំដែន លើខ្លួនបុគ្គល យានជំនិះ សម្ភារៈ ជាអាទិ៍ កាលបើមានសញ្ញានាំឲ្យមានការសង្ស័យថា នៅលើខ្លួនបុគ្គល យានជំនិះ សម្ភារៈទាំងនោះមានផ្ទុកនូវសារធាតុញៀន ។

ការឆែកឆេរខ្លួនបុគ្គល ត្រូវធ្វើឡើងដោយបុគ្គលដែលមានភេទដូចគ្នា តាមបទបញ្ជាជាធរមាន ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៧៦.- ការឆែកឆេរសរីរាង្គដោយប្រើបច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រ**

កាលបើមានតម្រុយដែលអាចសន្និដ្ឋានថា ជនណាម្នាក់ឆ្លងព្រំដែនមាននាំមកនូវគ្រឿងញៀនលាក់ទុកក្នុងសរីរាង្គ មន្ត្រីនគរបាលយុត្តិធម៌ដែលមាននីតិសម្បទា អាចដាក់ជននោះឲ្យគ្រូពេទ្យ ឬអ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រពិនិត្យតាមដាន ជាអាទិ៍ ដោយប្រើបច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រ ក្រោយពីបានទទួលការយល់ព្រមជាលាយលក្ខណ៍អក្សរពីសាមីខ្លួន ។

ក្នុងករណីសាមីខ្លួនមិនយល់ព្រម មន្ត្រីនគរបាលយុត្តិធម៌នោះ ត្រូវប្តឹងសុំការអនុញ្ញាតពីព្រះរាជអាជ្ញាតាមគ្រប់មធ្យោបាយ ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវទទួលជាបឋមនូវការអនុញ្ញាតទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។ ព្រះរាជអាជ្ញាចាត់តាំងគ្រូពេទ្យ ឬអ្នកបច្ចេកទេសខាងវេជ្ជសាស្ត្រឲ្យធ្វើការពិនិត្យជាបន្ទាន់ ។ លទ្ធផលនៃការពិនិត្យដែលគ្រូពេទ្យផ្តល់កំណត់សម្គាល់របស់ជនពាក់ព័ន្ធ និងដំណើរការនៃការពិនិត្យ ត្រូវចុះក្នុងកំណត់ហេតុដែលត្រូវផ្ញើជូនទៅព្រះរាជអាជ្ញា ។

**មាត្រា ៧៧.- ការត្រួតពិនិត្យក្នុងសេវាប្រៃសណីយ៍**

មន្ត្រីនគរបាលយុត្តិធម៌ដែលមាននីតិសម្បទាពិនិត្យកត់ត្រាបទល្មើសទាំងឡាយ ដែលមានចែងក្នុងច្បាប់នេះ ត្រូវបានអនុញ្ញាតឲ្យតាមដានគ្រប់ពេលម៉ោង ទាំងថ្ងៃ ទាំងយប់ នូវសេវាប្រៃសណីយ៍ ដើម្បីរុករកការផ្ញើបញ្ញើខុសច្បាប់នូវគ្រឿងញៀន ។

កាលបើមានសញ្ញាធ្ងន់ធ្ងរនាំឲ្យសន្និដ្ឋានបានថាមានការផ្ញើបញ្ញើបែបនេះ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរដែលបានទទួលរឿងនេះ អាចបញ្ជាឲ្យមន្ទីរប្រៃសណីយ៍ស្រាយបើកកញ្ចប់ដែលផ្ញើបញ្ញើនោះបាន ទោះបីជាបញ្ជាដោយផ្ទាល់មាត់ក៏ដោយ ។

**មាត្រា ៧៨.- ការឃ្លាំមើលការឆ្លងកាត់**

ការឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជានូវគ្រឿងញៀន វត្ថុធាតុដើម ឧបករណ៍ដែលមានបច្ច័យដល់វត្ថុធាតុដើមដែលមានចែងក្នុងច្បាប់នេះ ដែលផ្ញើបញ្ញើដោយខុសច្បាប់ ឬសង្ស័យថាខុសច្បាប់ ហើយដែលអាជ្ញាធរដឹងឮ ហើយតាមដាន ដើម្បីពិនិត្យកត់ត្រាបទល្មើសទាំងឡាយដែលមានចែងចាប់ពីផ្នែកទី ២ (បទល្មើសទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ១ និងតារាងទី ២)ដល់ផ្នែកទី ៥ (បទល្មើសទាក់ទងនឹងបរិក្ខារ និងសម្ភារៈ) នៃជំពូកទី ៤ (បទប្បញ្ញត្តិព្រហ្មទណ្ឌ) នៃច្បាប់នេះ អាចអនុញ្ញាតឲ្យឆ្លងកាត់បាន ដើម្បីតាមដានរកអត្តសញ្ញាណជនទាំងឡាយដែលជាប់ពាក់ព័ន្ធក្នុងបទល្មើសនោះ សម្រាប់ការចោទប្រកាន់ ។

ត្រូវបានអនុញ្ញាតឲ្យធ្វើក្នុងគោលដៅដូចខាងលើនេះដែរនូវការញុះញង់ឲ្យលក់ដោយខុសច្បាប់នូវគ្រឿងញៀន ធ្វើឡើងដោយមន្ត្រីសាធារណៈ មានសមត្ថកិច្ចដើម្បីពិនិត្យកត់ត្រាបទល្មើស ទោះបីដោយផ្ទាល់ ឬតាមរយៈជនណាម្នាក់ដែលប្រព្រឹត្តតាមការណែនាំរបស់មន្ត្រីសាធារណៈនោះ ។

ការញុះញង់ឲ្យទិញដោយខុសច្បាប់នូវគ្រឿងញៀនដែលប្រព្រឹត្តដោយអ្នករាជការមានសមត្ថកិច្ចដើម្បីពិនិត្យកត់ត្រាបទល្មើសទាំងឡាយដែលមានចែងក្នុងច្បាប់នេះ ត្រូវហាមឃាត់ ។ ផ្ទុយទៅវិញ នឹងត្រូវចោទប្រកាន់ពីបទល្មើសញុះញង់ដែលមានចែងក្នុងមាត្រា ៥៧ (បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស) នៃច្បាប់នេះ និងទុកការអង្កេតជាមោឃៈ ទោះបីអ្នករាជការនោះប្រព្រឹត្តដោយផ្ទាល់ ឬតាមរយៈជនណាម្នាក់ក៏ដោយ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌលំអិតនៃការឃ្លាំមើលការឆ្លងកាត់ និងការញុះញង់ឲ្យលក់ដោយខុសច្បាប់នូវគ្រឿងញៀន ដូចមានកំណត់ក្នុងកថាខណ្ឌទី ១ និងទី ២ខាងលើនេះ នឹងត្រូវកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៧៩.- ការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់គ្រឿងញៀន**

ក្នុងករណីចាំបាច់ដើម្បីបម្រើឲ្យការស៊ើបអង្កេតបទល្មើសគ្រឿងញៀន មន្ត្រីមានសមត្ថកិច្ចតាមការចាត់តាំងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬរបស់មន្ត្រីប្រតិភូរបស់ក្រសួងយុត្តិធម៌អាចសម្រេចអនុញ្ញាតឲ្យប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ឬប្រើវិធីញុះញង់ឲ្យលក់ដោយខុសច្បាប់នូវគ្រឿងញៀន ។ ការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់គ្រឿងញៀននេះ អាចធ្វើឡើងដោយមន្ត្រីដែលមានសមត្ថកិច្ចដោយផ្ទាល់ ឬតាមរយៈជនណាម្នាក់ដែលអនុវត្តតាមបញ្ជារបស់មន្ត្រីមានសមត្ថកិច្ចនោះ ។

ការសម្រេចឲ្យប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ឬប្រើវិធីញុះញង់ឲ្យលក់ដោយខុសច្បាប់នូវគ្រឿងញៀន ត្រូវធ្វើសម្រាប់ករណីនីមួយៗ ហើយបើសិនជាត្រូវធ្វើជាលក្ខណៈអន្តរជាតិ គឺផ្អែកលើមូលដ្ឋាននៃកិច្ចព្រមព្រៀងជាមួយប្រទេសឯទៀតដែលមានប្រយោជន៍ក្នុងរឿងនេះ ។

សេចក្តីសម្រេចឲ្យប្រើវិធីប្រគល់ដោយមានការឃ្លាំមើល ត្រូវជូនដំណឹងភ្លាមទៅស្ថាប័នមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងបញ្ជូនចេញ ឬកន្លែងបញ្ជូនចូលមកលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ។ ម៉្យាងទៀត ត្រូវជូនដំណឹងភ្លាមផងដែរ ទៅស្ថាប័នមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងដែលប្រគល់ ឬកន្លែងបញ្ចេញ ។

សេចក្តីសម្រេចអនុញ្ញាតឲ្យប្រើវិធីញុះញង់ឲ្យលក់ ត្រូវជូនដំណឹងភ្លាមទៅតុលាការដែលមានសមត្ថកិច្ចនៃកន្លែងដែលសន្មតថាជាកន្លែងលក់ ។

បែបបទ នីតិវិធី និងលក្ខខណ្ឌនៃការដាក់ឲ្យប្រើប្រាស់វិធីប្រគល់ដោយមានការឃ្លាំមើល និងវិធីញុះញង់ឲ្យលក់គ្រឿងញៀនខាងលើនេះ នឹងត្រូវកំណត់នៅក្នុងប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

**មាត្រា ៨០.- ការត្រួតពិនិត្យប្រតិបត្តិការឃ្លាំមើល**

អាជ្ញាធរចាត់តាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬប្រតិភូរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដឹកនាំនិងត្រួតពិនិត្យកិច្ចប្រតិបត្តិការលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ហើយបញ្ជាឲ្យធ្វើអន្តរាគមន៍ក្នុងករណីដែលមន្ត្រីនោះយល់ឃើញថាជាការសមស្រប ។

ករណីមានការព្រមព្រៀងពីប្រទេសឯទៀតដែលមានផលប្រយោជន៍ពាក់ព័ន្ធ ឬដោយអនុលោមជាយថាហេតុទៅលើកិច្ចព្រមព្រៀងខាងហិរញ្ញវត្ថុ អាជ្ញាធរ ឬមន្ត្រីនោះ អាចសម្រេចឲ្យចាំស្កាត់ចាប់វត្ថុបញ្ជូនខុសច្បាប់ដែលអាចអនុញ្ញាតឲ្យបញ្ជូនបន្តដូចដើម ឬឲ្យបញ្ជូនបន្តក្រោយពីឃាត់ទុករូបិយវត្ថុ ឧបករណ៍ដែលមានបច្ច័យដល់រូបិយវត្ថុ គ្រឿងញៀន ហើយដាក់ផលិតផលផ្សេងជំនួសវិញ ។

**មាត្រា ៨១.- ការបិទស្លាក និងការថែរក្សាវត្ថុតាង**

បន្ថែមលើបទប្បញ្ញត្តិនៃមាត្រា ៩២ (ការបិទស្លាកបោះត្រាលើវត្ថុតាង) មាត្រា ១១៣(ការឆែកឆេរ) និងមាត្រា ១៦០ (ការបិទស្លាកបោះត្រាលើវត្ថុតាង) មាត្រា ១៨១(ការឆែកឆេរ និងការចាប់យកដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះវត្ថុតាងដែលសង្ស័យថាជាគ្រឿងញៀន ត្រូវរក្សាទុកក្នុងកញ្ចប់ ប្រអប់ ឬហឹប និងបិទស្លាកបោះត្រា ។

កញ្ចប់ ប្រអប់ ឬហឹបដែលមានបិទស្លាកបោះត្រា ត្រូវធ្វើយ៉ាងណាការពារឲ្យបាន ដើម្បីកុំឲ្យមានការលួចដកហូតយកវត្ថុតាងពីក្នុងនោះ ។

កញ្ចប់ ប្រអប់ ឬហឹបដែលមានបិទស្លាកបោះត្រានីមួយៗ ត្រូវដាក់លេខរៀង និងមានសរសេរពីលើសំបកកញ្ចប់ ប្រអប់ ឬហឹប ឬសរសេរលើស្លាកបោះត្រារាយសេចក្តីអំពី ប្រភេទ និងទម្ងន់វត្ថុដែលសង្ស័យថាជាគ្រឿងញៀន ព្រមទាំងចំនួនកញ្ចប់ដែលខ្ចប់វត្ថុនោះ ។

ក្រៅពីនិទ្ទេសដែលត្រូវចុះនៅក្នុងកំណត់ហេតុ ដូចមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ កំណត់ហេតុនេះ ត្រូវបន្ថែមនូវនិទ្ទេសដូចខាងក្រោម :

១- ថ្ងៃ ខែ ឆ្នាំនិងទីកន្លែងនៃការរកឃើញ ។

២- ប្រភេទ ទម្ងន់នៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀន ។

៣- វិធីថ្លឹងដែលបានធ្វើ ។

៤- បញ្ជាក់ពីការធ្វើតេស្ត និងលទ្ធផលនៃការធ្វើតេស្តនោះ ប្រសិនបើបានធ្វើ ។

កំណត់ហេតុ និងកំណត់សរសេរនៅលើកញ្ចប់ ប្រអប់ ឬហឹបនីមួយៗ ត្រូវចុះអត្តសញ្ញាណ និងហត្ថលេខា របស់បុគ្គលដែលបានចូលរួមរៀបចំធ្វើកញ្ចប់ ប្រអប់ ឬហឹបទាំងអស់នោះ ។

ការរក្សាទុកនូវកញ្ចប់ ប្រអប់ ឬហឹប នៅកន្លែងណាមួយ ការផ្លាស់ប្តូរទីកន្លែងនៃការរក្សាទុក ឬការប្រែប្រួលសភាពដើមនៃកញ្ចប់ ប្រអប់ ឬហឹប ត្រូវធ្វើកំណត់ហេតុ ។

## មាត្រា ៨២.- ការដកយកវត្ថុដែលសង្ស័យថាជាគ្រឿងញៀនសម្រាប់ធ្វើកោសលវិច័យ

ចៅក្រមដែលមានសមត្ថកិច្ច ត្រូវដកយកជាបន្ទាន់នូវសំណាកយ៉ាងតិច ៣ (បី) កញ្ចប់ ឬតាមចំនួនដែលត្រូវការជាចាំបាច់ នៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬជនពាក់ព័ន្ធក្នុងបទល្មើស ឬចំពោះមុខសាក្សី ២ (ពីរ) នាក់ ប្រសិនបើគ្មានអ្នកកាន់កាប់ទីកន្លែង ឬជនពាក់ព័ន្ធក្នុងបទល្មើស ដើម្បីធ្វើជាភស្តុតាង និងជាការកត់សម្គាល់ភិនភាគនៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀនដែលបានចាប់យក ។

សំណាកនីមួយៗ ត្រូវដាក់ក្នុងកញ្ចប់បិទស្លាកបោះត្រាជាសម្គាល់ ។ នៅលើកញ្ចប់និងស្លាក ត្រូវកត់ចំណាំប្រភេទ ទម្ងន់នៃវត្ថុដែលនៅខាងក្នុង ។

បន្ទាប់ពីការដកសំណាកហើយ ត្រូវបិទស្លាកបោះត្រាឡើងវិញលើកញ្ចប់ដើម និងត្រូវធ្វើកំណត់ហេតុមួយបញ្ជាក់អំពីចំនួនសំណាកដែលបានដកយក ប្រភេទ និងទម្ងន់នៃវត្ថុដែលសង្ស័យថាជាគ្រឿងញៀនដែលមាននៅក្នុងកញ្ចប់នីមួយៗ ព្រមទាំងការផ្លាស់ប្តូរទៅលើស្លាកនិងត្រាដើម ។

កំណត់ហេតុ និងការសរសេរបញ្ជាក់ទាំងអស់លើសំណាកនីមួយៗ និងការបិទស្លាកបោះត្រាដែលបានធ្វើឡើងវិញ ត្រូវចុះអត្តសញ្ញាណនិងហត្ថលេខារបស់បុគ្គលដែលបានចូលរួមក្នុងកិច្ចប្រតិបត្តិការដកសំណាកនោះ ។

## មាត្រា ៨៣.- កោសលវិច័យតាមបច្ចេកទេសវិទ្យាសាស្ត្រ

កោសលវិច័យតាមបច្ចេកទេសវិទ្យាសាស្ត្រដោយអ្នកជំនាញ ដែលទទួលស្គាល់ដោយក្រសួងយុត្តិធម៌ ដើម្បីឲ្យបានដឹងអំពីប្រភេទជាតុផ្សំ និងកម្រិតជាតុសកម្មរបស់គ្រឿងញៀនដែលបានដកយក ត្រូវធ្វើដោយឆាប់បំផុតបន្ទាប់ពីការដកយក ដើម្បីចៀសវាងការខូចខាតថយចុះនូវសារជាតុ រូបវត្ថុ និងជាតិគីមីនៃវត្ថុនោះ។ អ្នកជំនាញត្រូវបញ្ជាក់ក្នុងរបាយការណ៍របស់ខ្លួននូវចំនួនសំណាកដែលគេបានប្រគល់ឲ្យ អំពីប្រភេទនិងទម្ងន់នៃគ្រឿងញៀនដែលមាននៅក្នុងសំណាកនីមួយៗ ចំនួនសំណាកដែលបានប្រើប្រាស់ធ្វើកោសលវិច័យ ហើយប្រសិនបើមាន ត្រូវបញ្ជាក់ចំនួនសំណាកដែលបានប្រមូលមកវិញសល់ពីការធ្វើកោសលវិច័យ និងការប្រែប្រួលទៅលើសំណាកទាំងនោះ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៨៤.- ការប្រគល់ ការបំផ្លាញចោលនូវគ្រឿងញៀនដែលបានចាប់យក**

ក្រោយពីបានចាប់យក និងក្រោយពីបានដកយកសំណាកក្នុងបរិមាណគ្រប់គ្រាន់ដើម្បីរក្សាទុកសម្រាប់ដំណើរការនីតិវិធី គ្រឿងញៀនទាំងនោះត្រូវរឹបអូសជាបន្ទាន់ និងត្រូវបានចាត់ចែងដូចខាងក្រោម :

១- ប្រគល់ឱសថដែលមានសារធាតុញៀនដែលអាចប្រើប្រាស់បានឲ្យទៅក្រសួងសុខាភិបាល ។

២- ប្រគល់គ្រឿងញៀនដែលអាចប្រើប្រាស់ក្នុងឧស្សាហកម្មឱសថ ឬប្រើប្រាស់ក្នុងវិស័យផ្សេងទៀតឲ្យទៅក្រសួងសុខាភិបាល ឬក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល តាមមុខងារប្រើប្រាស់នៃគ្រឿងញៀននោះ ។

៣- បំផ្លាញចោលនូវគ្រឿងញៀនដែលគ្មានប្រយោជន៍ក្នុងការប្រើប្រាស់ ។ ការបំផ្លាញចោលទាំងស្រុងនូវគ្រឿងញៀន ត្រូវធ្វើឲ្យបានឆាប់រហ័ស និងតាមមធ្យោបាយសមស្របបំផុត នៅចំពោះមុខគណៈកម្មការដែលត្រូវបង្កើតឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

ការរឹបអូសដើម្បីប្រគល់ ឬបំផ្លាញចោល ជាសមត្ថកិច្ចរបស់ :

១- ព្រះរាជអាជ្ញា នៅក្នុងដំណាក់កាលស៊ើបអង្កេត ។

២- យុត្តាធិការស៊ើបសួរ នៅក្នុងដំណាក់កាលស៊ើបសួរ ។

៣- យុត្តាធិការជំនុំជម្រះ នៅក្នុងដំណាក់កាលជំនុំជម្រះ ។

កាលណាការស៊ើបសួរត្រូវបានបញ្ចប់ដោយសេចក្តីសម្រេចលើកលែងចោទប្រកាន់ជាស្ថាពរ ឬយុត្តាធិការជំនុំជម្រះបានចេញសេចក្តីសម្រេចជាស្ថាពរ ហើយពុំបានសម្រេចសេចក្តីលើការរឹបអូសដើម្បីប្រគល់ឬបំផ្លាញចោលទេ នោះព្រះរាជអាជ្ញា ឬអគ្គព្រះរាជអាជ្ញាមានសមត្ថកិច្ច សម្រេចតាមករណីនីមួយៗ ។

**មាត្រា ៨៥.- ការតាមដាន**

ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរដែលទទួលបាននូវរឿងក្តីដែលជាបទល្មើស តាមបញ្ញត្តិនៃច្បាប់នេះ អាចអនុញ្ញាតឲ្យអាជ្ញាធរមានសមត្ថកិច្ច :

- ពិនិត្យដាក់ឲ្យស្ថិតនៅក្រោមការឃ្លាំមើលគណនីធនាគារ ឬគណនីឯទៀតដែលចាត់ទុកដូចជាគណនីធនាគារ ឬ

- តម្រូវឲ្យមានការត្រួតពិនិត្យ និងបង្គាប់ឲ្យផ្តល់ ឬថតចម្លងលិខិតយថាភូត ឬលិខិតឯកជន បង្កាន់ដៃធនាគារ ហិរញ្ញវត្ថុ និងពាណិជ្ជកម្មទាំងអស់ ឬ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

-បង្គាប់ឲ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ ដូចជាសារតាមទូរសារ ឬសារតាមអិនធើណែត ជាអាទិ៍ ឬ

-ចូលទៅពិនិត្យប្រព័ន្ធកុំព្យូទ័រ

ប្រសិនបើមានសញ្ញាធ្ងន់ធ្ងរល្មមសមឲ្យឃើញថា គណនី មធ្យោបាយទូរគមនាគមន៍ ប្រព័ន្ធកុំព្យូទ័រទាំងនោះកំពុងត្រូវបានប្រើប្រាស់ដោយបណ្តាជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្ត ឬមានផែនការប្រព្រឹត្តបទល្មើសណាមួយ ឬកាលបើលិខិត ឬឯកសារទាំងនោះពាក់ព័ន្ធ ឬអាចពាក់ព័ន្ធនឹងបទល្មើសណាមួយដែលមានបញ្ញត្តនៅក្នុងច្បាប់នេះ ។

វិធានការខាងលើនេះ មិនអាចចាត់ទុកជាការរំលោភលើការសម្ងាត់វិជ្ជាជីវៈឡើយ ។

ការបង្គាប់ឲ្យចាប់និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ អាចអនុញ្ញាតឲ្យបានតែក្នុងថិរវេលា ២ (ពីរ) ខែ ។ ការបន្តវិធានការ និងថិរវេលានេះ ត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរដែលកាន់សំណុំរឿងនោះតែប៉ុណ្ណោះ ។

**មាត្រា ៨៦.- ការសម្ងាត់ធនាគារ**

ការសម្ងាត់វិជ្ជាជីវៈធនាគារពុំមែនជាយុត្តិកម្មសម្រាប់បដិសេធមិនផ្តល់ភស្តុតាង ពាក់ព័ន្ធនឹងបទល្មើសដែលបានបញ្ញត្តនៅក្នុងច្បាប់នេះឡើយ ។

**មាត្រា ៨៧.- ការបិទគ្រឹះស្ថាន ការហាមឃាត់អាជីវកម្មលើគ្រឹះស្ថានជាបណ្តោះអាសន្ន**

ក្នុងករណីមានការចោទប្រកាន់ពីបទល្មើសណាមួយដែលមានចែងនៅក្នុងមាត្រា ៣៩ (បទផលិតដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៤០ (បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៤២ (បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) ដល់ មាត្រា ៤៤ (បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា៤៧ (បទផលិតដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៤៨ (បទរក្សាទុកដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៥០ (បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) ដល់ មាត្រា ៥២ (បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៥៤ (បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុគីមីផ្សំ) និងមាត្រា ៥៦ (បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរបរិក្ខារ ឬសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការផលិត ឬការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) នៃច្បាប់នេះ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ចៅក្រមស៊ើបសួរ អាចហាមឃាត់ចំពោះការធ្វើសកម្មភាពនៅក្នុងគ្រឹះស្ថានដែលនៅក្នុងឱកាសនៃការធ្វើសកម្មភាពនោះ បទល្មើសត្រូវបានប្រព្រឹត្តឡើង ឬហាមឃាត់ចំពោះការធ្វើអាជីវកម្មលើគ្រឹះស្ថានដែលបើកចំហសម្រាប់សាធារណជន ឬដែលត្រូវប្រើប្រាស់ដោយសាធារណជនប្រសិនបើម្ចាស់គ្រឹះស្ថាន ឬអ្នកធ្វើអាជីវកម្មលើគ្រឹះស្ថាន បានចូលរួមក្នុងការប្រព្រឹត្តបទល្មើសខាងលើនេះ ។

ការបិទគ្រឹះស្ថាន ការហាមឃាត់អាជីវកម្មលើគ្រឹះស្ថានជាបណ្តោះអាសន្ន អាចធ្វើឡើងសម្រាប់រយៈពេល ៦ (ប្រាំមួយ) ខែ យ៉ាងច្រើន ។

សេចក្តីសម្រេចនេះត្រូវយកទៅអនុវត្តភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

## ផ្នែកទី ៣
## វិធានការបណ្តោះអាសន្នសម្រាប់ធានាការរឹបអូស

### មាត្រា ៨៨.- វិធានការបន្ទាន់សម្រាប់ធានាការរឹបអូស

ក្នុងករណីមានការស៊ើបអង្កេត ចោទប្រកាន់ ស៊ើបសួរអំពីបទល្មើសណាមួយដែលមានចែងនៅក្នុងច្បាប់នេះ វិធានការឃាត់ទុក បង្កកទ្រព្យសម្បត្តិដែលជារបស់ជនសង្ស័យ ឬជនត្រូវចោទ ដែលជាផលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថាបានប្រើប្រាស់ ឬបម្រុងទុកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃផ្នែកនេះ ។

### មាត្រា ៨៩.- ការឃាត់ទុកទ្រព្យសម្បត្តិ

ព្រះរាជអាជ្ញាត្រូវឃាត់ទុកទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថាបានប្រើប្រាស់ ឬបម្រុងទុកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ហើយប្តឹងសុំជាបន្ទាន់ទៅចៅក្រមស៊ើបសួរ ឬតុលាការ ដោយយោងតាមករណីនៃការចោទប្រកាន់ ដើម្បីបង្កកទ្រព្យសម្បត្តិទាំងនោះ ។

### មាត្រា ៩០.- ការបង្កកទ្រព្យសម្បត្តិ

ចៅក្រមស៊ើបសួរ ឬតុលាការអាចបញ្ជាដោយឯកឯង ឬតាមបណ្តឹងសុំរបស់ព្រះរាជអាជ្ញាឲ្យបង្កកទ្រព្យសម្បត្តិ ប្រសិនបើពិនិត្យឃើញថា មានមូលហេតុសមហេតុផល និង សង្ស័យថាទ្រព្យនោះជាផលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថាបានប្រើប្រាស់ ឬបម្រុងទុកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ។

### មាត្រា ៩១.- ទ្រព្យបញ្ចូលគ្នា

នៅពេលណាដែលទ្រព្យដែលជាផលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យដោយសមហេតុផលថាជាផលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថាបានប្រើប្រាស់ ឬបម្រុងទុកប្រើប្រាស់ក្នុងការ

ប្រព្រឹត្តបទល្មើសត្រូវបានដាក់បញ្ចូលជាមួយទ្រព្យដទៃទៀតនោះ តម្លៃនៃទ្រព្យដែលត្រូវឃាត់ទុកតាមបញ្ញត្តិមាត្រា ៨៩ (ការឃាត់ទុកទ្រព្យសម្បត្តិ) ឬបង្កកតាមបញ្ញត្តិនៃមាត្រា ៩០ (ការបង្កកទ្រព្យសម្បត្តិ) ខាងលើនេះ មិនត្រូវលើសពីតម្លៃនៃទ្រព្យដែលជាផលកើតចេញពីបទល្មើស ឬត្រូវបានសង្ស័យថាបានប្រើប្រាស់ ឬបម្រុងទុកប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើសឡើយ ។

**មាត្រា ៩២.- បន្ទុករបស់ជនប្រឆាំងនឹងសេចក្តីសម្រេច**

ជនដែលសុំដកទ្រព្យដែលត្រូវបានសម្រេចឲ្យឃាត់ទុកតាមបញ្ញត្តិនៃមាត្រា ៨៩ (ការឃាត់ទុកទ្រព្យសម្បត្តិ) ឬបង្កកតាមបញ្ញត្តិនៃមាត្រា ៩០ (ការបង្កកទ្រព្យសម្បត្តិ) នៃច្បាប់នេះ ត្រូវទទួលបន្ទុកបង្ហាញភស្តុតាងពីភាពត្រឹមត្រូវនៃទ្រព្យសម្បត្តិដែលបានឃាត់ទុក ឬបង្កកនោះ ទៅចៅក្រមដែលទទួលបន្ទុករឿងក្តី ។

ជនដែលបដិសេធសេចក្តីសម្រេចបង្កកទ្រព្យសម្បត្តិដោយចៅក្រមស៊ើបសួរតាមបញ្ញត្តិនៃមាត្រា ៩០ (ការបង្កកទ្រព្យសម្បត្តិ) នៃច្បាប់នេះ អាចប្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចនោះ ទៅសភាស៊ើបសួរបាន ។

## ផ្នែកទី ៤
## វិធានការរឹបអូស

**មាត្រា ៩៣.- ការរឹបអូសជាច់ខាត**

គ្រឿងញៀនដែលចាប់យក ហើយដែលមិនទាន់បានបំផ្លាញចោល ឬមិនទាន់បានប្រគល់ទៅឲ្យស្ថាប័នមានសមត្ថកិច្ច ត្រូវរឹបអូសជាច់ខាត ទោះបីបទល្មើសមិនត្រូវបានចោទប្រកាន់ លើកលែងការចោទប្រកាន់ ឬសម្រេចរួចផុតពីបទចោទប្រកាន់ ឬផ្តន្ទាទោសក៏ដោយ ។

បទប្បញ្ញត្តិស្តីពីការប្រគល់វត្ថុដែលចាប់យកដូចមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត យោងតាមដំណាក់កាលនៃនីតិវិធី ។

**មាត្រា ៩៤.- ការរឹបអូសវត្ថុ ជាអាទិ៍**

ក្នុងករណីផ្តន្ទាទោសចំពោះបទល្មើសណាមួយដែលមានចែងក្នុងច្បាប់នេះ តុលាការត្រូវសម្រេច :

១- រឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុផ្សេងទៀតដែលបានប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ។

២- រឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៣- រឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

ក្រៅពីករណីដែលមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើមានភស្តុតាងបញ្ជាក់អំពីពិរុទ្ធភាពរបស់ជនជាប់ចោទដែលទទួលមរណភាពនៅក្នុងដំណាក់កាលនៃនីតិវិធីជំនុំជម្រះថា ជននោះបានប្រព្រឹត្តបទល្មើសណាមួយដែលមានចែងចាប់ពីមាត្រា ៣៩ (បទផលិតដោយខុសច្បាប់នូវសារធាតុញៀន) ដល់មាត្រា ៤២ (បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) ពីមាត្រា ៤៧ (បទផលិតដោយខុសច្បាប់នូវសារធាតុញៀន) ដល់មាត្រា ៥០ (បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៥៤ (បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុគីមីផ្សំ) មាត្រា ៥៦ (បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរបរិក្ខារ ឬសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការផលិត ឬការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) មាត្រា ៧១ (បទសំអាតប្រាក់) និងមាត្រា ៧២ (ស្ថានទម្ងន់ទោស) នៃច្បាប់នេះ តុលាការត្រូវរឹបអូសមត៌កដែលបន្សល់ពីជនជាប់ចោទ ទោះបីបានបែងចែក ឬមិនទាន់បានបែងចែកក្តីក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីថ្ងៃដែលជនជាប់ចោទទទួលមរណភាព ប្រសិនបើមានភាពច្បាស់លាស់ ឬសង្ស័យដោយសមហេតុផលថាមត៌កទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។

ប៉ុន្តែការរឹបអូសមិនអាចប្រកាសបានទេ ប្រសិនបើមានការប៉ះពាល់ដល់តតិយជន។

## មាត្រា ៩៥.- បន្ទុករបស់ជនប្រឆាំងនឹងសេចក្តីសម្រេចរឹបអូស

តតិយជនដែលមានផលប្រយោជន៍ពាក់ព័ន្ធនឹងសេចក្តីសម្រេចតាមបញ្ញត្តិមាត្រា ៩៤ (ការរឹបអូសវត្ថុ ជាអាទិ៍) ខាងលើនេះ មានសិទ្ធិប្តឹងឧបាស្រ័យ តាមបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះសេចក្តីសម្រេចរឹបអូសនេះ ហើយត្រូវទទួលបន្ទុកបង្ហាញភស្តុតាងអំពីភាពត្រឹមត្រូវនៃទ្រព្យ ជាអាទិ៍ដែលត្រូវបានរឹបអូស ។

## មាត្រា ៩៦.- ការរឹបអូសទ្រព្យសម្បត្តិ ជាអាទិ៍

ក្នុងករណីដែលការចោទប្រកាន់មិនអាចធ្វើបាន ដោយមូលហេតុមរណភាពនៃជនល្មើស ព្រះរាជអាជ្ញា អាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌដើម្បីរឹបអូស ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។

ក្នុងករណីមានការលើកលែងចោទប្រកាន់ដោយមូលហេតុមរណភាពនៃជនត្រូវចោទ ឬអត្តសញ្ញាណរបស់ជននោះមិនត្រូវបានដឹង ចៅក្រមស៊ើបសួរអាចប្តឹងសុំទៅតុលាការព្រហ្មទណ្ឌដើម្បីរឹបអូស

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិ ប្រសិនបើមានការសង្ស័យដោយសមហេតុផលថា ឧបករណ៍ សម្ភារៈ មូលនិធិ ផលទុន ឬទ្រព្យសម្បត្តិទាំងនោះពាក់ព័ន្ធនឹងបទល្មើស ។

ប៉ុន្តែការរឹបអូសមិនអាចសម្រេចបានទេ ប្រសិនបើមានការប៉ះពាល់ដល់តតិយជន ។ តតិយជនដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃកម្មវត្ថុនៃការរឹបអូស មានសិទ្ធិចូលរួមក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីតុលាការ និងមានសិទ្ធិប្តឹងឧបាស្រ័យប្រឆាំងនឹងសេចក្តីសម្រេចនោះបាន ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ៩៧.- ការលក់ដោយរដ្ឋនូវវត្ថុ ឬទ្រព្យសម្បត្តិរឹបអូស**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវចាត់ចែងនូវវត្ថុ ឬទ្រព្យសម្បត្តិដែលបានរឹបអូស ។ ក្នុងករណីដែលមានការលក់វត្ថុ ឬទ្រព្យសម្បត្តិដែលរឹបអូសត្រូវអនុលោមតាមនីតិវិធីស្តីពីការលក់ទ្រព្យសម្បត្តិរដ្ឋ ។

ប្រាក់ដែលបានមកពីការលក់តាមបញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើ រួមជាមួយនឹងទ្រព្យរឹបអូសដទៃទៀត ដែលជាសាច់ប្រាក់ត្រូវបង់ចូលមូលនិធិជាតិមួយដែលនឹងត្រូវបានប្រើប្រាស់ :

- ដើម្បីទូទាត់បំណុល និងចំណាយស្របច្បាប់ទាំងអស់ដែលកើតឡើងពីការរឹបអូសទ្រព្យ រាប់បញ្ចូលទាំងការចំណាយលើការរឹបអូស ការដឹកជញ្ជូន ការទុកដាក់ និងការថែរក្សា និង
- ដើម្បីសងសំណងដល់ជនរងគ្រោះ ប្រសិនបើមាន ឬ
- ដាក់ចូលទៅក្នុងបេឡាមូលនិធិរបស់អាជ្ញាធរជាតិសម្រាប់ការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន។

អាជ្ញាធរជាតិនេះចាត់ចែងមូលនិធិក្នុងបេឡាផ្តល់ឲ្យអង្គការរដ្ឋ ឬឲ្យទៅសមាគមឯកជនដែលមានការធានាខាងមុខជំនាញប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់ ឬប្រយុទ្ធប្រឆាំងជាមួយបទល្មើសគ្រឿង ញៀន ។

លក្ខខណ្ឌនៃការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិខាងលើនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៩៨.- បណ្តឹងចំពោះសេចក្តីសម្រេចស្ថាពរទាក់ទងនឹងការរឹបអូសទ្រព្យសម្បត្តិជាអាទិ៍**

តតិយជនដែលមានប្រយោជន៍ពាក់ព័ន្ធ ឬដែលអះអាងថាខ្លួនជាម្ចាស់នៃកម្មវត្ថុនៃការរឹបអូស មានសិទ្ធិប្តឹងទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារនូវទ្រព្យសម្បត្តិ ជាអាទិ៍ ដែលត្រូវបានរឹបអូសដោយសេចក្តីសម្រេចស្ថាពររបស់តុលាការព្រហ្មទណ្ឌ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

សិទ្ធិប្តឹងទាមទារដែលបានចែងក្នុងកថាខណ្ឌទី ១ ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៣ (បី) ឆ្នាំបានកន្លងហួស បន្ទាប់ពីតតិយជន ឬអ្នកតំណាងដែលច្បាប់បានកំណត់របស់ជននេះបានដឹង ។

ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី ២ ខាងលើ ក៏ដោយ ប្រសិនបើហួសអំឡុងពេល ១០ (ដប់) ឆ្នាំ ចាប់តាំងពីសេចក្តីសម្រេចរបស់តុលាការព្រហ្មទណ្ឌបានចូលជាស្ថាពរ នោះសិទ្ធិទាមទារត្រូវរលត់ ។

**មាត្រា ៩៩.- ការទុកជាមោឃៈនូវអំពើនានាដែលប៉ុនប៉ងបង្កើតឧបសគ្គដល់ការបង្អក ឬការរឹបអូស**

តុលាការត្រូវទុកជាមោឃៈ ឬបដិសេធគ្រប់សកម្មភាពទាំងឡាយ ទោះបីជាបង់កម្រៃ ឬមិនបង់កម្រៃក្តី ដែលធ្វើឡើងក្នុងគោលបំណងបង្វែរទ្រព្យទាំងឡាយឲ្យផុតពីវិធានការបង្អក ឬរឹបអូស ។

បុគ្គលដែលទទួលបានទ្រព្យដោយសារអានុភាពនៃសកម្មភាពដោយមិនបង់កម្រៃ ត្រូវបាត់បង់សិទ្ធិដោយសារការទុកជាមោឃៈ ឬការបដិសេធសកម្មភាពទាំងនោះ ។ ប៉ុន្តែបុគ្គលដែលទទួលបានទ្រព្យដោយសុចរិត ត្រូវមានករណីយកិច្ចសងត្រឹមកម្រិតផលប្រយោជន៍ដែលខ្លួននៅតែទទួលតែប៉ុណ្ណោះ ។

ការទុកជាមោឃៈ ឬការបដិសេធក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចធ្វើបានទេ ប្រសិនបើបុគ្គលដែលទទួលបានទ្រព្យដោយសារអានុភាពនៃសកម្មភាពនោះ សុចរិតហើយបានបង់កម្រៃ ។

## ជំពូកទី ៦
## វិធានការព្យាបាល និងស្តារនីតិសម្បទា

### ផ្នែកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១០០.- ភារកិច្ចរបស់រដ្ឋក្នុងការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា**

រដ្ឋត្រូវប្រើប្រាស់គ្រប់យន្តការ ដើម្បីគាំទ្រដល់ការផ្តល់សេវាសមស្របក្នុងការព្យាបាលផ្នែកវេជ្ជសាស្ត្រ និងការស្តារនីតិសម្បទាចំពោះអ្នកញៀនគ្រឿងញៀនគ្រប់រូប ដោយមិនមានការរើសអើង ។

រដ្ឋត្រូវជានាផងដែរឲ្យមានសេវាកាត់បន្ថយគ្រោះថ្នាក់ដែលបណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន សេវាសុខភាព និងគោលនយោបាយជាតិដែលជួយឲ្យមានការថយចុះនូវគ្រោះថ្នាក់ផ្នែកសុខភាព ផ្នែកសង្គម និងផ្នែកសេដ្ឋកិច្ច ទៅដល់បុគ្គល សហគមន៍ និង សង្គម ដោយសារគ្រឿងញៀន ។

រាល់ការចំណាយសម្រាប់ការព្យាបាល និងការស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលសាធារណៈសម្រាប់ព្យាបាល និងស្តារនីតិសម្បទា ជាបន្ទុករបស់រដ្ឋ ។ មជ្ឈមណ្ឌលសាធារណៈសម្រាប់ព្យាបាល និងស្តារនីតិសម្បទាអាចទទួលវិភាគទានពីមជ្ឈដ្ឋានផ្សេងៗ សម្រាប់ទ្រទ្រង់ដល់ដំណើរការនៃមជ្ឈមណ្ឌល ។

រដ្ឋគាំទ្រ និងលើកទឹកចិត្តដល់មជ្ឈមណ្ឌលឯកជន និងសហគមន៍ក្នុងការចូលរួមផ្តល់សេវាព្យាបាលផ្នែកវេជ្ជសាស្ត្រ និងស្តារនីតិសម្បទាចំពោះអ្នកញៀនគ្រឿងញៀន ។ មជ្ឈមណ្ឌលឯកជន និងសហគមន៍ត្រូវមានជំនាញសមស្រប ដោយមានការទទួលស្គាល់ពីក្រសួងសុខាភិបាលលើការងារព្យាបាលអ្នកញៀនគ្រឿងញៀន និងទទួលស្គាល់ពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាលើការងារស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។ ការទទួលស្គាល់នេះ ត្រូវរាយការណ៍ជូនអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ ក្នុងគ្រប់ករណីទាំងអស់ ការទទួលអ្នកញៀនគ្រឿងញៀនដើម្បីព្យាបាល និងស្តារនីតិសម្បទាក្នុងមជ្ឈមណ្ឌលឯកជន ឬសហគមន៍ ត្រូវអនុលោមតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់នេះ ។

## មាត្រា ១០១.- គោលការណ៍នៃការព្យាបាល និងការស្តារនីតិសម្បទា

ជាគោលការណ៍ ការព្យាបាល និងការស្តារនីតិសម្បទាអាចធ្វើទៅបាន លុះត្រាតែទទួលបានការព្រមព្រៀងពីអ្នកញៀនគ្រឿងញៀន ។ ប៉ុន្តែ ក្នុងករណីពិសេសនិងដើម្បីជាប្រយោជន៍ដល់អ្នកញៀនគ្រឿងញៀននិងប្រយោជន៍ទូទៅ ការព្យាបាល និងការស្តារនីតិសម្បទាអាចធ្វើឡើងដោយបង្ខំបាន ស្របតាមលក្ខខណ្ឌ និងនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះ ។

ក្នុងករណីអ្នកញៀនគ្រឿងញៀនជាអនីតិជន ឬជនដែលត្រូវបានកម្រិតសមត្ថភាព ត្រូវមានការព្រមព្រៀងពីអ្នកតំណាងដែលច្បាប់បានកំណត់ ។ បទប្បញ្ញត្តិផ្សេងទៀតដែលពាក់ព័ន្ធនឹងអនីតិជន និងជនដែលត្រូវបានកម្រិតសមត្ថភាព ត្រូវយកមកអនុវត្តសម្រាប់ការព្យាបាល និងការស្តារនីតិសម្បទា ។

អ្នកជំនាញដែលទទួលខុសត្រូវក្នុងការព្យាបាល និងការស្តារនីតិសម្បទាផ្នែកគ្រឿងញៀន មិនត្រូវទទួលការចោទប្រកាន់ណាមួយនៅក្នុងការអនុវត្តមុខងារព្យាបាលរបស់ខ្លួន ស្របតាមជំនាញវេជ្ជសាស្ត្រ និងស្របតាមច្បាប់ជាធរមាន ។

## មាត្រា ១០២.- វិធាននៃការគ្រប់គ្រងការព្យាបាល និងការស្តារនីតិសម្បទា

ការព្យាបាល និងការស្តារនីតិសម្បទាភាពញៀនគ្រឿងញៀន ត្រូវមានសេវាផ្នែកវេជ្ជសាស្ត្រ និងសេវាសង្គមកិច្ចសមស្របតាមបែបវិទ្យាសាស្ត្រ ជាអាទិ៍ :



១- ការព្យាបាល និងការស្ដារនីតិសម្បទាត្រូវគ្រប់គ្រងដោយអ្នកជំនាញផ្នែកថែទាំសុខភាព និងអ្នកជំនាញផ្នែកស្ដារនីតិសម្បទា ។

២- វិធីសាស្ត្រព្យាបាល និងស្ដារនីតិសម្បទាត្រូវតែច្បាស់លាស់ចំពោះសេចក្ដីត្រូវការតាមរោគសញ្ញារបស់បុគ្គលម្នាក់ៗ ហើយត្រូវបានសម្រេចដោយអ្នកជំនាញផ្នែកថែទាំសុខភាព និងអ្នកជំនាញផ្នែកស្ដារនីតិសម្បទាដោយមានការពិគ្រោះយោបល់ និងយល់ព្រមពីបុគ្គលនោះ ។

៣- ការព្យាបាល និងការស្ដារនីតិសម្បទានោះត្រូវស្របទៅតាមនិយាមជាតិ និងអន្តរជាតិ ហើយប្រតិបត្តិឲ្យបានល្អបំផុត ទៅលើវិធានការព្យាបាលភាពញៀនគ្រឿងញៀនឲ្យមានប្រសិទ្ធភាព និងមនុស្សធម៌ ។

៤- ការព្យាបាលនិងការស្ដារនីតិសម្បទានោះ ត្រូវគ្រប់គ្រងក្នុងផលប្រយោជន៍តែមួយគត់សម្រាប់អ្នកញៀនគ្រឿងញៀន ដើម្បីធ្វើឲ្យពួកគេទទួលបានសមត្ថភាពតាមផ្លូវច្បាប់យ៉ាងពេញលេញ ។

៥- វិធានការព្យាបាល និងស្ដារនីតិសម្បទាភាពញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលសាធារណៈ សម្រាប់ព្យាបាល និងស្ដារនីតិសម្បទារបស់រដ្ឋ មានរយៈពេលចាប់ពី ៦(ប្រាំមួយ)ខែ ដល់ ២ (ពីរ) ឆ្នាំ ។

នីតិវិធីលំអិតសម្រាប់វិធីសាស្ត្រព្យាបាល និងការគ្រប់គ្រងវិធានការព្យាបាល និងស្ដារនីតិសម្បទាភាពញៀនគ្រឿងញៀន ត្រូវកំណត់ដោយអនុក្រឹត្យ ។

ក្នុងគ្រប់ករណីទាំងអស់ គ្មានបុគ្គលណាម្នាក់ដែលស្ថិតនៅក្រោមការព្យាបាល និងការស្ដារនីតិសម្បទាភាពញៀនគ្រឿងញៀន ជាកម្មវត្ថុនៃការពិសោធផ្នែកវេជ្ជសាស្ត្រ ឬវិទ្យាសាស្ត្របានឡើយ ។

**មាត្រា ១០៣.- ការសម្ងាត់នៃការព្យាបាល និងការស្ដារនីតិសម្បទា**

ការសម្ងាត់ផ្នែកព័ត៌មានទាំងអស់ទាក់ទងនឹងការព្យាបាល និងការស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវបានធានារក្សាការពារ ។ ការកត់ត្រាអំពីអត្តសញ្ញាណ រោគវិនិច្ឆ័យ ការវិវត្តប្រែប្រួលនៃជំងឺ ឬលទ្ធផលនៃការព្យាបាល និងការស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនដែលបានធ្វើឡើង ត្រូវរក្សាជាការសម្ងាត់ ដោយមិនអាចបង្ហាញជាសាធារណៈ ឬចែករំលែកជាមួយបុគ្គល ឬភ្នាក់ងារផ្សេងទៀតឡើយ លើកលែងតែជាតម្រូវការនៃប្រយោជន៍សាធារណៈ ឬមានការព្រមព្រៀងពីបុគ្គលពាក់ព័ន្ធ ។

## ផ្នែកទី ២
## ការព្យាបាល និងការស្តារនីតិសម្បទាដោយស្ម័គ្រចិត្ត

**មាត្រា ១០៤.- ការព្យាបាល និងការស្តារនីតិសម្បទាដោយស្ម័គ្រចិត្ត**

បុគ្គលគ្រប់រូបដែលស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀន អាចស្វែងរកសេវាព្យាបាលផ្នែកវេជ្ជសាស្ត្រ និងស្តារនីតិសម្បទាបាន នៅតាមមជ្ឈមណ្ឌលដែលត្រូវបានបង្កើតឡើងក្នុងគោលបំណងព្យាបាល និងស្តារនីតិសម្បទា ។ មុននឹងសម្រេចចិត្តទទួលយកការព្យាបាល និងការស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀនមានសិទ្ធិទទួលបានពីមជ្ឈមណ្ឌលនូវព័ត៌មានសំខាន់ៗ អំពីការព្យាបាល និងការស្តារនីតិសម្បទា ជាអាទិ៍ :

- ប្រភេទនិងរយៈពេលនៃការព្យាបាល និងការស្តារនីតិសម្បទា
- វិធីនៃការព្យាបាល និងការស្តារនីតិសម្បទា និងការលំបាកនៃការព្យាបាល និងការស្តារនីតិសម្បទា
- ផលប្រយោជន៍នៃការព្យាបាល និងការស្តារនីតិសម្បទាដែលរំពឹងទុក
- ផលប៉ះពាល់ជាយថាហេតុ ដោយសារការព្យាបាល និងការស្តារនីតិសម្បទា
- ជម្រើសផ្សេងទៀតក្រៅពីការព្យាបាល និងការស្តារនីតិសម្បទា ប្រសិនបើមាន
- ផលវិបាកនៃការមិនទទួលយកការព្យាបាល និងការស្តារនីតិសម្បទា ។

មុននឹងទទួលព្យាបាល និងស្តារនីតិសម្បទា មជ្ឈមណ្ឌលត្រូវធានាថា អ្នកញៀនគ្រឿងញៀនពិតជាបានផ្តល់ការយល់ព្រមដោយស្ម័គ្រចិត្តឲ្យព្យាបាល និងស្តារនីតិសម្បទា បន្ទាប់ពីបានទទួលនូវព័ត៌មានសំខាន់ៗអំពីការព្យាបាល និងការស្តារនីតិសម្បទា ។ ការយល់ព្រមទទួលយកការព្យាបាល និងការស្តារនីតិសម្បទារបស់អ្នកញៀនគ្រឿងញៀន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ។

អ្នកញៀនគ្រឿងញៀនមានសិទ្ធិចូលរួមក្នុងការសម្រេចចិត្តទទួលយកវិធីនៃការព្យាបាល និងការស្តារនីតិសម្បទា ដោយរាប់បញ្ចូលទាំងពេលវេលានៃការចូលទៅទទួលយកការព្យាបាល និងការស្តារនីតិសម្បទា និងការបញ្ឈប់ការព្យាបាល និងការស្តារនីតិសម្បទា ។ អ្នកញៀនគ្រឿងញៀនអាចឈប់ទទួលយកការព្យាបាលដោយស្ម័គ្រចិត្តនៅពេលណាក៏បាន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## ផ្នែកទី ៣
## លក្ខខណ្ឌនៃការចោទប្រកាន់ និងការអនុវត្តទោសចំពោះ អ្នកញៀនគ្រឿងញៀន

### មាត្រា ១០៥.- លក្ខខណ្ឌនៃការចោទប្រកាន់អ្នកញៀនគ្រឿងញៀន

មុននឹងសម្រេចចោទប្រកាន់បុគ្គលដែលបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤៥ (បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) និងមាត្រា ៥៣ (បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) នៃច្បាប់នេះ ព្រះរាជអាជ្ញាអាចណែនាំបុគ្គលនេះឲ្យទៅទទួលយកការព្យាបាល និងការស្តារនីតិសម្បទានៅមជ្ឈមណ្ឌលសាធារណៈ ឬឯកជន ប្រសិនបើបុគ្គលនេះស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀន ដែលមានការបញ្ជាក់ត្រឹមត្រូវផ្នែកវេជ្ជសាស្ត្រពីគ្រូពេទ្យជំនាញ ។

ប្រសិនបើបុគ្គលនេះមិនយល់ព្រមទទួលយកការព្យាបាល និងការស្តារនីតិសម្បទាទេ នោះព្រះរាជអាជ្ញាប្រើប្រាស់នូវសិទ្ធិអំណាចរបស់ខ្លួនទាក់ទងនឹងជម្រើសនៃការចោទប្រកាន់ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

ប៉ុន្តែប្រសិនបើបុគ្គលនេះយល់ព្រមទទួលយកការព្យាបាល និងការស្តារនីតិសម្បទាព្រះរាជអាជ្ញាត្រូវកត់ត្រាជាលាយលក្ខណ៍អក្សរអំពីការយល់ព្រមនេះ និងត្រូវជូនដំណឹងជាបន្ទាន់ទៅមជ្ឈមណ្ឌល អំពីការសម្រេចចិត្តនេះ ។ ក្នុងករណីនេះ ការចោទប្រកាន់ត្រូវបង្អង់សិន ។ នីតិវិធីនៃការចោទប្រកាន់ត្រូវបន្តឡើងវិញ ប្រសិនបើបុគ្គលនោះបានគេចវេះមិនទទួលយកការព្យាបាលនិងការស្តារនីតិសម្បទារហូតដល់ចប់ តាមការកំណត់របស់មជ្ឈមណ្ឌល ។

ប្រសិនបើបុគ្គលនោះទទួលយកវិធានការនៃការព្យាបាល និងការស្តារនីតិសម្បទារហូតដល់ទីបញ្ចប់ ព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការ ។

### មាត្រា ១០៦.- លក្ខខណ្ឌនៃការអនុវត្តទោសចំពោះអ្នកញៀនគ្រឿងញៀន

ប្រសិនបើទណ្ឌិតស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀន ដែលមានការបញ្ជាក់ត្រឹមត្រូវផ្នែកវេជ្ជសាស្ត្រពីគ្រូពេទ្យជំនាញស្ម័គ្រចិត្តស្នើសុំទទួលយកវិធានការព្យាបាល និងស្តារនីតិសម្បទា ស្របតាមជំពូកទី ៦ (វិធានការព្យាបាល និង ស្តារនីតិសម្បទា) នៃច្បាប់នេះ បន្ទាប់ពីតុលាការបានប្រកាសទោសជាស្ថាពររួចហើយ ពីបទល្មើសដូចមានចែងក្នុងមាត្រា ៤៥ (បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) និងមាត្រា ៥៣ (បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) នៃច្បាប់នេះ ក្នុងករណីនេះ ការអនុវត្តទោសអាចផ្អាកសិន ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

បើទណ្ឌិតនោះទទួលយកវិធានការព្យាបាល និងស្តារនីតិសម្បទារហូតដល់ចប់ ទណ្ឌិតនោះត្រូវបានចាត់ទុកថាបានទទួលរងទោសរួចហើយ ។ ផ្ទុយទៅវិញ បើទណ្ឌិតនោះមិនទទួលយកវិធានការព្យាបាល និងស្តារនីតិសម្បទារហូតដល់ចប់ ទោសដែលប្រកាសរួចហើយ ត្រូវយកមកអនុវត្តវិញភ្លាម ។

## ផ្នែកទី ៤
## ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ

**មាត្រា ១០៧.- លក្ខខណ្ឌទូទៅនៃការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ**

គ្មានបុគ្គលណាម្នាក់អាចត្រូវបានបង្ខំឲ្យព្យាបាល និងស្តារនីតិសម្បទាភាពញៀនគ្រឿងញៀនឡើយ លើកលែងតែក្នុងករណីដែលបុគ្គលនោះស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀនធ្ងន់ធ្ងរ និងមានការគំរាមកំហែងយ៉ាងជាក់ស្តែងថានឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរភ្លាមៗចំពោះអ្នកញៀនគ្រឿងញៀនខ្លួនឯង ឬចំពោះអ្នកដទៃ ។ ក្នុងករណីនេះការព្យាបាល និងការស្តារនីតិសម្បទាអាចធ្វើឡើងដោយបង្ខំបាន ប្រសិនបើការព្យាបាល និងការស្តារនីតិសម្បទានេះ គឺជាវិធានការចាំបាច់ដើម្បីការពារប្រយោជន៍ទូទៅនិងដើម្បីជាប្រយោជន៍ដល់អ្នកញៀនគ្រឿងញៀន ។

ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំក៏អាចធ្វើបានដែរ ប្រសិនបើអ្នកញៀនគ្រឿងញៀនស្ថិតនៅក្នុងស្ថានភាពខ្វះសមត្ថភាពក្នុងការសំដែងឆន្ទៈ ដើម្បីទទួលយកការព្យាបាល និងការស្តារនីតិសម្បទាដោយស្ម័គ្រចិត្ត ។

**មាត្រា ១០៨.- ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំបង្គាប់ដោយព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញាអាចទទួលបណ្តឹងសុំដោយផ្ទាល់ពីឪពុកម្តាយ អាណាព្យាបាល ឬសាច់ញាតិរបស់អ្នកញៀនគ្រឿងញៀន ឬតាមរយៈមន្ត្រីមានសមត្ថកិច្ចផ្សេងទៀត ។ ក្នុងករណីនេះ អ្នកញៀនគ្រឿងញៀនអាចត្រូវបានបញ្ជូនខ្លួនជាបន្ទាន់ ដោយមន្ត្រីមានសមត្ថកិច្ច ឬដោយក្រុមគ្រួសាររបស់អ្នកញៀនគ្រឿងញៀនទៅព្រះរាជអាជ្ញាដើម្បីចាត់ការជាសមត្ថកិច្ចតាមនីតិវិធី ។

មុននឹងសម្រេច ព្រះរាជអាជ្ញា ត្រូវស្នើសុំឲ្យមានការពិនិត្យផ្នែកវេជ្ជសាស្ត្រពីគ្រូពេទ្យ ហើយអាចសួរយកចម្លើយពីបុគ្គលនោះបាន នៅចំពោះមុខមេធាវី ប្រសិនបុគ្គលនោះមានមេធាវីអមផង ។ គ្រូពេទ្យដែលត្រូវបានចាត់ឲ្យពិនិត្យផ្នែកវេជ្ជសាស្ត្រត្រូវផ្តល់លទ្ធផល ក្នុងរយៈពេលឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។

ព្រះរាជអាជ្ញាអាចបង្គាប់ឲ្យរក្សាទុកបុគ្គលនោះនៅកន្លែងឃាត់ខ្លួននៃអង្គភាពនគរបាលយុត្តិធម៌ ក្នុងអំឡុងពេលរង់ចាំលទ្ធផលនៃការពិនិត្យផ្នែកវេជ្ជសាស្ត្រ ។

ប្រសិនបើលទ្ធផលនៃការពិនិត្យផ្នែកវេជ្ជសាស្ត្របញ្ជាក់ថា បុគ្គលនោះស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀន ប៉ុន្តែមិនមានគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០៧ (លក្ខខណ្ឌទូទៅនៃការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ) ខាងលើទេ ព្រះរាជអាជ្ញាត្រូវចាត់នីតិវិធីដូចមានចែងក្នុងមាត្រា ១០៥ (លក្ខខណ្ឌនៃការចោទប្រកាន់អ្នកញៀនគ្រឿងញៀន) នៃច្បាប់នេះ ក្នុងករណីដែលបុគ្គលនេះបានប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា ៤៥ (បទប្រើប្រាស់ដោយ ខុសច្បាប់នូវសារធាតុញៀន) និងមាត្រា ៥៣ (បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន) នៃច្បាប់នេះ ។

ប្រសិនបើលទ្ធផលនៃការពិនិត្យផ្នែកវេជ្ជសាស្ត្របញ្ជាក់ថា បុគ្គលនោះស្ថិតក្នុងស្ថានភាពញៀនគ្រឿងញៀនធ្ងន់ធ្ងរ ឬមានភស្តុតាងផ្សេងទៀតបញ្ជាក់អំពីការគំរាមកំហែងយ៉ាងច្បាស់ថានឹងមានគ្រោះថ្នាក់ធ្ងន់ធ្ងរភ្លាមៗចំពោះខ្លួនឯង ឬចំពោះអ្នកដទៃ ព្រះរាជអាជ្ញាអាចសម្រេចឲ្យមានការព្យាបាលនិងការស្តារនីតិសម្បទាដោយបង្ខំបាន ។

បុគ្គលដែលត្រូវបានបង្ខំឲ្យព្យាបាល និងស្តារនីតិសម្បទាមានសិទ្ធិប្តឹងតវ៉ាចំពោះដីកាសម្រេចបង្ខំឲ្យព្យាបាល និងស្តារនីតិសម្បទារបស់ព្រះរាជអាជ្ញា ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញនៅអង្គការអយ្យការពាក់ព័ន្ធ ។ បន្ទាប់មកសំណុំរឿងត្រូវបានបញ្ជូនភ្លាមទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដោយតំណាងអយ្យការអមសាលាដំបូង ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវសម្រេចក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង គិតពីថ្ងៃដែលបានទទួលសំណុំរឿង ។

## មាត្រា ១០៩.- ការបង្ខំឲ្យព្យាបាល និងស្តារនីតិសម្បទានៅក្នុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ

ការបង្ខំឲ្យព្យាបាល និងស្តារនីតិសម្បទា អាចធ្វើបាននៅក្នុងដំណាក់កាលស៊ើបសួរដោយចៅក្រមស៊ើបសួរ និងនៅក្នុងដំណាក់កាលជំនុំជម្រះ ដោយចៅក្រមជំនុំជម្រះ ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០៧ (លក្ខខណ្ឌទូទៅនៃការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ) និងក្នុងកថាខណ្ឌទី ២ និងកថាខណ្ឌទី ៥ មាត្រា ១០៨ (ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំបង្គាប់ដោយព្រះរាជអាជ្ញា) នៃច្បាប់នេះ ។

សេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ ឬចៅក្រមជំនុំជម្រះ អាចប្តឹងឧទ្ធរណ៍បានស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១១០.- មូលដ្ឋានដោយឡែកនៃការកំណត់ទោស**

បន្ថែមលើបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ បុគ្គលដែលទទួលរងនូវការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ហូរហូតដល់ទីបញ្ចប់ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់អំពីទោស ។

## ជំពូកទី ៧
## បត្យាប័ន និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់

### ផ្នែកទី ១
### បត្យាប័ន

**មាត្រា ១១១.- បត្យាប័ននៃអាណិកជនបរទេសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា**

ព្រះរាជាណាចក្រកម្ពុជាអាចយល់ព្រមប្រគល់ដល់រដ្ឋបរទេស នូវអាណិកជនបរទេសដែលស្នាក់នៅលើដែនដីកម្ពុជា ហើយដែល :

- ជាកម្មវត្ថុនៃនីតិវិធីចោទប្រកាន់តាមផ្លូវតុលាការនៅក្នុងរដ្ឋបរទេសនោះ ចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ ឬ
- ត្រូវបានផ្តន្ទាទោសដោយដាក់ពន្ធនាគារដោយតុលាការនៃរដ្ឋបរទេសនោះ ចំពោះបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ១១២.- បទប្បញ្ញត្តិគ្រប់គ្រងការធ្វើបត្យាប័នចំពោះបទល្មើសទាក់ទងនឹងគ្រឿងញៀន**

បត្យាប័នអាណិកជនបរទេសនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានគ្រប់គ្រងដោយបទប្បញ្ញត្តិនៃសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិដែលទាក់ទងនឹងបត្យាប័ន ដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីគ្មានសន្ធិសញ្ញា ឬអនុសញ្ញាអន្តរជាតិដែលត្រូវបានទទួលសច្ចាប័នពីព្រះរាជាណាចក្រកម្ពុជាទេ លក្ខខណ្ឌនិងនីតិវិធីនៃបត្យាប័នដែលស្នើសុំដោយរដ្ឋបរទេស ឬដោយព្រះរាជាណាចក្រកម្ពុជាចំពោះរដ្ឋបរទេស ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**មាត្រា ១១៣.- ការឆ្លងកាត់**

ការឆ្លងកាត់ដែនដីនៃព្រះរាជាណាចក្រកម្ពុជាដោយបុគ្គលណាម្នាក់ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃនីតិវិធីបត្យាប័ន អាចត្រូវបានអនុញ្ញាត កាលណាបត្យាប័ននេះមិនទាក់ទងនឹងបទល្មើសនយោបាយទេ។ ពាក្យសុំឆ្លងកាត់ត្រូវធ្វើតាមផ្លូវទូត។ ពាក្យសុំត្រូវតែមានលិខិតបញ្ជាក់កស្តុតាងបញ្ជាក់ថាត្រឹមត្រូវអមជាមួយផង។

## ផ្នែកទី ២
## ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់

**មាត្រា ១១៤.- សំណើរបស់រដ្ឋបរទេសចំពោះព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬចំណាត់ការតុលាការនៅក្នុងរដ្ឋបរទេស**

មាត្រានេះត្រូវអនុវត្ត ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាទទួលសំណើពីរដ្ឋបរទេសណាមួយសុំជំនួយទាក់ទងនឹង :

១- ការស៊ើបអង្កេតបទល្មើសនៅក្រោមច្បាប់របស់រដ្ឋបរទេស ដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ។

២- ចំណាត់ការរឿងក្តីតុលាការចំពោះបទល្មើសនេះ ។

៣- ការស៊ើបអង្កេតទាក់ទងនឹងទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើស ។

៤- ចំណាត់ការសម្រាប់ការបង្កក ឬការរឹបអូសទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើសនៅក្នុងរដ្ឋធ្វើសំណើ ។

៥- ការបង្កក ឬការរឹបអូសនូវទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

តាមរយៈតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចផ្សេងទៀត រាជរដ្ឋាភិបាលកម្ពុជាអាចផ្តល់ជំនួយតាមវិធីណាមួយដូចខាងក្រោម :

១- ធ្វើកំណត់ហេតុកស្តុតាងជាលាយលក្ខណ៍អក្សរ ឬដោយសួរផ្ទាល់មាត់ពីបុគ្គលនានា ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

២- ជួយឲ្យបុគ្គលទាំងនោះ រួមទាំងបុគ្គលដែលត្រូវបានឃុំខ្លួន ដោយមានការយល់ព្រមពីសាមីខ្លួន ឲ្យបានផ្តល់ភស្តុតាង ឬឲ្យជួយក្នុងការស៊ើបអង្កេត ។

៣- ផ្តល់ឯកសារតុលាការ ។

៤- អនុវត្តការឆែកឆេរ ។

៥- ជួយក្នុងការតាមដានរកទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើស ។

៦- ស៊ើបអង្កេតការជួញដូរហិរញ្ញវត្ថុ ។

៧- ទទួលព័ត៌មាន ឬភស្តុតាងដែលអាចជួយក្នុងការស្តារឡើងវិញនូវទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើសដើម្បីរឹបអូស ។

៨- បង្កកទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើស ដើម្បីទប់ស្កាត់ការលក់ដូរ ឬការផ្ទេរ ឬការបោះបង់ចោលទ្រព្យដែលរង់ចាំការសម្រេចអំពីការរឹបអូស ។

៩- រឹបអូសទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើស រួមទាំងឯកសារ ។

១០- អនុវត្តសេចក្តីសម្រេចចុងក្រោយរបស់រដ្ឋបរទេសក្នុងការរឹបអូសទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើស ។

១១- ត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រលើវត្ថុតាង និងទីកន្លែងកើតហេតុ ។

១២- ផ្តល់ព័ត៌មាន និងវត្ថុតាងដល់រដ្ឋបរទេស ។

១៣- ផ្តល់ឯកសារដើម ឬច្បាប់ចម្លងដែលត្រូវមានបញ្ជាក់នៃឯកសារ ឬកំណត់ហេតុពាក់ព័ន្ធ រួមមានឯកសារធនាគារ ហិរញ្ញវត្ថុ សាជីវកម្ម ឬអាជីវកម្ម ជាអាទិ៍ ដល់រដ្ឋបរទេស ។

ព័ត៌មាន និងវត្ថុតាងដែលអាចត្រូវបានផ្តល់ឲ្យរដ្ឋបរទេស ដោយយោងតាមកថាខណ្ឌទី ២ ចំណុចទី ១២ ខាងលើនេះ រួមមានព័ត៌មានដែលទទួលបានស្របច្បាប់ទាំងអស់ រួមទាំងព័ត៌មានដែលបានមកពីការចាប់ និងការថត គ្រប់ការឆ្លើយឆ្លងគ្នាតាមទូរគមនាគមន៍ ឬដោយការប្រើឧបករណ៍លបស្តាប់ ។

ដើម្បីអនុវត្តសំណើសុំជំនួយពីរដ្ឋបរទេស នីតិវិធី និងដំណើរការនៅក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ការស៊ើបអង្កេត ការចោទប្រកាន់ ឬការស៊ើបសួរចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នៃព្រះរាជា-ណាចក្រកម្ពុជា អាចត្រូវបានប្រើប្រាស់សម្រាប់ការផ្តល់ជំនួយដល់រដ្ឋបរទេស ។

**មាត្រា ១១៥.- ជំនួយអាចត្រូវផ្តល់ជូនដោយផ្អែកលើលក្ខខណ្ឌ**

រាជរដ្ឋាភិបាលកម្ពុជាអាចផ្តល់ជំនួយទៅកាន់រដ្ឋបរទេសតាមផ្នែកនេះ ដោយផ្អែកលើលក្ខខណ្ឌតម្រូវឲ្យរដ្ឋធ្វើសំណើផ្តល់ការសន្យាជាលាយលក្ខណ៍អក្សរថា ខ្លួននឹងផ្តល់ជំនួយក្នុងរឿងដូចគ្នានេះ ប្រសិនបើព្រះរាជាណាចក្រកម្ពុជាធ្វើសំណើដូចគ្នា ។

**មាត្រា ១១៦.- មូលហេតុចាំបាច់សម្រាប់ការបដិសេធសំណើសុំជំនួយ**

រាជរដ្ឋាភិបាលកម្ពុជានឹងមិនត្រូវយល់ព្រមតាមសំណើសុំជំនួយ ទាក់ទងនឹងបទល្មើសតាមបញ្ញត្តិនៃផ្នែកនេះ ប្រសិនបើយល់ឃើញថា :

១- សំណើត្រូវបានធ្វើឡើងដើម្បីផ្តន្ទាទោសបុគ្គលណាម្នាក់ ដោយសារតែពូជសាសន៍ សាសនា សញ្ជាតិ ដើមកំណើត ជាតិពន្ធុ ឬទស្សនៈនយោបាយរបស់បុគ្គលនោះ ។

២- ស្ថានភាពរបស់បុគ្គលនោះអាចត្រូវរងបុរេនិច្ឆ័យ ដោយសារតែពូជសាសន៍ សាសនា សញ្ជាតិ ដើមកំណើត ជាតិពន្ធុ ឬទស្សនៈនយោបាយរបស់បុគ្គលនោះ ។

៣- សំណើទាក់ទងនឹងការផ្តន្ទាទោសបុគ្គលនោះចំពោះបទល្មើស ហើយ :

- បុគ្គលនោះត្រូវបានសម្រេចឲ្យរួចខ្លួនជាស្ថាពរ ឬត្រូវបានលើកលែងទោស ដោយតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ចនៅក្នុងរដ្ឋបរទេស ឬ
- បុគ្គលនោះបានទទួលរងទោសតាមបញ្ញត្តិចែងដោយច្បាប់នៃរដ្ឋនោះ ចំពោះបទល្មើសនោះ ឬចំពោះបទល្មើសដទៃទៀតដែលអំពើដូចគ្នានឹងបទល្មើសនោះរួចហើយ ។

**មាត្រា ១១៧.- វិធាននៃការសម្ងាត់ធនាគារ**

សំណើសុំជំនួយតាមបទប្បញ្ញត្តិនៃផ្នែកនេះមិនត្រូវបដិសេធ ដោយសារតែមូលហេតុនៃការសម្ងាត់របស់ធនាគារឡើយ ។

**មាត្រា ១១៨.- សំណើសុំផ្តល់ភស្តុតាងក្នុងតុលាការនៅក្នុងរដ្ឋបរទេស**

មាត្រានេះត្រូវអនុវត្ត ប្រសិនបើ :

១- សវនាការទាក់ទងនឹង :

- បទល្មើសក្រោមច្បាប់របស់រដ្ឋបរទេសដែលស្របគ្នានឹងបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ឬ

- ការបង្កក ឬការរឹបអូសទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស ជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើសបានចាប់ផ្តើមនៅក្នុងរដ្ឋបរទេស និង

២- រដ្ឋបរទេសនោះស្នើសុំឲ្យមានការចូលរួមនៅក្នុងសវនាការ ទាក់ទងនឹងដំណើរការជំនុំជម្រះនូវបុគ្គលណាមួយដែលស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា និង

៣- មានមូលហេតុសមហេតុផលនឹងជឿថា បុគ្គលនោះមានសមត្ថភាពក្នុងការផ្តល់ភស្តុតាងពាក់ព័ន្ធនឹងដំណើរការជំនុំជម្រះ ហើយនិង

៤-បុគ្គលនោះបានយល់ព្រមផ្តល់ភស្តុតាងនៅក្នុងរដ្ឋបរទេស ។

រដ្ឋបរទេសត្រូវតែផ្តល់ការសន្យា ដូចខាងក្រោម :

១-បុគ្គលនោះនឹងមិនត្រូវ :

-បានឃុំខ្លួន ឬផ្តន្ទាទោសចំពោះបទល្មើសណាមួយប្រឆាំងនឹងច្បាប់របស់រដ្ឋបរទេស ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្ត ឬដែលបានប្រព្រឹត្តមុន ពេលបុគ្គលនោះចាកចេញពីព្រះរាជាណាចក្រកម្ពុជា ឬ

- ទទួលរងនូវបណ្តឹងរដ្ឋប្បវេណីណាមួយ ចំពោះអំពើ ឬការគេចវេះរបស់បុគ្គលនោះដែលត្រូវបានចោទប្រកាន់ថាបានកើតឡើង ឬដែលបានកើតឡើង មុនពេលដែលបុគ្គលនោះចាកចេញពីព្រះរាជាណាចក្រកម្ពុជា ប្រសិនបើបុគ្គលនោះមិនត្រូវទទួលរងនូវបណ្តឹងរដ្ឋប្បវេណី ក្នុងករណីដែលបុគ្គលនោះមិនស្ថិតនៅរដ្ឋបរទេសនោះទេ ឬ

- បានតម្រូវឲ្យផ្តល់ភស្តុតាងក្នុងដំណើរការជំនុំជម្រះផ្សេងទៀតក្នុងរដ្ឋបរទេស ក្រៅពីដំណើរការជំនុំជម្រះដែលពាក់ព័ន្ធនឹងសំណើនោះ ។ លើកលែងតែបុគ្គលនោះបានចាកចេញពីរដ្ឋបរទេស ឬបុគ្គលនោះមានឱកាសចាកចេញពីរដ្ឋបរទេស ហើយបែរជាស្ថិតនៅក្នុងរដ្ឋបរទេសនោះតទៅទៀត ក្រៅពីគោលបំណងផ្តល់ភស្តុតាងក្នុងដំណើរការជំនុំជម្រះដែលពាក់ព័ន្ធនឹងសំណើនោះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

២- ភស្តុតាងណាដែលបុគ្គលនោះផ្តល់ឲ្យ ក្នុងដំណើរការជំនុំជម្រះដែលពាក់ព័ន្ធនឹងសំណើនោះមិនអាចទទួលយកបាន ឬមិនបានការ សម្រាប់ការកាត់ទោសជនល្មើសប្រឆាំងនឹងច្បាប់នៃរដ្ឋបរទេសនោះ មិនមែនជាបទល្មើសផ្តល់សក្ខីភាពក្លែងក្លាយ ចំពោះការផ្តល់ភស្តុតាងទាំងនោះ ។

៣- បុគ្គលនោះនឹងត្រូវបញ្ជូនមកព្រះរាជាណាចក្រកម្ពុជាវិញ យោងតាមការព្រមព្រៀងដែលត្រូវបានឯកភាពគ្នាដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ។

៤- ប្រសិនបើបុគ្គលនោះកំពុងស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ននៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាស្នើសុំរដ្ឋបរទេសនោះ ឲ្យធ្វើការចាត់ចែងដើម្បីរក្សាបុគ្គលនោះឲ្យស្ថិតក្នុងការឃុំខ្លួន នៅពេលដែលបុគ្គលនោះស្ថិតនៅក្នុងរដ្ឋបរទេសនោះ :

- រដ្ឋនោះត្រូវធ្វើការរៀបចំសមស្របសម្រាប់គោលបំណងនេះ ហើយ

- បុគ្គលនោះនឹងមិនត្រូវដោះលែងឲ្យនៅក្រៅឃុំ នៅក្នុងរដ្ឋបរទេសឡើយ លើកលែងតែរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាជូនដំណឹងដល់អាជ្ញាធរសមស្របនៃរដ្ឋបរទេសនោះថា បុគ្គលនោះទទួលបានសិទ្ធិត្រូវដោះលែងតាមបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង

- ប្រសិនបើបុគ្គលនោះត្រូវបានដោះលែងនៅក្នុងរដ្ឋបរទេស ដូចមានចែងក្នុងវាក្យខណ្ឌទី ២ នៃចំណុចទី ៤ ខាងលើនេះ រដ្ឋបរទេសនោះត្រូវទទួលបន្ទុកចំណាយលើការស្នាក់នៅ និងចំណាយផ្សេងៗរបស់បុគ្គលនោះ រហូតដល់ចំណាត់ការរឿងក្តីដែលពាក់ព័ន្ធនឹងសំណើនោះត្រូវបានបញ្ចប់ ។

## មាត្រា ១១៩.- សំណើដោយព្រះរាជាណាចក្រកម្ពុជា ចំពោះរដ្ឋបរទេសមួយ ដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬចំណាត់ការតុលាការ

រាជរដ្ឋាភិបាលកម្ពុជាអាចស្នើសុំទៅរដ្ឋបរទេសឲ្យផ្តល់នូវជំនួយ ទាក់ទងនឹង :

១- ការស៊ើបអង្កេតចំពោះបទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ។

២- ចំណាត់ការតុលាការសម្រាប់បទល្មើសតាមបញ្ញត្តិនៃច្បាប់នេះ ។

៣- ការស៊ើបអង្កេតទាក់ទងនឹងទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើសជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើស ។

៤- ចំណាត់ការដើម្បីបង្កក ឬរឹបអូសទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើសជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

៥- ការបង្កក ឬការរឹបអូសទ្រព្យដែលត្រូវបានប្រើប្រាស់ ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើសជាកម្មវត្ថុ ឬជាផលដែលកើតចេញពីបទល្មើសនៅក្នុងរដ្ឋដែលត្រូវបានស្នើសុំ ។

សំណើអាចត្រូវបានធ្វើឡើងដើម្បីសុំជំនួយនៅក្នុងរដ្ឋបរទេស នៅក្នុងករណីណាមួយដែលមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១១៤ (សំណើរបស់រដ្ឋបរទេសចំពោះព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬចំណាត់ការតុលាការនៅក្នុងរដ្ឋបរទេស) នៃច្បាប់នេះ ។

ភស្តុតាងដែលទទួលបានដោយស្របច្បាប់នៅក្នុងរដ្ឋបរទេស អាចត្រូវបានប្រើប្រាស់ជាភស្តុតាងនៅក្នុងចំណាត់ការរឿងក្ដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ប្រសិនបើបុគ្គលមួយរូបដែលកំពុងត្រូវបានឃុំខ្លួននៅក្នុងរដ្ឋបរទេស ត្រូវបានឲ្យផ្ដល់ភស្តុតាងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយរដ្ឋបរទេសនោះស្នើសុំឲ្យរាជរដ្ឋាភិបាលកម្ពុជាចាត់ចែងដើម្បីរក្សាបុគ្គលនោះក្នុងការឃុំខ្លួន នៅពេលដែលបុគ្គលនោះស្ថិតនៅក្នុងព្រះរាជាណាចក្រកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា :

១- ត្រូវធ្វើការចាត់ចែងសមស្របសម្រាប់គោលបំណងនោះ ឬ

២- មិនត្រូវដោះលែងបុគ្គលនោះឲ្យនៅក្រៅឃុំនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ លើកលែងតែ រដ្ឋបរទេសជូនដំណឹងដល់អាជ្ញាធរសមស្របនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាថា បុគ្គលនោះទទួលបានសិទ្ធិ ត្រូវដោះលែងក្រោមច្បាប់របស់រដ្ឋបរទេសនោះ ហើយ

៣- ប្រសិនបើបុគ្គលនោះត្រូវបានដោះលែងនៅព្រះរាជាណាចក្រកម្ពុជា ដូចមានចែងនៅក្នុងចំណុចទី ២ ខាងលើនេះ ត្រូវទូទាត់ចំណាយលើការស្នាក់នៅ និងចំណាយផ្សេងៗរបស់បុគ្គលនោះ រហូតដល់ចំណាត់ការរឿងក្ដីដែលពាក់ព័ន្ធនឹងសំណើនោះត្រូវបានបញ្ចប់ ។

បុគ្គលណាដែលត្រូវបានឲ្យផ្ដល់ភស្តុតាងនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយរដ្ឋបរទេស ត្រូវតែបានបញ្ជូនទៅកាន់រដ្ឋនោះវិញ ដោយពុំចាំបាច់មានចំណាត់ការបត្យាប័ន យោងតាមការព្រមព្រៀងដែលត្រូវបានឯកភាពគ្នាជាមួយរដ្ឋបរទេសនោះ ។

**មាត្រា ១២០.- សហប្រតិបត្តិការអន្តរជាតិ**

បទប្បញ្ញត្តិនៃផ្នែកនេះពុំកម្រិត ឬរារាំងដល់ការផ្ដល់ ឬការទទួលព័ត៌មាន ឬកិច្ចសហប្រតិបត្តិការអន្តរជាតិ ទាក់ទងនឹងបទល្មើសណាមួយដែលមានចែងក្នុងច្បាប់នេះ ឬបទល្មើសស្របគ្នាក្រោមច្បាប់របស់រដ្ឋបរទេស ទោះជាវិធីណាក៏ដោយ ។



# ជំពូកទី ៨
# អន្តរប្បញ្ញត្តិ

## មាត្រា ១២១.- អន្តរប្បញ្ញត្តិស្តីពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនដែលត្រូវបានបង្កើតដោយព្រះរាជក្រឹត្យលេខ នស/ រកត/ ០៥០៩/៦០៨ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៩ ត្រូវបន្តជាស្ថាប័នអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន រហូតមានបទប្បញ្ញត្តិថ្មីមកជំនួស ។

## មាត្រា ១២២.- អន្តរប្បញ្ញត្តិស្តីពីអាជ្ញាបណ្ណ និងការអនុញ្ញាត

អាជ្ញាបណ្ណ និងការអនុញ្ញាតដែលត្រូវបានផ្តល់ស្របតាមបទប្បញ្ញត្តិពីមុនសម្រាប់ការធ្វើសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ត្រូវមានសុពលភាពបន្តទៀត រហូតដល់អាជ្ញាបណ្ណនិងការអនុញ្ញាតនោះអស់សុពលភាព ។

ការផ្តល់ ការបន្ត ឬការដកហូតអាជ្ញាបណ្ណ និងការអនុញ្ញាត ក្រោយការចូលជាធរមាននៃច្បាប់នេះ ត្រូវអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## មាត្រា ១២៣.- អន្តរប្បញ្ញត្តិស្តីពីនីតិវិធី

បទប្បញ្ញត្តិស្តីពីនីតិវិធីដែលមានចែងក្នុងច្បាប់នេះត្រូវអនុវត្តភ្លាមចំពោះគ្រប់កិច្ចនីតិវិធី ក្រោយច្បាប់នេះចូលជាធរមាន ។

ការអនុវត្តបទប្បញ្ញត្តិនៃច្បាប់នេះ គ្មានអានុភាពទៅលើសុពលភាពនៃកិច្ចនីតិវិធីដែលបានបំពេញដោយអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ចាស់ឡើយ ។

## មាត្រា ១២៤.- អន្តរប្បញ្ញត្តិស្តីពីបទល្មើស

បទល្មើសព្រហ្មទណ្ឌដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលដែលច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៥/០១៤ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវបន្តអនុវត្តតាមច្បាប់ចាស់ និងអនុលោមតាមបទប្បញ្ញត្តិគន្ថីទី ១ (បទប្បញ្ញត្តិទូទៅ) នៃក្រមព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៩ ។

# ជំពូកទី ៩
# អវសានបញ្ញត្តិ

**មាត្រា ១២៥.- និរាករណ៍នៃបទបញ្ញត្តិ និងករណីលើកលែង**

ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៧/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនដែលប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០០៥ ត្រូវបាត់បង់អានុភាពចាប់ពីថ្ងៃដែលច្បាប់នេះត្រូវបានអនុវត្ត លើកលែងតែករណីដែលមានចែងក្នុងមាត្រា ១២៤ (អន្តរប្បញ្ញត្តិស្តីពីបទល្មើស) នៃច្បាប់នេះ ។

បទដ្ឋានគតិយុត្តក្រោមច្បាប់ទាក់ទងនឹងច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ត្រូវបន្តអានុភាពអនុវត្តរហូតមានបទដ្ឋានថ្មីមកជំនួស លើកលែងតែបទប្បញ្ញត្តិណាដែលផ្ទុយនឹងស្មារតីនៃច្បាប់នេះ ។

ធ្វើនៅព្រះបរមរាជវាំងថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១២

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកម/០១១២/០០១

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
ឧបនាយករដ្ឋមន្ត្រី ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
ហត្ថលេខា
កែ គឹមយ៉ាន

លេខ ០៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី
ទីស្តីការគណៈរដ្ឋមន្ត្រី
សយ សុខា

៧/៣

# មាតិកា

ទំព័រ


ជំពូកទី ១ បទប្បញ្ញត្តិទូទៅ ........ ១

មាត្រា ១.- គោលបំណងនៃច្បាប់នេះ ........ ១

មាត្រា ២.- គោលដៅនៃច្បាប់នេះ ........ ១

មាត្រា ៣.- វិសាលភាពនៃច្បាប់នេះ ........ ១

មាត្រា ៤.- និយមន័យ ........ ១

មាត្រា ៥.- ចំណាត់ថ្នាក់គ្រឿងញៀន ........ ៣

មាត្រា ៦.- ការកែប្រែចំណាត់ថ្នាក់ ........ ៤

ជំពូកទី ២ ស្ថាប័នប្រយុទ្ធប្រឆាំងគ្រឿងញៀន ........ ៤

ផ្នែកទី ១ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ........ ៤

មាត្រា ៧.- អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ........ ៤

ផ្នែកទី ២ មន្ទីរប្រឆាំងគ្រឿងញៀន ........ ៤

មាត្រា ៨.- តួនាទីមន្ទីរប្រឆាំងគ្រឿងញៀន ........ ៤

ផ្នែកទី ៣ ស្ថាប័នត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ........ ៥

មាត្រា ៩.- ការបង្កើតគណៈកម្មាធិការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ........ ៥

ជំពូកទី ៣ សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ........ ៥

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ ........ ៥

មាត្រា ១០.- សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ........ ៥

មាត្រា ១១.- លក្ខខណ្ឌនៃការចេញអាជ្ញាបណ្ណ ឬការអនុញ្ញាតស្តីពីគ្រឿងញៀន ........ ៥

មាត្រា ១២.- ការអនុញ្ញាតសម្រាប់ការសិក្សាស្រាវជ្រាវដោយប្រើប្រាស់គ្រឿងញៀន ........ ៦

មាត្រា ១៣.- លក្ខខណ្ឌនៃការអនុញ្ញាតឲ្យចែកចាយ ផ្គត់ផ្គង់ និងលក់ឱសថ ដែលមានសារធាតុញៀន ........ ៦


ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ផ្នែកទី ២ ស្ថាប័នមានសមត្ថកិច្ចក្នុងការចេញអាជ្ញាបណ្ណ ឬការអនុញ្ញាតទាក់ទងនឹងគ្រឿងញៀន ........ ៨
មាត្រា ១៤.- អាជ្ញាបណ្ណ ឬការអនុញ្ញាតសម្រាប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ១ ទី ២ និងទី ៣ ........ ៨
មាត្រា ១៥.- អាជ្ញាបណ្ណ ឬការអនុញ្ញាតសម្រាប់សកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ៤ ........ ៩
ផ្នែកទី ៣ ការត្រួតពិនិត្យសកម្មភាពស្របច្បាប់ទាក់ទងនឹងគ្រឿងញៀន ........ ៩
មាត្រា ១៦.- វិធានការត្រួតពិនិត្យផលិតផលលាយថ្នាំ ........ ៩
មាត្រា ១៧.- ការហាមឃាត់ការផ្សព្វផ្សាយពាណិជ្ជកម្ម ........ ៩
មាត្រា ១៨.- ការត្រួតពិនិត្យ ការឆ្លងកាត់ ឬការឃាត់សំចតនៃគ្រឿងញៀន ........ ១០
មាត្រា ១៩.- បទប្បញ្ញត្តិចំពោះសារធាតុគីមីថ្នាំក្នុងតារាងទី ៤ ........ ១០
មាត្រា ២០.- ព័ត៌មានដែលត្រូវរាយការណ៍ ........ ១១
មាត្រា ២១.- ការកំណត់បរិមាណនៃសេចក្តីត្រូវការនូវគ្រឿងញៀន ........ ១១
មាត្រា ២២.- កាតព្វកិច្ចក្នុងការចុះបញ្ជី ........ ១១
មាត្រា ២៣.- ការធ្វើបញ្ជីសារពើភណ្ឌ និងការគណនាសមតុល្យ ........ ១២
មាត្រា ២៤.- ការវេចខ្ចប់ និងការដាក់ស្លាកសញ្ញា ........ ១៣
មាត្រា ២៥.- ការត្រួតពិនិត្យ និងអធិការកិច្ច ........ ១៣
មាត្រា ២៦.- ការត្រួតពិនិត្យតាមដាននៅកំពង់ផែរួចពន្ធ និងតំបន់រួចពន្ធ ........ ១៤
ជំពូកទី ៤ បទប្បញ្ញត្តិព្រហ្មទណ្ឌ ........ ១៤
ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ ........ ១៤
មាត្រា ២៧.- ការអនុវត្តបទប្បញ្ញត្តិទូទៅនៃក្រមព្រហ្មទណ្ឌ ........ ១៤
មាត្រា ២៨.- ការប្រកាសមូលទោស ........ ១៤
មាត្រា ២៩.- និយមន័យនៃការប៉ុនប៉ង ........ ១៥
មាត្រា ៣០.- ការបង្ខំឲ្យទទួលការព្យាបាល ........ ១៥
មាត្រា ៣១.- ការលើកលែងឲ្យរួចផុតពីទោស ........ ១៥

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
ព្រះបរមរាជវាំង

មាត្រា ៣២.- ការសម្រាលទោស ........ ១៥

មាត្រា ៣៣.- ការអនុវត្តស្ថានសម្រាលទោស ........ ១៦

មាត្រា ៣៤.- ទោសបន្ថែមសម្រាប់រូបវន្តបុគ្គល ........ ១៦

មាត្រា ៣៥.- ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ........ ១៧

មាត្រា ៣៦.- មូលទោសអនុវត្តចំពោះនីតិបុគ្គល ........ ១៧

មាត្រា ៣៧.- ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល ........ ១៧

ផ្នែកទី ២ បទល្មើសទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ១ និងតារាងទី ២ ........ ១៧

មាត្រា ៣៨.- បទដាំដោយខុសច្បាប់នូវរុក្ខជាតិញៀន ........ ១៧

មាត្រា ៣៩.- បទផលិតដោយខុសច្បាប់នូវសារធាតុញៀន ........ ១៨

មាត្រា ៤០.- បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ........ ២០

មាត្រា ៤១.- បទរឹបយកសារធាតុញៀន ........ ២៣

មាត្រា ៤២.- បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ........ ២៤

មាត្រា ៤៣.- បទបង្ខំ អូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ........ ២៥

មាត្រា ៤៤.- បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ........ ២៦

មាត្រា ៤៥.- បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ........ ២៧

ផ្នែកទី ៣ បទល្មើសទាក់ទងនឹងគ្រឿងញៀនក្នុងតារាងទី ៣ ........ ២៧

មាត្រា ៤៦.- បទដាំដោយខុសច្បាប់នូវរុក្ខជាតិញៀន ........ ២៧

មាត្រា ៤៧.- បទផលិតដោយខុសច្បាប់នូវសារធាតុញៀន ........ ២៨

មាត្រា ៤៨.- បទរក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ........ ២៩

មាត្រា ៤៩.- បទរឹបយកសារធាតុញៀន ........ ៣០

មាត្រា ៥០.- បទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ........ ៣១


ROYAUME DU CAMBODGE
ព្រះបរមរាជវាំង
LE MINISTRE DU PALAIS ROYAL

មាត្រា ៥១.- បទបង្ខំ អូសទាញអ្នកដទៃឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ....... ៣២

មាត្រា ៥២.- បទសម្រួលឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ....... ៣៣

មាត្រា ៥៣.- បទប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ....... ៣៤

ផ្នែកទី ៤ បទល្មើសទាក់ទងនឹងសារធាតុគីមីផ្សំក្នុងតារាងទី ៤ ....... ៣៤

មាត្រា ៥៤.- បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរដោយខុសច្បាប់នូវសារធាតុគីមីផ្សំ ....... ៣៤

មាត្រា ៥៥.- បទផ្តល់ឲ្យអនីតិជនហិត ស្រូបនូវសារធាតុគីមីផ្សំ ជាអាទិ៍ ....... ៣៥

ផ្នែកទី ៥ បទល្មើសទាក់ទងនឹងបរិក្ខារ និងសម្ភារៈ ....... ៣៦

មាត្រា ៥៦.- បទផលិត រក្សាទុក ដឹកជញ្ជូន ឬជួញដូរបរិក្ខារ ឬសម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការផលិត ឬការប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ....... ៣៦

ផ្នែកទី ៦ បទល្មើសទាក់ទងនឹងការញុះញង់ ....... ៣៦៦

មាត្រា ៥៧.- បទញុះញង់ឲ្យប្រព្រឹត្តបទល្មើស ....... ៣៦

ផ្នែកទី ៧ បទល្មើសផ្សេងទៀត ....... ៣៧

មាត្រា ៥៨.- បទទទួលផលបទល្មើស ....... ៣៧

មាត្រា ៥៩.- បទចូលរួមក្នុងក្រុមឧក្រិដ្ឋជន ....... ៣៨

មាត្រា ៦០.- ការផ្តន្ទាទោសចំពោះមេដឹកនាំក្រុមឧក្រិដ្ឋជន ....... ៣៨

មាត្រា ៦១.- បទប្រឆាំងនឹងវិធានការឆែកឆេរសរីរាង្គ ....... ៣៨

មាត្រា ៦២.- បទបំពានលើបទប្បញ្ញត្តិ ឬបទបញ្ជាស្តីពីការគ្រប់គ្រង ការប្រើប្រាស់ឱសថដែលមានសារធាតុញៀន សារធាតុញៀន ឬសារធាតុគីមីផ្សំ... ៣៩

មាត្រា ៦៣.- បទបើកបរក្រោមឥទ្ធិពលនៃគ្រឿងញៀន ....... ៣៩

មាត្រា ៦៤.- បទបំពានលើការសម្ងាត់នៃវិធានការតាមដាន ....... ៤០

មាត្រា ៦៥.- បទរាំងការធ្វើអធិការកិច្ច ....... ៤០

មាត្រា ៦៦.- បទបំពានវិធានការបណ្តោះអាសន្នសម្រាប់ធានាការរឹបអូស ....... ៤០


ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ៦៧.- បទមិនគោរពការរឹបអូស ............ ៤១

មាត្រា ៦៨.- បទគេចវេះពីភាតព្វកិច្ចព្យាបាលដោយបង្ខំ ............ ៤១

ផ្នែកទី ៤ បទប្បញ្ញត្តិស្តីពីការសំអាតប្រាក់ទាក់ទងនឹងបទល្មើសគ្រឿងញៀន .... ៤១

មាត្រា ៦៩.- បទប្បញ្ញត្តិទូទៅ ............ ៤១

មាត្រា ៧០.- និយមន័យនៃការសំអាតប្រាក់ ............ ៤១

មាត្រា ៧១.- បទសំអាតប្រាក់ ............ ៤២

មាត្រា ៧២.- ស្ថានទម្ងន់ទោស ............ ៤២

ជំពូកទី ៥ បទប្បញ្ញត្តិស្តីពីនីតិវិធីព្រហ្មទណ្ឌ ............ ៤៣

ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ ............ ៤៣

មាត្រា ៧៣.- ការអនុវត្តបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ............ ៤៣

មាត្រា ៧៤.- ការចូលរួមក្នុងនីតិវិធី ............ ៤៣

ផ្នែកទី ២ វិធានការស៊ើបអង្កេត និងស៊ើបសួរ ............ ៤៣

មាត្រា ៧៥.- ការឆែកឆេរនៅតាមព្រំដែន ............ ៤៣

មាត្រា ៧៦.- ការឆែកឆេរសរីរាង្គដោយប្រើបច្ចេកទេសស្វែងរកតាមវេជ្ជសាស្ត្រ.. ៤៤

មាត្រា ៧៧.- ការត្រួតពិនិត្យក្នុងសេវាប្រៃសណីយ៍ ............ ៤៤

មាត្រា ៧៨.- ការឃ្លាំមើលការឆ្លងកាត់ ............ ៤៤

មាត្រា ៧៩.- ការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឲ្យលក់គ្រឿងញៀន ............ ៤៥

មាត្រា ៨០.- ការត្រួតពិនិត្យប្រតិបត្តិការឃ្លាំមើល ............ ៤៦

មាត្រា ៨១.- ការបិទស្លាក និងការថែរក្សាវត្ថុតាង ............ ៤៦

មាត្រា ៨២.- ការដកយកវត្ថុដែលសង្ស័យថាជាគ្រឿងញៀនសម្រាប់ធ្វើកោសលវិច័យ ............ ៤៧

មាត្រា ៨៣.- កោសលវិច័យតាមបច្ចេកទេសវិទ្យាសាស្ត្រ ............ ៤៧

មាត្រា ៨៤.- ការប្រគល់ ការបំផ្លាញចោលនូវគ្រឿងញៀនដែលបានចាប់យក.. ៤៨

មាត្រា ៨៥.- ការតាមដាន ............ ៤៨

មាត្រា ៨៦.- ការសម្ងាត់ធនាគារ ......... ៤៩
មាត្រា ៨៧.- ការបិទគ្រឹះស្ថាន ការហាមឃាត់អាជីវកម្មលើគ្រឹះស្ថានជាបណ្តោះអាសន្ន ......... ៤៩
ផ្នែកទី ៣ វិធានការបណ្តោះអាសន្នសម្រាប់ធានាការរឹបអូស ......... ៥០
មាត្រា ៨៨.- វិធានការបន្ទាន់សម្រាប់ធានាការរឹបអូស ......... ៥០
មាត្រា ៨៩.- ការឃាត់ទុកទ្រព្យសម្បត្តិ ......... ៥០
មាត្រា ៩០.- ការបង្កកទ្រព្យសម្បត្តិ ......... ៥០
មាត្រា ៩១.- ទ្រព្យបញ្ចូលគ្នា ......... ៥០
មាត្រា ៩២.- បណ្តឹងរបស់ជនប្រឆាំងនឹងសេចក្តីសម្រេច ......... ៥១
ផ្នែកទី ៤ វិធានការរឹបអូស ......... ៥១
មាត្រា ៩៣.- ការរឹបអូសដាច់ខាត ......... ៥១
មាត្រា ៩៤.- ការរឹបអូសវត្ថុ ជាអាទិ៍ ......... ៥១
មាត្រា ៩៥.- បណ្តឹងរបស់ជនប្រឆាំងនឹងសេចក្តីសម្រេចរឹបអូស ......... ៥២
មាត្រា ៩៦.- ការរឹបអូសទ្រព្យសម្បត្តិ ជាអាទិ៍ ......... ៥២
មាត្រា ៩៧.- ការលក់ដោយរដ្ឋនូវ វត្ថុ ឬទ្រព្យសម្បត្តិរឹបអូស ......... ៥៣
មាត្រា ៩៨.- បណ្តឹងចំពោះសេចក្តីសម្រេចស្តាពរទាក់ទងនឹងការរឹបអូសទ្រព្យសម្បត្តិ ជាអាទិ៍ ......... ៥៣
មាត្រា ៩៩.- ការទុកជាមោឃៈនូវអំពើទាំងឡាយ ដែលប៉ុនប៉ងបង្កើតឧបសគ្គដល់ការបង្កក ឬការរឹបអូស ......... ៥៤
ជំពូកទី ៦ វិធានការព្យាបាល និងស្តារនីតិសម្បទា ......... ៥៤
ផ្នែកទី ១ បទប្បញ្ញត្តិទូទៅ ......... ៥៤
មាត្រា ១០០.- ភារកិច្ចរបស់រដ្ឋក្នុងការផ្តល់សេវាព្យាបាល និងស្តារនីតិសម្បទា. ៥៤
មាត្រា ១០១.-គោលការណ៍នៃការព្យាបាល និងការស្តារនីតិសម្បទា ......... ៥៥
មាត្រា ១០២.-វិធាននៃការគ្រប់គ្រងការព្យាបាល និងការស្តារនីតិសម្បទា ..... ៥៥
មាត្រា ១០៣.-ការសម្ងាត់នៃការព្យាបាល និងការស្តារនីតិសម្បទា ......... ៥៦

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ផ្នែកទី ២ ការព្យាបាល និងការស្តារនីតិសម្បទាដោយស្ម័គ្រចិត្ត ........................ ៥៧

មាត្រា ១០៤.- ការព្យាបាល និងការស្តារនីតិសម្បទាដោយស្ម័គ្រចិត្ត ........................ ៥៧

ផ្នែកទី ៣ លក្ខខណ្ឌនៃការចោទប្រកាន់ និងការអនុវត្តទោសចំពោះអ្នកញៀនគ្រឿងញៀន ........................ ៥៨

មាត្រា ១០៥.- លក្ខខណ្ឌនៃការចោទប្រកាន់អ្នកញៀនគ្រឿងញៀន ........................ ៥៨

មាត្រា ១០៦.- លក្ខខណ្ឌនៃការអនុវត្តទោសចំពោះអ្នកញៀនគ្រឿងញៀន ........ ៥៨

ផ្នែកទី ៤ ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ ........................ ៥៩

មាត្រា ១០៧.- លក្ខខណ្ឌទូទៅនៃការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំ .. ៥៩

មាត្រា ១០៨.- ការព្យាបាល និងការស្តារនីតិសម្បទាដោយបង្ខំបង្គាប់ដោយព្រះរាជអាជ្ញា ........................ ៥៩

មាត្រា ១០៩.- ការបង្ខំឲ្យព្យាបាល និងស្តារនីតិសម្បទានៅក្នុងដំណាក់កាលស៊ើបសួរ និងដំណាក់កាលជំនុំជម្រះ ........................ ៦០

មាត្រា ១១០.- មូលដ្ឋានដោយឡែកនៃការកំណត់ទោស ........................ ៦១

ជំពូកទី ៧ បត្យាប័ន និងការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ........................ ៦១

ផ្នែកទី ១ បត្យាប័ន ........................ ៦១

មាត្រា ១១១.- បត្យាប័ននៃអាណិកជនបរទេសលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ........................ ៦១

មាត្រា ១១២.- បទប្បញ្ញត្តិគ្រប់គ្រងការធ្វើបត្យាប័នចំពោះបទល្មើសទាក់ទងនឹងគ្រឿងញៀន ........................ ៦១

មាត្រា ១១៣.- ការឆ្លងកាត់ ........................ ៦២

ផ្នែកទី ២ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ........................ ៦២

មាត្រា ១១៤.- សំណើរបស់រដ្ឋបរទេសចំពោះព្រះរាជាណាចក្រកម្ពុជា ដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬចំណាត់ការតុលាការនៅក្នុងរដ្ឋបរទេស ..... ៦២

មាត្រា ១១៥.- ជំនួយអាចត្រូវផ្តល់ជូនដោយផ្អែកលើលក្ខខណ្ឌ ........................ ៦៤

មាត្រា ១១៦.- មូលហេតុចាំបាច់សម្រាប់ការបដិសេធសំណើសុំជំនួយ ........................ ៦៤

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

មាត្រា ១១៧.- វិធាននៃការសម្ងាត់ធនាគារ ............ ៦៤

មាត្រា ១១៨.- សំណើសុំផ្តល់ភស្តុតាងក្នុងតុលាការនៅក្នុងរដ្ឋបរទេស ............ ៦៥

មាត្រា ១១៩.- សំណើដោយព្រះរាជាណាចក្រកម្ពុជា ចំពោះរដ្ឋបរទេសមួយដើម្បីសុំជំនួយក្នុងការស៊ើបអង្កេត ឬចំណាត់ការតុលាការ ............ ៦៦

មាត្រា ១២០.- សហប្រតិបត្តិការអន្តរជាតិ ............ ៦៧

ជំពូកទី ៨ អន្តរប្បញ្ញត្តិ ............ ៦៨

មាត្រា ១២១.- អន្តរប្បញ្ញត្តិស្តីពីអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ............ ៦៨

មាត្រា ១២២.- អន្តរប្បញ្ញត្តិស្តីពីអាជ្ញាបណ្ណ និងការអនុញ្ញាត ............ ៦៨

មាត្រា ១២៣.- អន្តរប្បញ្ញត្តិស្តីពីនីតិវិធី ............ ៦៨

មាត្រា ១២៤.- អន្តរប្បញ្ញត្តិស្តីពីបទល្មើស ............ ៦៨

ជំពូកទី ៩ អវសានប្បញ្ញត្តិ ............ ៦៩

មាត្រា ១២៥.- និរាករណ៍នៃបទប្បញ្ញត្តិ និងករណីលើកលែង ............ ៦៩


ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# តារាងឧបសម្ព័ន្ធ
# ថ្នាំញៀន និងសារធាតុមានឥទ្ធិពលលើប្រព័ន្ធសរសៃប្រសាទ និងសារធាតុសម្រាប់ផលិតគ្រឿងញៀន

List of Narcotic Drugs, Psychotropic Substances, and Substances used for drug manufacturing

**ក្នុងបញ្ជីនេះមាន** :

- សារធាតុខាងក្រោមនេះមានឈ្មោះរួមអន្តរជាតិ ឬឈ្មោះដែលប្រើក្នុងអនុសញ្ញាអន្តរជាតិជាធរមាន
- អ៊ីហ្សូមែរ (isomère) ក្នុងគ្រប់ករណីដែលអាចស្របនឹងរូបមន្តគីមីជាសារវន្តនៃសារធាតុទាំងនោះ លើកលែងតែមានអញ្ញត្រកម្មច្បាស់លាស់
- អេស្ទែរ (esters) និងអេទែរ (éthers) នៃសារធាតុទាំងនោះក្នុងគ្រប់ករណីទាំងអស់ដែលអាចមាន
- អំបិលនៃសារធាតុទាំងនេះ រួមទាំងអំបិលរបស់អេស្ទែរ (esters) អំបិលអេទែរ (ethers) និងអំបិលអ៊ីហ្សូមែរ (isomère) ក្នុងគ្រប់ករណីទាំងអស់ដែលអាចមាន
- ការរៀបចំផ្សំធ្វើសារធាតុទាំងនោះ លើកលែងតែមានអញ្ញត្រកម្មដូចមានចែងក្នុងច្បាប់នេះ
- ការរកឃើញសារធាតុថ្មីដោយក្រុមអ្នកបច្ចេកទេសវិទ្យាសាស្ត្រពាក់ព័ន្ធគ្រឿងញៀននៅព្រះរាជាណាចក្រកម្ពុជា ។

**តារាងទី ១** Table I

| **ភាសាខ្មែរ**<br>Khmer Language | **ភាសាបារាំង**<br>France Language | **ភាសាអង់គ្លេសបែបអាមេរិកកាំង**<br>English Language |
|---|---|---|
| អាសេទ័រហ្វីន | ( Acétorphine ) | ( Acetorphine ) |
| កញ្ឆា ជ័រកញ្ឆា ប្រេងកញ្ឆា និងគ្រាប់កញ្ឆា | ( Cannabis, résine de cannabis, huile de cannabis et Grain de cannabis ) | ( Cannabis, cannabis resin, cannabis oil and cannabis seed ) |
| សេតូបេមីដូន | ( Cétobémidone ) | ( Ketobemidone ) |
| ដេហ្សូម័រហ្វីន | ( Désomorphine ) | ( Desomorphine ) |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| អេទ័រហ្វីន | ( Etorphine ) | ( Etorphin ) |
| ហេរ៉ូអ៊ីន | ( Héroïne ) | ( Heroin ) |
| អាសេទីល-អាល់ហ្វា-មេទីល ហ្វង់តានីល | ( Acétyl-alpha-méthylfentanyl ) | ( Acelty-alpha-methylfentanyl ) |
| អាល់ហ្វាសេទីលមេតាដុល | ( Alphacétylméthadol ) | ( Alphacetylmethadol ) |
| អាល់ហ្វា-មេទីលហ្វង់តានីល | ( Alpha-méthylfentanyl ) | ( Alpha-methylfentanyl ) |
| បែតា-អ៊ីដ្រុកស៊ីហ្វង់តានីល | ( Bêta-hydroxyfentanyl ) | ( Beta-hydroxyfentanyl ) |
| បែតា-អ៊ីដ្រុកស៊ីមេទីល-៣-ហ្វង់តានីល | ( Bêta-hydroxyméthyl-3-fentanyl) | ( Beta-hydroxymethyl-3-fentanyl ) |
| មេទីល-៣-ហ្វង់តានីល | ( Méthyl-3-fentanyl ) | ( Methyl-3-fentanyl ) |
| មេទីល-៣-ត្យូហ្វង់តានីល | ( Méthyl-3-thiofentanyl ) | ( Methyl-3-thiofentanyl ) |
| អឹម ប៉េ ប៉េ ប៉េ | ( MPPP ) | ( MPPP ) |
| ប៉ារ៉ា-ហ្លុយអ័រ៉ូហ្វង់តានីល | ( Para-fluorofentanyl ) | ( Para-fluorofentanyl ) |
| ប៉េ អឺ ប៉េ អា ប៉េ | ( PEPAP ) | ( PEPAP ) |
| ត្យូហ្វង់តានីល | ( Thiofentanyl) | ( Thiofentanyl) |
| ប្រ៊ោឡាំហ្វេតាមីន | ( Brolamfétamine ) | ( Brolamfetamine ) |
| កាទីណូន | ( Cathinone ) | ( Cathinone ) |
| ដេ អឺ តេ | ( DET ) | ( DET ) |
| ដេ អឹម អា | ( DMA ) | ( DMA ) |
| ដេ អឹម ហាស់ ប៉េ | ( DMHP ) | ( DMHP ) |
| ដេ អឹម តេ | ( DMT ) | ( DMT ) |
| ដេ អូ អឺ តេ | ( DOET ) | ( DOET ) |
| អេទីស៊ីក្លីឌីន | ( Eticyclidine ) | ( Eticyclidine ) |
| លីហ្សែរហ្ស៊ីដ | ( Lysergide ) | ( Lysergide ) |
| អឹម ដេ អឹម អា | ( MDMA ) | ( MDMA ) |
| មេស្កាលីន | ( Mescaline ) | ( Mescaline ) |

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| មេទីល-៤-អាមីណូរិច | ( Méthyl-4-aminorex ) | ( 4-Methylaminorex ) |
| អឹម អឹម ដេ អា | ( MMDA ) | ( MMDA ) |
| អិន-អេទីល អឹម ដេ អា | ( N-éthyl MDA ) | ( N-Ethyl-MDA ) |
| អិន-អ៊ីដ្រុកស៊ី អឹម ដេ អា | ( N-hydroxy MDA ) | ( N-Hydroxy-MDA ) |
| ប៉ារ៉ាអ៊ិចហ្ស៊ីល | ( Parahexyl ) | ( Parahexyl ) |
| ប៉េ អឹម អា | ( PMA ) | ( PMA ) |
| ផ្ស៊ីឡូស៊ីន,ផ្ស៊ីឡូស៊ីន | ( Psilocine, Psilotsine ) | ( Psilocine, Psilotsin ) |
| ផ្ស៊ីឡូស៊ីប៊ីន | ( Psilocybine ) | ( Psilocybine ) |
| រ៉ូលីស៊ីគ្លីឌីន | ( Rolicyclidine ) | ( Rolicyclidine ) |
| អេស តេ ប៉េ | ( STP ) | ( STP ) |
| ដេ អូ អឹម | ( DOM ) | ( DOM ) |
| តេណំហ្វេតាមីន | ( Ténamfétamine ) | ( Tenamfetamine ) |
| តេណូស៊ីគ្លីឌីន | ( Ténocyclidine ) | ( Tenocyclidine ) |
| តេត្រាអ៊ីដ្រូកានណាប៊ីណុល | ( Tétrahydrocannabinol ) | ( Tetrahydrocannabinol ) |
| តេ អឹម អា | ( TMA ) | ( TMA ) |
| ៤-អឹម តេ អា | ( 4-MTA ) | ( 4-MTA ) |

**ភាគទី ២ Table II**

| **ភាសាខ្មែរ** Khmer Language | **ភាសាបារាំង** France Language | **ភាសាអង់គ្លេសបែប អាមេរិកាំង** English Language |
|---|---|---|
| អាសេទីលឌីអ៊ីដ្រូកូដេអ៊ីន | ( Acétyldihydrocodéine ) | ( Acetyldihydrocodeine ) |
| អាសេទីលមេតាដុល | ( Acétylméthadol ) | ( Acetylmethadol ) |
| អាល់ហ្វង់តានីល | ( Alfentanil ) | ( Alfentanil ) |
| អាល់លីប្រ៉ូឌីន | ( Allylprodine ) | ( Allylprodine ) |
| អាល់ហ្វាមេប្រ៉ូឌីន | ( Alphaméprodine ) | ( Alphameprodine ) |

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| អាល់ហ្វាមេតាដុល | ( Alphaméthadol ) | ( Alphamethadol ) |
| អាល់ហ្វា-មេទីលត្យូហ្វង់តានីល | ( Alpha-méthylthiofentanyl ) | ( Alpha-methylthiofentanyl ) |
| អាល់ហ្វាប្រ៉ូឌីន | ( Alphaprodine ) | ( Alphaprodine ) |
| អានីឡេរីឌីន | ( Aniléridine ) | ( Anileridine ) |
| បង់ហ្សេទីឌីន | ( Benzéthidine ) | ( Benzethidine ) |
| បង់ហ្ស៊ីលម័រហ្វីន | ( Benzylmorphine ) | ( Benzylmorphine ) |
| បេតាសេទីលមេតាដុល | ( Bétacétylméthadol ) | ( Betacetylmethadol ) |
| បេតាមេប្រ៉ូឌីន | ( Bétaméprodine ) | ( Betameprodine ) |
| បេតាមេតាដូន | ( Bétaméthadone ) | ( Betamethadone ) |
| បេតាប្រ៉ូឌីន | ( Bétaprodine ) | ( Betaprodine ) |
| បេហ្ស៊ីត្រាមីដ | ( Bézitramide ) | ( Bezitramide ) |
| ប៊ុយទីរ៉ាត ដឺ ឌីអុកសាហ្វេទីល | ( Butyrate de dioxaphétyl ) | ( Dioxaphetyl butyrate ) |
| ក្លូនីតាហ្សែន | ( Clonitazène ) | ( Clonitazene ) |
| ស្លឹកកូកា | ( [ feuille de Coca ] ) | ( Coca leaf ) |
| កូកាអ៊ីន | ( Cocaïne ) | ( Cocaine ) |
| កូដេអ៊ីន | ( Codéine ) | ( Codeine ) |
| កូដុកស៊ីម | ( Codoxime ) | ( Codoxime ) |
| ទឹកកំហាប់ដើមអាភៀន (រុក្ខជាតិអាភៀនក្រៀម) | ( Concentré de paille de pavot ) | ( Concentrate of poppy straw ) |
| ដិចស្ត្រូម៉ូរ៉ាមីដ | ( Dextromoramide ) | ( Dextromoramide ) |
| ដិចស្ត្រូប្រ៉ូប៉ុកស៊ីហ្វែន | ( Dextropropoxyphène ) | ( Dextropropoxyphene ) |
| ឌីអំប្រ៉ូមីដ | ( Diampromide ) | ( Diampromide ) |
| ឌីអេទីលទីត្យាំប៊ុយទែន | ( Diéthylthiambutène ) | ( Diethylthiambutene ) |
| ឌីហ្វេណុកស៊ីន | ( Difénoxine ) | ( Difenoxin ) |
| ឌីអ៊ីដ្រូកូដេអ៊ីន | ( Dihydrocodéine ) | ( Dihydrocodeine ) |
| ឌីអ៊ីដ្រូម័រហ្វីន | ( Dihydromorphine ) | ( Dihydromorphine ) |

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

| | | |
|---|---|---|
| ឌីមេណុកសាដុល | ( Diménoxadol ) | ( Dimenoxadol ) |
| ឌីមេហ្វេបតានណុល | ( Dimépheptannol ) | ( Dimepheptannol ) |
| ឌីមេទីលទីត្យាំប៊ុយតែន | ( Diméthylthiambutène ) | ( Dimethylthiambutene ) |
| ឌីហ្វេណុកស៊ីឡាត | ( Diphénoxylate ) | ( Diphenoxylate ) |
| ឌីពីប៉ាណូន | ( Dipipanone ) | ( Dipipanone ) |
| ដ្រូតេបាណុល | ( Drotébanol ) | ( Drotebanol ) |
| អិកហ្គូនីន, ជាតុក្លាយពីអេស្ទែរ របស់វា | ( Ecgonine, ses esthers dérivés ) | ( Ecgonine, and it derivative of esters ) |
| អេទីលមេទីលត្យាំប៊ុយតែន | ( Ethylméthylthiambutène ) | ( Ethylmethylthiambutene ) |
| អេទីលម័រហ្វីន | ( Ethylmorphine ) | ( Ethylmorphine ) |
| អេតូនីតាហ្សែន | ( Etonitazène ) | ( Etonitazene ) |
| អេតូហ្សេរីឌីន | ( Etozéridine ) | ( Etozeridine ) |
| ហ្វង់តានីល | ( Fentanyl ) | ( Fentanyl ) |
| ហ្វុយរ៉េទីឌីន | ( Furéthidine ) | ( Furethidine ) |
| អ៊ីដ្រូកូដូន | ( Hydrocodone ) | ( Hydrocodone ) |
| អ៊ីដ្រូម័រហ្វីណុល | ( Hydromorphinol ) | ( Hydromorphinol ) |
| អ៊ីដ្រូម័រហ្វូន | ( Hydromorphone ) | ( Hydromorphone ) |
| អ៊ីដ្រុកស៊ីប៉េទីឌីន | ( Hydroxypéthidine ) | ( Hydroxypethidine ) |
| អ៊ីហ្សូមេតាដូន | ( Isométhadone ) | ( Isomethadone ) |
| ឡេវ៉ូមេទ័រហ្វាន | ( Lévométhorphane ) | ( Levomethorphane ) |
| ឡេវ៉ូម៉ូរ៉ាមីដ | ( Lévomoramide ) | ( Levomoramide ) |
| ឡេវ៉ូហ្វេណាស៊ីលម័រហ្វាន | ( Lévophénacylmorphane ) | ( Levophenacylmorphane ) |
| ឡេវ៉ហ្វាណុល | ( Lévorphanol ) | ( Levorphanol ) |
| មេតាហ្សូស៊ីន | ( Métazocine ) | ( Metazocine ) |
| មេតាដូន | ( Méthadone ) | ( Methadone ) |
| (មេតាដូន, អ[illegible]ឡា [[illegible]យ៉ាណូ-៤ ឌីមេទីឡាមីណូ-២ ឌីហ្វេនីល-៤, ៤ប៊ុយតាន] ) | | |

| | | |
|---|---|---|
| ( Méthadone, intermédiaire de la [ cyano-4 diméthylamino-2 diphény1-4,4 butane ] )<br>( Methadone, intermediate [4-cyano-2-dimethylamino-4,4-diphenylbutane ] ) | | |
| មេទីលដេហ្សូរហ្វីន | ( Méthyldésorphine ) | ( Methyldesorphine ) |
| មេទីលឌីអ៊ីដ្រូម័រហ្វីន | ( Méthyldihydromorphine ) | ( Methyldihydromorphine ) |
| មេតូប៉ុង | ( Métopon ) | ( Metopon ) |
| ម៉ូរ៉ាមីដ | ( Moramide ) | ( Moramide ) |
| ម័រហ្វេរីឌីន | ( Morphéridine ) | ( Morpheridine ) |
| ម័រហ្វីន | ( Morphine ) | ( Morphine ) |
| ម័រហ្វីននមេតូប្រ៉ូមីដ និងជាតុក្លាយពីម័រហ្វីននឯទៀតដែលមាន អាហ្សូត ប៉ង់តាវ៉ាឡង់<br>( Morphine méthobromide et autres dérivés morphiniques à azote pentavalent )<br>( Morphine methobromide and others derivative of morphine azotes pentavalent ) | | |
| មីរ៉ូហ្វីន | ( Myrophine ) | ( Myrophine ) |
| នីកូកូឌីន | ( Nicocodine ) | ( Nicocodine ) |
| នីកូឌីកូឌីន | ( Nicodicodine ) | ( Nicodicodine ) |
| នីកូម័រហ្វីន | ( Nicomorphine ) | ( Nicomorphine ) |
| ណូរ៉ាស៊ីមេតាដុល | ( Noracyméthadol ) | ( Noracymethadol ) |
| ន័រកូដេអ៊ីន | ( Norcodéine ) | ( Norcodeine ) |
| ន័រឡេវ៉ហ្វាណុល | ( Norlévorphanol ) | ( Norlevorphanol ) |
| ន័រមេតាដូន | ( Norméthadone ) | ( Normethadone ) |
| ន័រម័រហ្វីន | ( Normorphine ) | ( Normorphine ) |
| ន័រពីប៉ាណូន | ( Norpipanone ) | ( Norpipanone ) |
| អិន-អុកស៊ីម័រហ្វីន | ( N-oxymorphine ) | ( N-Oxymorphine ) |
| អាភៀន | ( Opium ) | ( Opium ) |
| អុកស៊ីកូដូន | ( Oxycodone ) | ( Oxycodone ) |
| អុកស៊ីម័រហ្វូន | ( Oxymorphone ) | ( Oxymorphone ) |
| ប៉េទីឌីន | ( Péthidine ) | ( Pethidine ) |
| ( ប៉េទីឌីន, [illegible] ដីឡូ[illegible]ស៊ីយ៉ាណូ-៤ មេទីល-១ ហ្វេនីល-៤ ពីប៉េរីឌីន ]) | | |

| | | |
|---|---|---|
| ( Péthidine, intermédiaire A de la [ cyano-4 méthyl-1 phényl-4 pipéridine ] )<br>( Pethidine, intermediaite A [4-Cyano-1-methyl-4-phenylpiperidine ] ) | | |
| (ប៉េទីឌីន, អាំងទែរមេដ្យែ បេ ជឺឡា [ អេស្ទែរអេទីលិក ជឺឡាស៊ីតហ្វេនីល-៤ ពីប៉េរីឌីនកាបុកស៊ីលិក-៤] )<br>( Péthidine, intermédiaire B de la [ ester éthylique de l'acide phényl-4 pipéridine carboxylique-4 ] )<br>( Pethidine, intermediate B [4-phenylpiperidine-4-carboxylic acid ethyl ester ] ) | | |
| (ប៉េទីឌីន, អាំងទែរមេដ្យែ សេ ជឺឡា [អាស៊ីដមេទីល-១ ហ្វេនីល-៤ ពីប៉េរីឌីន កាបុកស៊ីលិក-៤] )<br>( Péthidine, intermédiaire C de la [ acide méthyl-1 phényl-4 pipéridine carboxylique-4] )<br>( Pethidine, intermediate C [1-methyl-4-phenylpiperidine-4-carboxylic acid] ) | | |
| ហ្វេណំប្រ៉ូមីដ | ( Phénampromide ) | ( Phenampromide ) |
| ហ្វេណាដុកសូន | ( Phénadoxone ) | ( Phenadoxone ) |
| ហ្វេណាហ្សូស៊ីន | ( Phénazocine ) | ( Phenazocine ) |
| ហ្វេណូប៉េរីឌីន | ( Phénopéridine ) | ( Phenoperidine ) |
| ហ្វុលកូឌីន | ( Pholcodine ) | ( Pholcodine ) |
| ពីមីណូឌីន | ( Piminodine ) | ( Piminodine ) |
| ពីរីត្រាមីដ | ( Piritramide ) | ( Piritramide ) |
| ប្រ៉ូអឹបតាហ្ស៊ីន | ( Proheptazine ) | ( Proheptazine ) |
| ប្រ៉ូប៉េរីឌីន | ( Propéridine ) | ( Properidine ) |
| ប្រ៉ូពីរ៉ាម | ( Propiram ) | ( Propiram ) |
| រ៉ាសេមេទ័រហ្វាន | ( Racéméthorphane ) | ( Racemethorphane ) |
| រ៉ាសេម័រ៉ាមីដ | ( Racémoramide ) | ( Racemoramide ) |
| រ៉ាសេម័រហ្វាន | ( Racémorphane ) | ( Racemorphane ) |
| ស៊ុយហ្វង់តានីល | ( Sufentanil ) | ( Sufentanil ) |
| តេបាកូន | ( Thébacone ) | ( Thebacone) |
| តេបាអ៊ីន | ( Thébaïne ) | ( Thebaine ) |
| ទីលីឌីន | ( Tilidine ) | ( Tilidine ) |
| ទ្រីមេប៉េរីឌីន | ( Triméperidine ) | ( Trimeperidine ) |
| អំហ្វេតាមីន | ( Amfétamine ) | ( Amfetamine ) |
| ដិចហ្សំហ្វេតាមីន | ( Dexamfétamine ) | ( Dexamfetamine ) |
| ហ្វេណេទីលលីន | ( Fénétylline ) | ( Fenetylline ) |
| ឡេវំហ្វេតាមីន | ( Levamfétamine ) | ( Levamfetamine ) |

| | | |
|---|---|---|
| មេក្លូកកឺឡូន | ( Mécloquelone ) | ( Mecloquelone ) |
| មេតំហ្វេតាមីន | ( Métamfétamine ) | ( Metamfetamine ) |
| មេតាកាឡូន | ( Méthaqualone ) | ( Methaqualone ) |
| មេទីលហ្វេនីដាត | ( Méthylphénidate ) | ( Methylphenidate ) |
| ហ្វង់ស៊ីក្លីឌីន | ( Phencyclidine ) | ( Phencyclidine ) |
| ហ្វង់មេត្រាហ្ស៊ីន | ( Phenmétrazine ) | ( Phenmetrazine ) |
| រ៉ាសេម៉ាត ដឺ មេតំហ្វេតាមីន | ( Racémate de Métamfétamine ) | ( Metamfetamine Racemate ) |
| សេកូបារប៊ីតាល់ | ( Sécobarbital ) | ( Secobarbital ) |
| ២ សេ-បេ | ( 2-CB ) | ( 2 C-B ) |

**តារាងទី ៣ Table III**

| ភាសាខ្មែរ<br>Khmer Language | ភាសាបារាំង<br>France Language | ភាសាអង់គ្លេសបែប<br>អាមេរិកកាំង<br>English Language |
|---|---|---|
| អាម៉ូបារប៊ីតាល់ | ( Amobarbital ) | ( Amobarbital ) |
| ប៊ុយប្រេន័រហ្វីន | ( Buprénorphine ) | ( Buprenorphine ) |
| ប៊ុយតាល់ប៊ីតាល់ | ( Butalbital ) | ( Butalbital ) |
| កាទីន | ( Cathine ) | ( Cathine ) |
| ស៊ីក្លូបារប៊ីតាល់ | ( Cyclobarbital ) | ( Cyclobarbital ) |
| គ្លុយតេទីមីដ | ( Glutéthimide ) | ( Glutethimide ) |
| ប៉ង់តាហ្សូស៊ីន | ( Pentazocine ) | ( Pentazocine ) |
| ប៉ង់តូបារប៊ីតាល់ | ( Pentobarbital ) | ( Pentobarbital ) |
| អាល់ឡូបារប៊ីតាល់ | ( Allobarbital ) | ( Allobarbital ) |
| អាល់ប្រ៉ាហ្សូឡាំ | ( Alprazolam ) | ( Alprazolam ) |
| អំហ្វេប្រ៉ាម៉ូន | ( Amfépramone ) | ( Amfepramone ) |
| បារប៊ីតាល់ | ( Barbital ) | ( Barbital ) |

| | | |
|---|---|---|
| បង់ហ្សហ្វេតាមីន | ( Banzfétamine ) | ( Banzphetamine ) |
| ប្រោម៉ាហ្សេប៉ាម | ( Bromazépam ) | ( Bromazepam ) |
| ប៊ុយតូបារប៊ីតាល់ | ( Butobarbital ) | ( Butobarbital ) |
| កាម៉ាហ្សេប៉ាម | ( Camazépam ) | ( Camazepam ) |
| ក្ល័រឌីយ៉ាហ្សេប៉ុកស៊ីដ | ( Chlordiazépoxide ) | ( Chlordiazepoxide ) |
| ក្លូបាហ្សាំ | ( Clobazam ) | ( Clobazam ) |
| ក្លូណាហ្សេប៉ាម | ( Clonazépam ) | ( Clonazepam ) |
| ក្លូរ៉ាហ្សេប៉ាត | ( Clorazépate ) | ( Clorazepate ) |
| ក្លូត្យាហ្សេប៉ាម | ( Clotiazépam ) | ( Clotiazepam ) |
| ក្លុកសាហ្សូឡាំ | ( Cloxazolam ) | ( Cloxazolam ) |
| ដេឡូរ៉ាហ្សេប៉ាម | ( Délorazépam ) | ( Delorazepam ) |
| ឌីយ៉ាហ្សេប៉ាម | ( Diazépam ) | ( Diazepam ) |
| អេស្តាហ្សូឡាំ | ( Estazolam ) | ( Estazolam ) |
| អេតក្ល័រវីណុល | ( Ethchlorvynol ) | ( Ethchlorvynol ) |
| អេទីណាម៉ាត | ( Ethinamate ) | ( Ethinamate ) |
| អិន-អេទីលអំហ្វេតាមីន | ( N-éthylamfétamine ) | ( N-ethylamphetamine ) |
| ហ្វង់កាំហ្វាមីន | ( Fencamfarmine ) | ( Fencamfamine ) |
| ហ្វង់ប្រ៉ូប៉ូរ៉ិច | ( Fenproporex ) | ( Fenproporex ) |
| ហ្វ្លុយឌីយ៉ាហ្សេប៉ាម | ( Fludiazépam ) | ( Fludiazepam ) |
| ហ្វ្លុយនីត្រាហ្សេប៉ាម | ( Flunitrazépam ) | ( Flunitrazepam ) |
| ហ្វ្លុយរ៉ាហ្សេប៉ាម | ( Flurazépam ) | ( Flurazepam ) |
| អាឡាហ្សេប៉ាម | ( Halazépam ) | ( Halazepam ) |
| អាឡុកសាហ្សូឡាំ | ( Haloxazolam ) | ( Haloxazolam ) |
| កេតាហ្សូឡាំ | ( Kétazolam ) | ( Ketazolam ) |
| ឡេហ្វេតាមីន | ( Léfétamine ) | ( Lefetamine ) |
| ឡូហ្វ្លាហ្សេប៉ាតអេទីល | ( Loflazépate d'Ethyle ) | ( Ethyl Loflazepate ) |

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL

| | | |
|---|---|---|
| ឡូប្រ៉ាហ្សូឡាំ | ( Loprazolam ) | ( Loprazolam ) |
| ឡូរ៉ាហ្សៀប៉ាម | ( Lorazépam ) | ( Lorazepam ) |
| ឡូមេតាហ្សៀប៉ាម | ( Lométazépam ) | ( Lometazepam ) |
| ម៉ាហ្សាំងដុល | ( Mazindol ) | ( Mazindol ) |
| មេដាហ្សៀប៉ាម | ( Médazépam ) | ( Medazepam ) |
| មេហ្វេណូរិច | ( Méfénorex ) | ( Mefenorex ) |
| មេប្រ៉ូបាម៉ាត | ( Méprobamate ) | ( Meprobamate ) |
| មេទីលហ្វេណូបាប៊ីតាល់ | ( Méthylphénobarbital ) | ( Methylphenobarbital ) |
| មេទីព្រីឡូន | ( Méthyprylone ) | ( Methyprylone ) |
| មេដាហ្សូឡាំ | ( Médazolam ) | ( Medazolam ) |
| នីមេតាហ្សៀប៉ាម | ( Nimétazépam ) | ( Nimetazepam ) |
| នីត្រាហ្សៀប៉ាម | ( Nitrazépam ) | ( Nitrazepam ) |
| ន័រដាហ្សៀប៉ាម | ( Nordazépam ) | ( Nordazepam ) |
| អុកសាហ្សៀប៉ាម | ( Oxazépam ) | ( Oxazepam ) |
| អុកសាហ្សូឡាំ | ( Oxazolam ) | ( Oxazolam ) |
| ប៉េម៉ូលីន | ( Pémoline ) | ( Pemoline ) |
| ហ្វង់ឌីមេត្រាហ្ស៊ីន | (Phendimétrazine ) | ( Phendimetrazine ) |
| ហ្វេណូបាប៊ីតាល់ | ( Phénobarbital ) | ( Phenobarbital ) |
| ហ្វង់ទែរមីន | ( Phentermine ) | ( Phentermine ) |
| ពីណាហ្សៀប៉ាម | ( Pinazépam ) | ( Pinazepam ) |
| ពីប្រ៉ាដ្រុល | ( Pipradrol ) | ( Pipradrol ) |
| ប្រ៉ាហ្សៀប៉ាម | ( Prazépam ) | ( Prazepam ) |
| ពីរ៉ូវ៉ាឡេរ៉ូន | ( Pyrovalérone ) | ( Pyrovalerone ) |
| សិចប៊ុយតាបាប៊ីតាល់ | ( Secbutabarbital ) | ( Secbutabarbital ) |
| តេម៉ាហ្សៀប៉ាម | ( Témazépam ) | ( Temazepam ) |
| តេត្រាហ្សៀប៉ាម | ( Tétrazépam ) | ( Tetrazepam ) |

| | | |
|---|---|---|
| ទ្រីហ្សូឡាំ | ( Trizolam ) | ( Triazolam ) |
| វីនីលប៊ីតាល់ | ( Vinylbital ) | ( Vinylbital ) |
| ស៊ៀ អាស់ បេ | ( GHB ) | ( GHB ) |
| ហ្ស៊ុលពីដែម | ( Zolpidem ) | ( Zolpidem ) |
| កេតាមីន | ( Kétamine ) | ( Ketamine ) |

**តារាងទី ៤** Table IV

| **ភាសាខ្មែរ** Khmer Language | **ភាសាបារាំង** France Language | **ភាសាអង់គ្លេសបែបអាមេរិកកាំង** English Language |
|---|---|---|
| ១. **តារាងទី ៤** (I) Table IV (I) | | |
| អាស៊ីដ លីហ្សែហ្ស៊ីក | ( Acide lysergique ) | ( Lysergic acid ) |
| អេហ្វេដ្រីន | ( Ephédrine ) | ( Ephedrine ) |
| អែរហ្គូមេទ្រីន | ( Ergométrine ) | ( Ergometrine ) |
| អែរហ្គូតាមីន | ( Ergotamine ) | ( Ergotamine ) |
| ហ្វេនីល-១ ប្រ៉ូប៉ាណូន-២ | ( Phényl-1 propanone-2 ) | ( 1-Phenyl-2 propanone ) |
| ផ្សីដូ-អេហ្វេដ្រីន | ( Pseudo-éphédrine ) | ( Pseudo-ephedrine ) |
| អាស៊ីដ អិន-អាសេទីល អង់ត្រានីលិក | ( Acide N-acétylanthranilique ) | ( N-Acetylanthranilic acid ) |
| អ៊ីហ្សូសាហ្វ្រូល | ( Isosafrole ) | ( Isosafrole ) |
| មេទីលឡែនឌីអុកស៊ីហ្វេនីល-៣,៤ប្រ៉ូប៉ាណូន-២ | ( Méthylènedioxyphényl-3,4 propanone-2 ) | ( 3,4-Methylenedioxy phenyl-2-propanone ) |
| ពីប៉េរ៉ូណាល់ | ( Pipéronal ) | ( Piperonal ) |
| សាហ្វ្រូល | ( Safrole ) | ( Safrole ) |
| ប្រេងម្រះព្រៅភ្នំ | ( Preng Mrah Prao Phnom ) | ( Preng Mrah Prao Phnom )[1] |
| អានីឌ្រីដអាសេទិក | ( Anhydride acétique ) | ( Acetic anhydride ) |
| ពែម៉ង់ហ្គាណាត ដឺប៉ូតាស្យូម | ( Permanganate de | ( Potassium permanganate ) |

ROYAUME DU CAMBODGE MINISTRE DU PALAIS ROYAL ក្រសួងព្រះបរមរាជវាំង

| | | |
|---|---|---|
| | potassium ) | |
| [1]Preng Mrah Prao Phnom is a kind of oils which refined from Mrah Prao trees in Cambodia and high contained Safrole Rich Oil. | | |

| ២. **តារាងទី ៤** (II) Table IV (II)[1] | | |
|---|---|---|
| អាសេតូន | ( Acétone ) | ( Acetone ) |
| អាស៊ីដ អង់ត្រានីលិក | ( Acide anthranilique ) | ( Anthranilic acid ) |
| អាស៊ីដ ហ្វេនីល អាសេទិក | ( Acide phénylacétique ) | ( Phenylacetic acid ) |
| អេទែរអេទីលិក | ( Ether éthylique ) | ( Ethyl ether ) |
| ពីប៉េរីឌីន | ( Pipéridine ) | ( Piperidine ) |
| អាស៊ីដ ក្លរីឌ្រិក | ( Acide chlorhydrique ) | ( Hydrochloric acid ) |
| មេទីលអេទីលសេតូន | ( Méthyléthylcétone ) | ( Methyl ethyl ketone ) |
| អាស៊ីដ ស៊ុលហ្វួរិក | ( Acide sulfurique ) | ( Sulfuric acid ) |
| តូលុយអែន | ( Toluène ) | ( Toluene ) |
| ផូស្វ័រុស ទ្រីក្លរ៉ីដ | ( Phosphorus trichloride ) | ( Phosphorus trichloride ) |
| ផូស្វ័រុស ប៉ង់តាក្លរ៉ីដ | ( Phosphorus pentachloride ) | ( Phosphorus pentachloride ) |
| ប៉ាល់ឡាដ្យូម | ( Palladium ) | ( Palladium ) |
| អាសេទីល ក្លរ៉ីដ | ( Acétyl chloride ) | ( Acetyl chloride ) |
| អេទីលីឌែន ឌីអាសេតាត | ( Ethylidène diacétate ) | ( Ethylidene diacetate ) |
| អាស៊ីដ ហ្វ័រមិក | ( Acide formique ) | ( Formic acid ) |
| អាស៊ីដ អាសេទិក គ្លាស់ស្យាល់ | ( Acide acétique glacial ) | ( Acetic acid glacial ) |
| ក្លរ៉ូហ្វម | ( Chloroforme ) | ( Chloroform ) |
| ត្យូនីល ក្លរ៉ីដ | ( Thionyl chloride ) | ( Thionyl chloride ) |

[1] The last six items of precursors were included into the table 4 (II) of the annex of the draft of Drug Control Law by Minister of health on 24 December 2009

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០១១

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៤ នៃរដ្ឋសភានាថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំនៃរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់សេចក្តីសម្រេចរួមលេខ ០០៥ ព.រ.ក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការបង្កើតបេឡាសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈសម្រាប់មន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៦០៨/៧៥៥ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីការផ្ទេរបញ្ចូលក្នុងក្របខ័ណ្ឌមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា
- បានទ្រង់យល់សេចក្តីសម្រេចលេខ ២០៤ រ.ស ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ របស់រដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានដាក់ឱ្យចូលនិវត្តន៍ឯកឧត្តម **ចាន់ ម៉ែន** ពីឋានន្តរសក្តិឧត្តមអភិបាល ថ្នាក់លេខ ១ នៃក្របខ័ណ្ឌមន្ត្រីរាជការ នៃក្រុមនីតិប្បញ្ញត្តិ មន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

**មាត្រា ២ :** សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣១៤. ១២០១. ០១៣

លេខៈ ៣៤ ច.ល
**ដើម្បីចម្លងចែក**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល**

**សុយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០១៨

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្រ្ទាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០១៩៦/១៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងព័ត៌មាន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១:** ត្រូវបានតែងតាំងឯកឧត្តម **សោម សារុន** ជាទីប្រឹក្សាក្រសួងព័ត៌មាន មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២:** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣:** ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៩. ១៨០១. ០១២

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២

លេខៈ ៤៦ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០១២
អគ្គលេខាធិការរងទីស្តីការរាជរដ្ឋាភិបាល

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០១៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា**
**សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ប្រោសព្រះរាជទាន

នូវ

គ្រឿងឥស្សរិយយស ជាតូបការ

ចំពោះ

ឯកឧត្តម ឡោត ហ៊្វីរ

ដែលបានខិតខំបំពេញភារកិច្ចជូនជាតិមាតុភូមិ និងមានស្នាដៃល្អ
ក្នុងការចូលរួមចំណែកកសាងអភិវឌ្ឍន៍ប្រទេសជាតិ

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៩៤. ១២០១. ០២០

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២*

លេខៈ ៥៤ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១២
**អគ្គលេខាធិការនៃទីស្តីការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០១៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

ចំពោះ

មន្ត្រីរាជការ និងសប្បុរសជន ចំនួន ១២រូប ដែលមានគុណបំណាច់យ៉ាងធំធេងក្នុងការបម្រើជាតិ មាតុភូមិ

នូវ

ក- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

- ឯកឧត្តម **ថៃ ហ្វា**

ខ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **គាង អ៊ីនធ័រ** ២- ឯកឧត្តម **គង់ ប៉ូល**
៣- ឯកឧត្តម **សា ផល្លី**

គ- គ្រឿងឥស្សរិយយស **សុវត្ថារា** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម **ឈុន ចន្ទ្រា** ២- ឯកឧត្តម **លឹម ហ្សូរនីតា**

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

- ឯកឧត្តម **តាន់ សុវត្ថុន**

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

១- ឯកឧត្តម **លាង វ៉ូលាន** ២- ឯកឧត្តម **ចាង សាធធ័រ**
៣- ឯកឧត្តម **គាង យុនម៉ុង**

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

១- លោក **ឆាន់ ជីងហ៊ូ** ២- លោក **ដួង ចិនយី**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

៣៦៩.១២០១.០២១

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២

លេខៈ ៥៣ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែមករា ឆ្នាំ២០១២
**អគ្គលេខាធិការរងទី១រាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០១១២/០៧០

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

**ប្រោសព្រះរាជទាន**

**នូវ**

ក- គ្រឿងឥស្សរិយយស ថ្នាក់ **ជាតូបការ** :

- ឧត្តមសេនីយ៍ឯក យឹម ណាង

ខ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឧត្តមសេនីយ៍ទោ អ៊ឹង សំកត់ ២- ឧត្តមសេនីយ៍ទោ គីម សោភ័ណ្ឌ
៣- ឧត្តមសេនីយ៍ទោ មាស គីមហេង ៤- ឧត្តមសេនីយ៍ត្រី មិក សាផាណារេត
៥- ឧត្តមសេនីយ៍ត្រី ចេង ហុង ៦- ឧត្តមសេនីយ៍ត្រី មាស ស៊ីផាន
៧- វរសេនីយ៍ឯក គីម សារ៉ុន

គ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- ឯកឧត្តម ប៉ក់ វិជិត ២- ឯកឧត្តម ឈឹម ម៉ៅ
៣- ឯកឧត្តម ឈឹម ហួរ ៤- ឧត្តមសេនីយ៍ត្រី នួន សុខ័ណ្ណារ៉ា
៥- ឧត្តមសេនីយ៍ត្រី ញ៉ែម ចំណាន ៦- ឧត្តមសេនីយ៍ត្រី សុខ សារ៉ន
៧- ឧត្តមសេនីយ៍ត្រី ឡី ណារី ៨- ឧត្តមសេនីយ៍ត្រី ហេង នាយ
៩- ឧត្តមសេនីយ៍ត្រី មិន ធឿន ១០- វរសេនីយ៍ឯក យឹម ល័ក្ខ
១១- វរសេនីយ៍ឯក តូច វាសនា ១២- វរសេនីយ៍ឯក ទឹម សម្បត្តិ
១៣- វរសេនីយ៍ឯក ជា សុភា ១៤- វរសេនីយ៍ឯក ខាំ វណ្ណា
១៥- លោក អ៊ិត ភូម្រា ១៦- លោក ប៊ុល ខាំណារ៉េ

ឃ- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **ធិបឌិន្ទ** :

១- ឯកឧត្តម ធន វិមានច័ន្ទ ២- វរសេនីយ៍ឯក ញ៉ែម ធន
៣- វរសេនីយ៍ឯក ព្រាប សុខ ៤- វរសេនីយ៍ឯក គីម សារី

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះបរមរាជវាំង

| | | | | | |
|---|---|---|---|---|---|
| ៥- វរសេនីយ៍ទោ | ញ៉ែម | វិរៈឆ្វុប | ៦- វរសេនីយ៍ទោ | ព្រាប | បុរិន្ទ |
| ៧- វរសេនីយ៍ទោ | មាស | សម្បត្តិ | ៨- វរសេនីយ៍ទោ | យិន | សុខ |
| ៩- វរសេនីយ៍ទោ | ម៉ុក | សុខា | ១០- លោក | ប៉ូ | សុវណ្ណារ៉េត |

ង- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** :

| | | | | | |
|---|---|---|---|---|---|
| ១- វរសេនីយ៍ទោ | ចាន់ | សារ៉េត | ២- វរសេនីយ៍ត្រី | ឈុន | គីមហេង |
| ៣- លោកស្រី | សៅ | ចន្ទ្រា | ៤- លោកស្រី | ពេជ្រ | ចាន់ធី |
| ៥- លោកស្រី | អ៊ឹម | ស្រីមុំ | ៦- លោកស្រី | តឹម | សាមិត្ត |
| ៧- លោកស្រី | យុន | សុឃីម | ៨- កញ្ញា | យុន | សុឃឿន |
| ៩- លោកស្រី | ហេង | ខួច | ១០- លោកស្រី | ពុធ | ម៉ាឈ័យ |
| ១១- កញ្ញា | សុខ | លក្ខិណា | ១២- កញ្ញា | វិន | សាម៉ន |
| ១៣- លោក | ថ្រី | អាំងតុង | | | |

ច- គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **អស្សឫទ្ធិ** :

| | | | | | |
|---|---|---|---|---|---|
| ១- វរសេនីយ៍ត្រី | ឈុន | គីមហុង | ២- លោក | សុវណ្ណ | ដេណូរ៉ា |
| ៣- កញ្ញា | ចាន់ | ផូរស្មី | ៤- កញ្ញា | មុំ | ចិន្តា |
| ៥- លោក | ជា | ប៊ុនធឿន | | | |

លេខរៀងទី៤ ចំណុច ច នៃព្រះរាជក្រឹត្យលេខ **នស/រកត/៤២៥** ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១១ ត្រូវទុកជានិរាករណ៍ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

នសរកត. ១២០១. ០២២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១២*

លេខ: ៥៧ ច.ល
**ដើម្បីចម្លងចែក**
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១២
**អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី** ... **ទីស្តីការគណៈរដ្ឋមន្ត្រី**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...០៦...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៧.៦០០ ហិកតា ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ខែ ឧសភា ឆ្នាំ ២០០១ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រងក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១**:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនូវផ្ទៃដីទំហំ ៧.៦០០ (ប្រាំពីរពាន់ប្រាំមួយរយ) ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៣៨៩ សជណ ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២**:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣**:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៤**:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ០៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៦.៥០០ ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រ ខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ២០០១ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាល នៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ២៦៣ អនក្រ.បកចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១**:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៦.៥០០ (ប្រាំមួយពាន់ប្រាំរយ) ហិកតា ក្នុងតំបន់ជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ក្រោមល័ក្ខខ័ណ្ឌ សម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ លើវិស័យដាំដំណាំកសិ-ឧស្សាហកម្ម និងដាំដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៣៨៨ សជណ ចុះថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២**:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣**:

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤**:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តឧត្តរមានជ័យ និងខេត្តព្រះវិហារ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..០៥៤.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.០២០ ហិកតា ក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្រ្ត ខេត្តឧត្តរមានជ័យ

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការ បង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែ ឧសភាឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ២៧១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១**:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៩.០២០ (ប្រាំបួនពាន់ម្ភៃ) ហិកតា ក្នុងតំបន់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ស្ថិតនៅក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ ក្រោមល័ក្ខខ័ណ្ឌសម្បទាន ដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៩០២ សជណ ចុះថ្ងៃទី០៤ ខែ វិច្ឆិកា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២**:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្តដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣**:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤**:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តឧត្តរមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១២

ជ.នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារកាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ០៩ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគ ផ្ទៃដីទំហំ ៩.១៧៣ ហិកតា ក្នុងដែនជម្រកសត្វព្រៃលំផាត់ ស្ថិតនៅក្នុងភូមិសាស្ត្រស្រុកលំផាត់ ខេត្តរតនគិរី

# រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រតក/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និង របស់នីតិបុគ្គលសាធារណៈ

-បានឃើញអនុក្រឹត្យលេខ ២៥៩ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ស្តីពីការកំណត់តំបន់គ្រប់គ្រង ក្នុងតំបន់ការពារធម្មជាតិទៅជាតំបន់ប្រើប្រាស់ដោយចីរភាព

-យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

**មាត្រា១**:

ត្រូវបានចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នូវផ្ទៃដីទំហំ ៩.១៧៣ (ប្រាំបួនពាន់មួយរយចិតសិបបី) ហិកតាក្នុងតំបន់ដែនជម្រកសត្វព្រៃលំផាត់ស្ថិតក្នុងភូមិសាស្ត្រខេត្តរតនគីរី ក្រោមល័ក្ខខ័ណ្ឌ សម្បទានដើម្បីធ្វើការវិនិយោគអភិវឌ្ឍន៍ លើវិស័យដំណាំកសិ-ឧស្សាហកម្ម និងដំណាំកៅស៊ូ ដូចមានក្នុងផែនទី និងនិយាមកា ដែលជាឯកសារភ្ជាប់នឹងលិខិតលេខ ១៣១៩ សជណ ចុះថ្ងៃទី១៧ ខែ តុលា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា២**:

ផ្ទៃដីដែលត្រូវបានធ្វើអនុបយោគ ដូចកំណត់ក្នុងមាត្រា១ នៃអនុក្រឹត្យនេះត្រូវស្ថិតក្រោមការចាត់ចែងនីតិវិធីបន្ត ដោយក្រសួងបរិស្ថាន ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ ព្រមទាំងមានកិច្ចសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ស្របតាមច្បាប់ និងគោលការណ៍របស់រាជរដ្ឋាភិបាល។

**មាត្រា៣**:

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៤**:

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន គ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្តរតនគីរី ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១២.

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

<u>កន្លែងទទួល:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ៤
-រាជកិច្ច
-ឯកសារកាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ពាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០២រូប ដែលបានផ្តល់ថវិកាចំនួន ៤៥.៤១៩.៨៣ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០១ខ្នង មាន០៤បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ និងបង្គន់អនាម័យ ០១ខ្នង មាន០២បន្ទប់ ជូនដល់សាលាមត្តេយ្យសិក្សាជប់វារី ស្ថិតនៅភូមិជប់ ឃុំវារី ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

១-អ្នកស្រី ELISABET PLANAS សប្បុរសជន
២-អ្នកស្រី MARINA UALLCOBBA សប្បុរសជន

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៤រូប ដែលបានផ្តល់ថវិកាសរុបចំនួន ១៩២.០០០ ដុល្លារអាមេរិក ក្នុងការជួយកសាងអគារសិក្សា ០៣ខ្នង មាន១៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ និងបង្គន់អនាម័យ ១៣បន្ទប់ ជូនដល់សាលាបឋមសិក្សាកំពង់ស្វាយ ស្ថិតនៅភូមិកំពង់ស្វាយ សង្កាត់កំពង់-ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោម ៖

១-លោក JOHN VERNON WHHITE

២-អ្នកស្រី JANE ALISON WHITE

៣-លោក MECH SAMUTH និង ភរិយា

៤-អ្នកស្រី JANET ELIZABETH GRACEY

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១២

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧. អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយសហមេត្រី

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**សម្រេច**

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនមន្ត្រីស្ថានទូតជប៉ុន និងមន្ត្រីទីភ្នាក់ងារ JICA ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចំនួន០៥រូប ដែលបានខិតខំនិងយកចិត្តទុកដាក់រួមចំណែកដ៏ធំធេងក្នុងការជួយវិស័យអប់រំ នៅរាជធានីភ្នំពេញ ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយសហមេត្រី ថ្នាក់ ធិបឌិន្ទ:**

១-លោកស្រី KAMEI Naoko , Representative JICA Office Phnom Penh

២-លោក YAMADA Osamu, Grant Aid Advisor JICA Office Phnom Penh

**ខ-មេដាយសហមេត្រី ថ្នាក់ សេនា:**

១-លោក KONDO Naomitsu , Second Secretary Economic & ODA Section Embassy of Japan

២-លោកស្រី HIGASHIYAMA Harumi , KUSANONE Grant Coordinator Embassy of Japan

៣-លោកស្រី TOYAMA Haruko , KUSANONE Grant Coordinator Embassy of Japan

**មាត្រា២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា និងអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការអនុវត្តន៍ ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## សម្រេច

**មាត្រា ១** : ត្រូវបានផ្ទេរភារកិច្ចលោក **សុច សុផាន់ណារ៉ា** ពីអធិការ នៃអគ្គាធិការដ្ឋានកិច្ចការតុលាការ ទៅជាប្រធាននាយកដ្ឋានកិច្ចការព្រហ្មទណ្ឌ នៃអគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងយុត្តិធម៌។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់សមាជិកជ្រើសតាំង សភាពាណិជ្ជកម្មខេត្តព្រៃវែង អាណត្តិទី១ លើកទី១

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០៦/០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា២ និងមាត្រា១៥ ស្តីពីច្បាប់សភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៩១ អនក្រ.បក ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំការបោះឆ្នោតសភាពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការបង្កើតសភាពាណិជ្ជកម្មខេត្តព្រៃវែង
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សម្រេច**

**មាត្រា ១:** ទទួលស្គាល់សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្តព្រៃវែង ចំនួន១៥រូប សម្រាប់អាណត្តិទី១ លើកទី១ ដូចខាងក្រោម ៖

| | |
|---|---|
| ១- លោក **ឈុន ធំ** | **ជាប្រធានសភាពាណិជ្ជកម្ម ខេត្តព្រៃវែង** |
| ២- លោក **រស់ ឈោខ** | សមាជិក |
| ៣- លោក **ម៉ែន ណុប** | សមាជិក |
| ៤- លោក **សួស សារ៉ន** | សមាជិក |
| ៥- លោក **តូច បុណ្ណាម៉ុរ៉ាមី** | សមាជិក |
| ៦- លោក **ស៊ុយ គីមលី** | សមាជិក |
| ៧- លោក **ហួខ ឡេខ** | សមាជិក |
| ៨- លោកស្រី **ម៉ៅ នីន** | សមាជិក |
| ៩- លោក **ឈុន កុយ** | សមាជិក |
| ១០- លោក **ពេញ រស្មី** | សមាជិក |
| ១១- ឧកញ៉ា **សារ លាខ** | សមាជិក |
| ១២- លោកស្រី **ម៉ែន ច័ន្ទបុប្ផា** | សមាជិក |
| ១៣- លោកស្រី **ឆែម ថាវបុរី** | សមាជិក |
| ១៤- លោក **ឈុន យ៉ាន** | សមាជិក |
| ១៥- លោកស្រី **សារី គន្ធា** | សមាជិក |

**មាត្រា ២:** ទទួលស្គាល់លោក **ឈុន ធំ** ជាប្រធានសភាពាណិជ្ជកម្មខេត្តព្រៃវែង។

**មាត្រា ៣:** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៤.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលខេត្តព្រៃវែង ប្រធានសភាពាណិជ្ជកម្មកម្ពុជា និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ច រៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែមករា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>កន្លែងទទួល</u> ៖**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-សាលារាជធានី-ខេត្ត

-សភាពាណិជ្ជកម្មកម្ពុជា

-ដូចមាត្រា៤

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...៧៤១..អនក្រ.បក**

# អនុក្រឹត្យ

ស្តីពី

## ការកែសម្រួលថ្នាក់ជូនមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ

-យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ត្រូវបានកែសម្រួលថ្នាក់ជូនលោក **អ៊ុន សាខុធ** ពីឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ ៩ ទៅជាវរមន្ត្រីថ្នាក់លេខ ៥ នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការដាក់មន្ត្រីរាជការស៊ីវិល
## ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ចុះថ្ងៃទី២៥ខែកញ្ញាឆ្នាំ២០០៨ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ខែកក្កដាឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/២០ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ៦៦អនក្រ.បកចុះថ្ងៃទី២២ខែតុលាឆ្នាំ១៩៩៧ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ០៥អនក្រ.ប.កចុះថ្ងៃទី២៨ខែមករាឆ្នាំ២០០៣ស្តីពីការតម្លើងនាយកដ្ឋានរដ្ឋបាលនិងបណ្តុះបណ្តាលទៅជាអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- អនុក្រឹត្យលេខ១១៦អនក្រ.កតចុះថ្ងៃទី១៩ខែតុលាឆ្នាំ១៩៩៥ស្តីពីការដាក់មន្ត្រីរាជការស៊ីវិលឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### សម្រេច

**មាត្រា ១ :** ផ្អាកការងារលោក **លី សំអាន** បច្ចុប្បន្នជាអគ្គនាយករងរដ្ឋបាលនៃអគ្គនាយកដ្ឋានរដ្ឋបាលឱ្យស្ថិតក្នុងភាព ទំនេរគ្មានបៀវត្សរយៈពេល០១ឆ្នាំ (មួយឆ្នាំ) លើកទី០១ចាប់ពីថ្ងៃទី០១ខែមករាឆ្នាំ២០១២ដល់ថ្ងៃទី០១ខែមករាឆ្នាំ២០១៣។

**មាត្រា ២ :** លោក **លី សំអាន** ត្រូវដាក់ពាក្យសុំបន្ត ឬចូលបម្រើការងារវិញឱ្យបាន០២ខែ (ពីរខែ) មុនពេលផុតកំណត់នៃរយៈពេលស្ថិតក្នុងភាពទំនេរគ្មានបៀវត្សរ៍។ក្នុងករណីដែលពុំបានសុំបន្តឬសុំចូលបម្រើការងាររបស់ខ្លួនវិញដូចបានកំណត់ខាងលើគឺចាត់ទុកថាបោះបង់ចោលការងារហើយនឹងត្រូវលុបឈ្មោះចេញពីក្របខ័ណ្ឌ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្ត អនុក្រឹត្យនេះចាប់ពីថ្ងៃដូចមានចែងក្នុងមាត្រា១ខាងលើ ។

រាជធានីភ្នំពេញ.ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១២

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ: ៧៣ អនក្រ.បក**

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា** ជូនសប្បុរសជន ០២រូប ដែលបានបរិច្ចាគកម្លាំងកាយ-ចិត្ត ចូលរួមកសាង ព្រះវិហារ ឧបដ្ឋានសាលា របងវត្ត និងសមិទ្ធផលជាច្រើនទៀត នៅវត្តទួលសង្កែ ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម៖

| | | |
|---|---|---|
| ១-លោក | **ឃុត មករា** | មន្ត្រីកាំកុងត្រូល ខេត្តកំពង់ចាម |
| ២-លោក | **សំ អឿន** | មន្ត្រីគយ ខេត្តកំពង់ចាម |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤ . អនក្រ . បក

## អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស

### សម្រេច

**មាត្រា ១.-**

ត្រូវបានបំពាក់ មេដាយការងារ តាមលំដាប់ថ្នាក់ ជូនមន្ត្រីរាជការ ចំនួន ០៧រូប ដែលមានស្នាដៃល្អក្នុងការ ចូលរួមកសាង ព្រះវិហារ ឧបដ្ឋានសាលា របងវត្ត និងសមិទ្ធផលជាច្រើនទៀត នៅវត្តទួលសង្កែ ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ដូចមានរាយនាមខាងក្រោម៖

**ក-មេដាយមាសការងារ**

| | | |
|---|---|---|
| ១-លោក | ចាន់ ផានិត | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ២-លោក | ហោ តុលា | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |

**ខ-មេដាយប្រាក់ការងារ**

| | | |
|---|---|---|
| ១-លោក | អ៊ឹម ពិរុណ | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ២-លោក | ខង កឹកសុផាន់ណា | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៣-លោក | ខត្យ រតនៈ | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៤-លោក | យត់ សោភាន់ | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |
| ៥-លោកស្រី | ពេជ្រ សុជាតា | មន្ត្រីអគ្គលេខាធិការដ្ឋានរដ្ឋសភា |

**មាត្រា ២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជន ដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព [illegible] ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០១២

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាល**

**គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត**

លេខ : ..០៤..គសអ

# សេចក្តីសម្រេច

## ស្តីពី

## ការបំពេញបន្ថែមសមាសភាពរបស់លេខាធិការដ្ឋាន នៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤

## គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រម លេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៣០១/០៤ ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ
- បានឃើញអនុក្រឹត្យ លេខ ២១៥.អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១ ស្តីពីការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិឆ្នាំ២០១១-២០១៤
- ផែនការអន្តរស្ថាប័នមហាផ្ទៃ-ការពារជាតិ និង គ.ជ.ប លេខ ០១៤ ផ.ក/១១ ចុះថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១១ ស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សម្រាប់ដំណើរការរៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ប្រចាំឆ្នាំ និងការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១ ២០១៤
- យោងតាមការចាំបាច់ ។

## ស ម្រេ ច

**ប្រការ ១.-** ត្រូវបានបន្ថែមសមាសភាព **ឯកឧត្តម នាយឧត្តមសេនីយ៍ ឌុល គៀន** អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុក្រសួងមហាផ្ទៃ ជាអនុប្រធានលេខាធិការដ្ឋាននៃគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ (គ.ស.អ) សម្រាប់ការបោះឆ្នោតនៅថ្នាក់ក្រោមជាតិ-ថ្នាក់ជាតិ ឆ្នាំ២០១១-២០១៤ ។

**ប្រការ ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានលេខាធិការដ្ឋាន គ.ស.អ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងឯកឧត្តម **ឌុល គៀន** ត្រូវអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០១២**

**ប្រធានគណៈកម្មាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត**

ស ខេង

**កន្លែងទទួល :**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី ស ខេង
- អគ្គស្នងការដ្ឋាននគរបាលជាតិ
- អគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេស
- លេខាធិការដ្ឋាន គ.ស.អ
- គ្រប់គណៈបញ្ជាការឯកភាពរាជធានី ខេត្ត
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ ២
- ឯកសារ កាលប្បវត្តិ

ssd-Secretary for Election Security 2012-2014

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ**

រាជធានីភ្នំពេញ, ថ្ងៃទី..១៣..ខែ..មករា..ឆ្នាំ ២០១២

លេខ:......០៩.....ប្រ.ក

# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងអាជីវកម្ម សេវាកម្ម ថតរូប ផ្តិតរូប និងថតវីដេអូ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការគ្រប់គ្រងត្រួតពិនិត្យភាពយន្ត និងវីដេអូ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- យោងតាមការចាំបាច់របស់ក្រសួង ។

## សម្រេច

**ប្រការ១:** ប្រកាសនេះមានគោលបំណងគ្រប់គ្រងអាជីវកម្ម សេវាកម្មថតរូប ផ្តិតរូប និងថតវីដេអូ ដើម្បីធានាឲ្យបាននូវការគោរពសិទ្ធិ ទំនៀមទម្លាប់ប្រពៃណី និង សីលធម៌របស់សង្គមជាតិ។

**ប្រការ២:** អាជីវកម្ម សេវាកម្មថតរូប ផ្តិតរូប និងថតវីដេអូ សំដៅអាជីវកម្មដែលប្រើប្រាស់ឧបករណ៍ចាប់យករូបភាព ឬនិងសំឡេង រួមបញ្ចូលបច្ចេកទេសសិល្បៈ និងដោយមានការរៀបចំទុកជាមុន ដើម្បីបង្កើតនូវសោភ័ណភាពរូបភាព សម្រាប់បម្រើឲ្យគោលបំណង ឬគំនិតមួយ។

**ប្រការ៣:** រូបថតសិល្បៈ ជាកម្មសិទ្ធរបស់ម្ចាស់រូប ។ ការយករូបថតសិល្បៈទៅប្រើប្រាស់ ក្នុងទិសដៅអ្វីក៏ដោយ ត្រូវមានការយល់ព្រមពីម្ចាស់កម្មសិទ្ធិ ។

រូបថតសិល្បៈ មិនរាប់បញ្ចូល ការថតនូវរូបភាព ឬ សកម្មភាពរបស់បុគ្គល ឬ ក្រុមណាមួយដោយគ្មានការរៀបចំទុកជាមុន សម្រាប់បម្រើឲ្យការផ្សព្វផ្សាយពត៌មាន នោះឡើយ។

**ប្រការ៤:** រាល់ការប្រើប្រាស់បច្ចេកទេស កាត់តរូបភាព លើរាងកាយបុគ្គល ដើម្បីបង្កើតជារូបភាពមួយផ្សេង ដែលនាំឲ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់បុគ្គល ទំនៀមទម្លាប់ប្រពៃណីជាតិ និងជំនឿសាសនា ត្រូវហាមឃាត់។

អាជីវករ សេវករ: ថតរូប ផ្តិតរូប និងថតវីដេអូ មិនត្រូវប្រើប្រាស់សកម្មភាពរបស់ខ្លួនធ្វើឲ្យខូចខាត ឬ ប៉ះពាល់ដល់របៀបរបបក្នុងពិធីជាប្រពៃណី លើកលែងតែមានការយល់ព្រមពីម្ចាស់ពិធីនោះ។

**ប្រការ៥:** រូបថតសិល្បៈគ្រប់ប្រភេទ អាចប្រើប្រាស់ សម្រាប់ការផ្សព្វផ្សាយ ជាសាធារណៈបាន ប្រសិនបើរូបភាពនោះ មានតម្លៃសិល្បៈខ្ពស់ និងមិនប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់។

ការផលិតរូបភាពអាសអាភាស ត្រូវហាមឃាត់។

**ប្រការ៦:** ការប្រកបអាជីវកម្ម សេវាកម្ម ថតរូប ផ្តិតរូប និងថតវីដេអូ ត្រូវសុំការអនុញ្ញាតពីមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ឬ ពីការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខ័ណ្ឌ ស្រុកគោលដៅ ដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

រាល់ការអនុញ្ញាត ប្រកបអាជីវកម្ម សេវាកម្ម ថតរូប ផ្តិតរូប និងថតវីដេអូ ត្រូវមានកម្រៃសេវាកម្មដែលកំណត់ដោយប្រកាសអន្តរក្រសួង រវាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬ តាមតារាងកម្រៃសេវាកម្ម របស់ការិយាល័យច្រកចេញចូលតែមួយនៃក្រុង ខ័ណ្ឌ ស្រុកគោលដៅដែលបានទទួលការធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

**ប្រការ៧:** នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ ប្រធាននាយកដ្ឋានសិល្បៈសូនរូប និងសិល្បៈសិប្បកម្ម ប្រធាននាយកដ្ឋានសិល្បៈភាពយន្ត និងផ្សព្វផ្សាយវប្បធម៌ ប្រធាននាយកដ្ឋានសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល គ្រប់ប្រធានអង្គភាពពាក់ព័ន្ធ និង ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**ហ៊ឹម ឆែម**

**កន្លែងទទួល:**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-គ្រប់ក្រសួងស្ថាប័ន " ដើម្បីជ្រាបជាព័ត៌មាន "
-គ្រប់សាលារាជធានី ខេត្ត" ដើម្បីសហការ "
-ដូចប្រការ៧
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ

លេខៈ...៣៧/ប៨

## ប្រកាស
## ស្តីពី
## ការធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចការងារវប្បធម៌និងវិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ

### រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

-បានឃើញសេចក្តីសម្រេចលេខ ១២ សសរ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការបង្កើតការិយាល័យច្រកចេញចូលតែមួយនិងការិយាល័យប្រជាពលរដ្ឋ នៅថ្នាក់ស្រុក ខណ្ឌ ។

### សម្រេច

**ប្រការ១ .~**

ត្រូវបានធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចការងារវប្បធម៌និងវិចិត្រសិល្បៈ ជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញក្នុងក្របខណ្ឌនៃការចេញអាជ្ញាបណ្ណ ដើម្បីផ្តល់សេវាកម្មវប្បធម៌និងវិចិត្រសិល្បៈដូចខាងក្រោម៖

- កម្មវិធីសម្តែងសិល្បៈផ្សេងៗ
- កម្មវិធីបញ្ចាំងភាពយន្ត វីដេអូ
- សេវាកម្មលក់ ជួលស្នាដៃភាពយន្ត វីដេអូ
- សេវាកម្មផ្តិតរូប ថតរូប ថតវីដេអូ
- សេវាកម្មស្លាកសញ្ញាអាជីវកម្ម
- សេវាកម្មចម្លាក់ពុម្ព
- សេវាកម្មលក់សៀវភៅ
- សេវាកម្មបញ្ចូលបទភ្លេងទូរសព្ទ

- សេវាកម្មគ្រឿងបំពងសំឡេង
- សេវាកម្មអ៊ុតសក់ កាត់សក់ លម្អក្រចក និង
- សេវាកម្មសម្អាងការ

**ប្រការ២ .-**

មន្ត្រីទទួលបន្ទុកបច្ចេកទេសជំនាញនិងនីតិកម្ម ត្រូវរៀបចំគំរូសំណុំបែបបទ តាមគោលការណ៍កំណត់ ជូនខណ្ឌគោលដៅសម្រាប់ការផ្តល់អាជ្ញាបណ្ណសេវាកម្ម ដូចបានចែងក្នុងប្រការ ១ ។

**ប្រការ៣ .-**

ការអនុវត្តលើសំណុំបែបបទ ដែលពាក់ព័ន្ធដល់ការចេញអាជ្ញាបណ្ណសេវាកម្ម វប្បធម៌ និងវិចិត្រសិល្បៈ ត្រូវកំណត់ដោយសេចក្តីណែនាំមួយដោយឡែករបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

បញ្ជីលម្អិតកាយមុខសេវាកម្ម ដែលត្រូវធ្វើប្រតិភូកម្មជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ ជាឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៤ .-**

ខណ្ឌគោលដៅ ត្រូវធ្វើរបាយការណ៍រៀងរាល់ខែនិងឆ្នាំពីលទ្ធផលនៃសកម្មភាពផ្តល់អាជ្ញាបណ្ណសេវាកម្ម វប្បធម៌ និងវិចិត្រសិល្បៈតាមរយៈមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី មកក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ។

**ប្រការ៥ .-**

នាយកខុទ្ទកាល័យ អធិការ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសវប្បធម៌ គ្រប់ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈរាជធានីភ្នំពេញ និង មន្ត្រីទទួលបន្ទុកការងារវិសហមជ្ឈការ មានភារកិច្ចអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១២

រដ្ឋមន្ត្រី

ហ៊ឹម ឆែម

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
(ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល)
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
(អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន)
- សាលារាជធានីភ្នំពេញ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ពន្ធ ប្រកាសលេខ[illegible]ចុះថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ ២០១២ស្ដីពីការធ្វើប្រតិភូកម្មមុខងារ
និងភារកិច្ចការងារវប្បធម៌និងវិចិត្រសិល្បៈជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ

**បញ្ជីលម្អិតរាយមុខសេវាកម្មវប្បធម៌និងវិចិត្រសិល្បៈ**

| ល.រ | សេវាកម្ម | ប្រភេទសេវាកម្ម | ផ្សេងៗ |
|---|---|---|---|
| ១ | -កម្មវិធីសម្ដែងសិល្បៈផ្សេងៗ | - ការប្រគំតន្ត្រីតាមទីសាធារណៈ<br>- ការសម្ដែងល្ខោនគ្រប់ទម្រង់ (លក់សំបុត្រ)<br>- អាជីវកម្មរាំលក់ផ្កា | (២កម្រិត) |
| ២ | -កម្មវិធីបញ្ចាំងភាពយន្តវីដេអូ | - បញ្ចាំងផ្សព្វផ្សាយពាណិជ្ជកម្ម (តាមទីសាធារណៈ)<br>- បញ្ចាំងកំដរក្នុងពិធីបុណ្យផ្សេងៗ (តាមទីសាធារណៈ)<br>- បញ្ចាំងកំដរភ្ញៀវ( ហាងកាហ្វេ ក្លិបកំសាន្ត ។ល។ ) | (ចល័ត)<br>(ចល័ត) |
| ៣ | -សេវាកម្មលក់ជួលស្នាដៃភាពយន្ត វីដេអូ | - អគារលក់ស៊ីឌី វីស៊ីឌី ឌីវីឌី<br>- ហាងលក់ ជួលកាស្សែត ស៊ីឌី វីស៊ីឌី ឌីវីឌី<br>- តូបលក់ជួលកាស្សែត ស៊ីឌី វីស៊ីឌី ឌីវីឌី | |
| ៤ | -សេវាកម្មផ្ដិតរូប ថតរូបនិងថតវីដេអូ | - អគារផ្ដិតរូប ថតរូប ថតវីដេអូ (ស្ទូឌីយោ)<br>- ហាងថតរូប ថតវីដេអូ | |
| ៥ | - សេវាកម្មស្លាកសញ្ញាអាជីវកម្ម | - ផ្ទាំងយីហោ ផ្ទាំងផ្សាយពាណិជ្ជកម្ម និងនិមិត្តសញ្ញាផ្សេងៗ<br>- បដាផ្សាយពាណិជ្ជកម្ម<br>- បណ្ណប្រកាសផ្សាយពាណិជ្ជកម្ម<br>- ទីតាំងផលិតស្លាកសញ្ញា<br>- ជាងគំនូរ | (៥កម្រិត) |
| ៦ | -សេវាកម្មចម្លាក់ពុម្ព | - ទីតាំងផលិត លក់ចម្លាក់ពុម្ពស៊ីម៉ង់ត៍<br>- ទីតាំងផលិតលក់ចម្លាក់ម្នាងសិលា | |
| ៧ | -សេវាកម្មលក់សៀវភៅ | - បណ្ណាគារ<br>- តូបលក់សៀវភៅ | (២កម្រិត) |
| ៨ | -សេវាកម្មបញ្ចូលបទភ្លេងទូរស័ព្ទ | -សេវាកម្មបញ្ចូលបទភ្លេងទូរសព្ទ | |
| ៩ | -សេវាកម្មគ្រឿងបំពងសំឡេង | - សេវាកម្មជួលឧបករណ៍បំពងសំឡេងក្នុងពិធីផ្សេងៗ<br>- សេវាកម្ម ជួលធុងបាស់ | |
| ១០ | -សេវាកម្មអ៊ុតសក់ កាត់សក់ លម្អក្រចក | - អ៊ុតសក់ កាត់សក់ លម្អក្រចក<br>- កាត់សក់ | (២កម្រិត) |
| ១១ | -សេវាកម្មសម្អាងការ | - សម្អាងការ | (៣កម្រិត) |

## តារាងតម្លៃសេវាកម្មវប្បធម៌និងវិចិត្រសិល្បៈ
## ដែលត្រូវធ្វើប្រតិភូកម្មមុខងារនិងភារកិច្ចជូនខណ្ឌគោលដៅនៃរាជធានីភ្នំពេញ

| លក្ខណៈប្រតិភូកម្ម | រាយមុខសេវាកម្ម | | តម្លៃសេវាកម្ម | | | | | ទឹកប្រាក់សរុប |
|---|---|---|---|---|---|---|---|---|
| | | | បង្កាន់ដៃ - ពាក្យសុំ | តែមប្រ៍ | សេវាប្រតិបត្តិ | រយៈពេល | អាជ្ញាបណ្ណ | |
| ១-កម្មវិធីសម្តែងសិល្បៈផ្សេងៗ | -ការប្រគំតន្ត្រីតាមទីសាធារណៈ | លក្ខណៈអន្តរជាតិ | ១០០០៛ | ២០០០៛ | ១៩៧០០០៛ | ១លើក | លិខិតអនុញ្ញាត | ២០០០០០៛ |
| | | លក្ខណៈជាតិ | ១០០០៛ | ២០០០៛ | ៩៧០០០៛ | | | ១០០០០០៛ |
| | -ការសម្តែងល្ខោនគ្រប់ទម្រង់(លក់សំបុត្រ) | | ១០០០៛ | ២០០០៛ | ១២០០០៛ | | | ១៥០០០៛ |
| | -អាជីវកម្មរាំលក់ផ្កា (លក់សំបុត្រ) | | ១០០០៛ | ២០០០៛ | ១២០០០៛ | ១ថ្ងៃ | | ១៥០០០៛ |
| ២-កម្មវិធីបញ្ចាំងភាពយន្តវីដេអូ | -បញ្ចាំងផ្សព្វផ្សាយពាណិជ្ជកម្ម | | ១០០០៛ | ២០០០៛ | ១២០០០៛ | ១ថ្ងៃ | លិខិតអនុញ្ញាត | ១៥០០០៛ |
| | -បញ្ចាំងកំដរក្នុងពិធីបុណ្យផ្សេងៗ | | ១០០០៛ | ២០០០៛ | ១២០០០៛ | | | ១៥០០០៛ |
| | -បញ្ចាំងកំដរភ្ញៀវ | | ៣០០០៛ | ២០០០៛ | ២១០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ២៦០០០៛ |
| ៣-សេវាកម្មលក់ជួលស្នាដៃភាពយន្តវីដេអូ | -អគារលក់ស៊ីឌី វីស៊ីឌី ឌីវីឌី | | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៤០០០០៛ |
| | -ហាងលក់ ជួលកាសែ្សត ស៊ីឌី វីស៊ីឌី ឌីវីឌី | | ៣០០០៛ | ២០០០៛ | ២១០០០៛ | | | ២៦០០០៛ |
| | -តូបលក់ជួលកាសែ្សត ស៊ីឌី វីស៊ីឌី ឌីវីឌី | | ៣០០០៛ | ២០០០៛ | ១២០០០៛ | | | ១៧០០០៛ |
| ៤-សេវាកម្មផ្តិតរូប ថតរូបនិងថតវីដេអូ | -អគារផ្តិតរូប ថតរូប ថតវីដេអូ ( ស្ទីឌីយោ ) | | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៤០០០០៛ |
| | -ហាងថតរូប ថតវីដេអូ | | ៣០០០៛ | ២០០០៛ | ២១០០០៛ | | | ២៦០០០៛ |
| ៥-សេវាកម្មស្លាកសញ្ញាអាជីវកម្ម | -ផ្ទាំងឃោសនា ផ្ទាំងផ្សាយពាណិជ្ជកម្ម និង និមិត្តសញ្ញាផ្សេង ៗ | ២ម² ចុះក្រោម | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ២ឆ្នាំ | បណ្ណអនុញ្ញាត | ៤០០០០៛ |
| | | ២ម² - ៤ម² | ៣០០០៛ | ២០០០៛ | ៤៥០០០៛ | | | ៥០០០០៛ |
| | | ៤ម² - ៨ម² | ៣០០០៛ | ២០០០៛ | ៩៥០០០៛ | | | ១០០០០០៛ |
| | | ៨ម² - ២០ម² | ៣០០០៛ | ២០០០៛ | ១៩៥០០០៛ | | | ២០០០០០៛ |
| | | ២០ម² ឡើង | ៣០០០៛ | ២០០០៛ | ៣៩៥០០០៛ | | | ៤០០០០០៛ |
| | -បដាផ្សាយពាណិជ្ជកម្ម | | ១០០០៛ | ២០០០៛ | ១២០០០៛ | ៣ខែ | លិខិតអនុញ្ញាត | ១៥០០០៛ |
| | -បណ្ណប្រកាសផ្សាយពាណិជ្ជកម្ម | | ១០០០៛ | ២០០០៛ | ១២០០០៛ | | | ១៥០០០៛ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥-សេវាកម្មស្លាកសញ្ញាអាជីវកម្ម | -ទីតាំងផលិតស្លាកសញ្ញា | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៨០០០០៛ |
| | -ជាងគំនូរ | ៣០០០៛ | ២០០០៛ | ២១០០០៛ | ១ឆ្នាំ | | ២៦០០០៛ |
| ៦-សេវាកម្មចម្លាក់ពុម្ព | -ទីតាំងផលិត លក់ចម្លាក់ពុម្ពស៊ីម៉ង់ | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៨០០០០៛ |
| | -ទីតាំងផលិតលក់ចម្លាក់ម្នាងសិលា | ៣០០០៛ | ២០០០៛. | ៣៥០០០៛ | | | ៨០០០០៛ |
| ៧-សេវាកម្មលក់សៀវភៅ | -បណ្ណាគារ ( ខ្នាតធំ ) | ៣០០០៛ | ២០០០៛ | ៧៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៨០០០០៛ |
| | -បណ្ណាគារ | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | | | ៨០០០០៛ |
| | -តូបលក់សៀវភៅ | ៣០០០៛ | ២០០០៛ | ២១០០០៛ | | | ២៦០០០៛ |
| ៨-សេវាកម្មបញ្ចូលបទភ្លេងទូរសព្ទ | -សេវាកម្មបញ្ចូលបទភ្លេងទូរសព្ទ | ៣០០០៛ | ២០០០៛ | ២១០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ២៦០០០៛ |
| ៩-សេវាកម្មគ្រឿងបំពងសំឡេង | -សេវាកម្មជួលឧបករណ៍ឧគ្ឃោសនសព្ទក្នុងពិធីផ្សេងៗ | ៣០០០៛ | ២០០០៛ | ៣០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៨០០០៛ |
| | -សេវាកម្មជួលធុងបាស់ | ៣០០០៛ | ២០០០៛ | ៣០០០៛ | | | ៨០០០៛ |
| ១០-សេវាកម្មអ៊ុតសក់ កាត់សក់ លម្អក្រចក | -ហាងកាត់សក់ ( ២ - ៤កៅអី ) | ៣០០០៛ | ២០០០៛ | ១៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ២០០០០៛ |
| | -ហាងកាត់សក់ ( លើសពី៥ កៅអី ) | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | | | ៨០០០០៛ |
| | -ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក ( ២ -៤ កៅអី ) | ៣០០០៛ | ២០០០៛ | ៣៥០០០៛ | | | ៨០០០០៛ |
| | -ហាងអ៊ុតសក់ កាត់សក់ លម្អក្រចក ( លើសពី៥កៅអី ) | ៣០០០៛ | ២០០០៛ | ៥៥០០០៛ | | | ៦០០០០៛ |
| ១១-សេវាកម្មសម្អាងការ | -សម្អាងការ ( តម្លៃក្រោម ៥០០ ដុល្លា ) | ៣០០០៛ | ២០០០៛ | ៤៥០០០៛ | ១ឆ្នាំ | បណ្ណអនុញ្ញាត | ៥០០០០៛ |
| | -សម្អាងការ ( តម្លៃក្រោម ១០០០ដុល្លា ) | ៣០០០៛ | ២០០០៛ | ៧៥០០០៛ | | | ៨០០០០៛ |
| | -សម្អាងការ ( តម្លៃលើសពី ១០០០ ដុល្លា ) | ៣០០០៛ | ២០០០៛ | ៩៥០០០៛ | | | ១០០០០០៛ |

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០១២

**តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ ២០១២

ជម្រន្រ្តី

ហ៊ឹម ឆែម